01004663



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 07 / 08 / 2014
ម៉ោង (Time/Heure) : 9h 00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**

សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម

1. បន្ទាប់ពីសំណុំរឿង ០០២ ត្រូវបានបញ្ជូនមកជំនុំជម្រះ កាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យភាគីកំណត់អត្តសញ្ញាណសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងអស់ដែលខ្លួនមានបំណងចង់ឱ្យកោះហៅ ទាក់ទិននឹងការចោទប្រកាន់នានានៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២[1]។ ជាការឆ្លើយតប ភាគីនានាបានស្នើសុំឱ្យស្តាប់សក្ខីកម្មបុគ្គលដែលមានចំនួនសរុបទាំងអស់ ១.០៥៤ នាក់ នៅក្នុងសវនាការ។ ក្រោយពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីបំបែកកិច្ចដំណើរការនីតិវិធី និងដើម្បីបន្តកិច្ចដំណើរការនីតិវិធីជំនុំជម្រះទាក់ទិននឹងបទចោទ និងការចោទប្រកាន់ផ្នែកអង្គហេតុនានាមួយចំនួនតូចនៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ("សំណុំរឿង០០២/០១") អង្គជំនុំជម្រះបានប្រើប្រាស់វិធីសាស្ត្រជាដំណាក់កាល ដើម្បីធ្វើការកំណត់អត្តសញ្ញាណបុគ្គលទាំងឡាយដែលសក្ខីកម្មរបស់បុគ្គលទាំងនោះ ត្រូវបានចាត់ទុកថាមានសារសំខាន់បំផុត ដើម្បីស្តាប់សក្ខីកម្មក្នុងសវនាការទាក់ទិននឹងដំណាក់កាលនីមួយៗនៃការជំនុំជម្រះលើកដំបូងនេះនៅក្នុងសំណុំរឿង០០២។

2. សេចក្តីសម្រេចនេះ បង្ហាញអំពីវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងដែលបានយកមកអនុវត្តដើម្បីកំណត់អត្តសញ្ញាណ និងជ្រើសរើសបុគ្គលទាំងឡាយដែលត្រូវចាត់ទុកថាចាំបាច់ ដើម្បីស្តាប់សក្ខីកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០១ និងអំពីថាតើតម្លៃភ័ស្តុតាងនៃសក្ខីកម្មរបស់បុគ្គលសរុបទាំងអស់ចំនួន ១.០៥៤ នាក់ ដែលភាគីស្នើសុំនៅក្នុងសំណុំរឿង ០០២ ត្រូវបានវាយតម្លៃតាមរបៀបណា។ ជាបញ្ហាទូទៅ បុគ្គលទាំងអស់ដែលភាគីស្នើសុំឱ្យកោះហៅនៅក្នុងសំណុំរឿង ០០២ និងត្រូវបានរាយនាមនៅក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ ស្ថិតនៅក្រោមប្រភេទមួយក្នុងចំណោមប្រភេទទាំងបីខាងក្រោមនេះ៖

i. បុគ្គលដែលត្រូវបានស្តាប់សក្ខីកម្មរួចហើយ នៅក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០១ (ឧបសម្ព័ន្ធ I)

ii. បុគ្គលដែលភាគីស្នើសុំឱ្យកោះហៅនៅក្នុងសំណុំរឿង ០០២/០១ ប៉ុន្តែជាចុងក្រោយមិនត្រូវបានស្តាប់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ (បុគ្គលដែលត្រូវបានបដិសេធ

[1] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ឯកសារ E9 ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១។

មិនស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១ ឬត្រូវបានពន្យារពេលទៅធ្វើការជំនុំ-ជម្រះ នាពេលខាងមុខ) (ឧបសម្ព័ន្ធ II) និង

iii. បុគ្គលដែលមាននៅក្នុងបញ្ជីឈ្មោះដើមរបស់ភាគី អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុងដែលទាក់ទិននឹងសំណុំរឿង០០២ ទាំងមូល ប៉ុន្តែភ័ស្តុតាងរបស់បុគ្គលទាំងនោះមិនត្រូវបានស្នើសុំឱ្យកោះហៅដោយភាគី នៅក្នុងសំណុំរឿង០០២/០១ (ដូច្នេះ សេចក្តីសម្រេចដែលទាក់ទិននឹងករណីនេះ ត្រូវបានពន្យារពេលទៅការជំនុំជម្រះនាពេលខាងមុខ) (ឧបសម្ព័ន្ធ III)។

3. នៅក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មសរុបទាំងអស់ចំនួន ៩២ នាក់។ នៅក្នុងករណីភាគច្រើន បុគ្គលដែលនៅសេសសល់ទាំងនេះដែលត្រូវបានស្នើឡើងដោយភាគីនៅក្នុងសំណុំរឿង ០០២/០១ មិនត្រូវបានស្តាប់ចម្លើយ ដោយផ្អែកលើមូលដ្ឋានថា សក្ខីកម្មរបស់ពួកគាត់មិនពាក់ព័ន្ធ ឬទំនងជាច្រំដែលទៅនឹងភ័ស្តុតាងផ្សេងទៀតដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះ[2]។ បុគ្គលទាំងអស់ដែលភាគីបានស្នើសុំនៅក្នុងសំណុំរឿង ០០២/០១ ត្រូវបានអង្គជំនុំជម្រះពិចារណាក្នុងកិច្ចដំណើរការជំនុំជម្រះ ហើយជាចុងក្រោយបុគ្គលមួយចំនួនទៀត ត្រូវបានស្តាប់ក្នុងករណីគាត់ត្រូវបានបញ្ចូលទៅក្នុងបញ្ជីឈ្មោះបុគ្គលដែលត្រូវស្តាប់សក្ខីកម្ម ។ ចាប់តាំងពីបានកំណត់ជាក់លាក់អំពីបុគ្គលទាំងឡាយដែលនឹងត្រូវកោះហៅឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១[3] អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញអំពីសំអាងហេតុនៃសេចក្តីសម្រេចរបស់ខ្លួន ក្នុងការមិនស្តាប់សក្ខីកម្មរបស់បុគ្គលនៅសេសសល់ដែលភាគីបានស្នើសុំឱ្យកោះហៅនៅក្នុងសំណុំរឿងនេះ។

---

[2] *សូមមើល* វិធាន៨៧(៣)នៃវិធានផ្ទៃក្នុង (ចែងអំពីមូលដ្ឋានជាច្រើនដែលអង្គជំនុំជម្រះអាចបដិសេធចោលសំណើសុំឱ្យពិនិត្យភ័ស្តុតាង ដោយរួមមាននៅពេលដែលអង្គជំនុំជម្រះយល់ឃើញថា ភ័ស្តុតាងដែលស្នើសុំ មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា)។

[3] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើង "ការជូនដំណឹងអំពីសវនាការដែលនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣" ឯកសារ E288, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣។

## ២. ប្រវត្តិនីតិវិធី

4. កាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១ បន្ទាប់ពីការស៊ើបសួរតាមផ្លូវតុលាការអស់រយៈពេល ៣ ឆ្នាំ ដែលក្នុងអំឡុងពេលស៊ើបសួរនេះ បុគ្គលជាច្រើន ត្រូវបានសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ស្តាប់សក្ខីកម្ម ។ បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូងបានទទួលដីកាដំណោះ-ស្រាយក្នុងសំណុំរឿង០០២ ដែលមានចំនួន ១១៣៣ ទំព័រ ជាភាសាខ្មែរ ៧៣៩ ទំព័រ ជាភាសាអង់គ្លេស និង៧៩០ ទំព័រ ជាភាសាបារាំង ដោយបានបញ្ជូនជនជាប់ចោទ នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ជាផ្លូវការ ទៅជំនុំជម្រះ។

5. ជាការឆ្លើយតបទៅនឹងដីកាបង្គាប់ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ របស់អង្គជំនុំជម្រះសាលាដំបូង ភាគីនានាបានស្នើសុំឱ្យស្តាប់សក្ខីកម្មបុគ្គលដែលមានចំនួនសរុបទាំងអស់ ១.០៥៤ នាក់ ដើម្បីដោះស្រាយការចោទប្រកាន់ទាំងអស់នៅ ក្នុងដីកាដំណោះស្រាយសំណុំរឿង០០២។ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យកោះហៅសាក្សីចំនួន ២៤៧ នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣២ នាក់ និងអ្នកជំនាញចំនួន ១៦ នាក់[4]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបាន

---

[4] បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៨០ រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ទី២, ទី៣ (ក), ទី៤ និងទី៥ ឯកសារ E9/4 កថាខណ្ឌ២ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១។ ឧបសម្ព័ន្ធ ១ ៖ សំណើបង្គាប់ឱ្យសាក្សីចូលបង្ហាញខ្លួនក្នុងសវនាការ (បញ្ជីឈ្មោះរួមបញ្ចូលគ្នានៃអ្នកជំនាញការ សាក្សី និងភាគីដើមបណ្តឹងរដ្ឋប្បវេណី) ឯកសារ E9/4.1 ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១។ ឧបសម្ព័ន្ធ ២ ៖ បញ្ជីឈ្មោះអ្នកជំនាញរបស់ ក.ស.ព ឯកសារE9/4.2 ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១។ ឧបសម្ព័ន្ធ ៣៖ បញ្ជីឈ្មោះសាក្សី ឯកសារE9/4.3 ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១។ ឧបសម្ព័ន្ធ ៣ ក ៖ បញ្ជីឈ្មោះសាក្សីរបស់ ក.ស.ព ឯកសារE9/4.3.1 ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១។ ឧបសម្ព័ន្ធ ៤ ៖ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីរបស់ ក.ស.ព ឯកសារE9/4.4 ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១។ ឧបសម្ព័ន្ធ ៥ ឯកសារE9/4.5 ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១។ សូមមើលសេចក្តីសង្ខេបអំពីអ្នកជំនាញ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០ឯកសារE9/13 ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១។ សេចក្តីសង្ខេបអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដោយមានចំណុចនៃដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ - ក.ស.ព ឯកសារE9/13.1 ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ (បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះពីមុនអនុលោមតាមវិធាន៨០របស់ខ្លួន ដើម្បីបង្ហាញឱ្យឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីរនាក់ដែលត្រូវបាន កំណត់អត្តសញ្ញាណនៅក្នុងបញ្ជីឈ្មោះពីមុន អនុលោមតាមវិធាន ៨០ របស់សហព្រះរាជអាជ្ញា ត្រូវបានប្រកាសថាមិនអាចទទួលយកបាន និងសាក្សីមួយរូបទើបតែត្រូវបានទទួលស្គាល់ថ្មីៗជាដើមបណ្តឹងរដ្ឋប្បវេណី)។

ស្នើសុំឱ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៤៦ នាក់, សាក្សី ១៨ នាក់ និងអ្នកជំនាញ ១៥ នាក់[5]។ មេធាវីការពារក្តី នួន ជា ស្នើសុំឱ្យកោះហៅសាក្សីចំនួន ៥២៧ នាក់ អ្នកជំនាញ១៣ នាក់ និងដើមបណ្តឹងរដ្ឋប្បវេណី ៥ នាក់[6]។ មេធាវីការពារក្តី ខៀវ សំផន ស្នើសុំឱ្យកោះហៅសាក្សីចំនួន ៦១ នាក់ និងអ្នកជំនាញចំនួន ៣២ នាក់[7]។ មេធាវីការពារក្តី អៀង ធីរិទ្ធ ស្នើសុំស្តាប់ចម្លើយសាក្សី

---

[5] បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដោយអនុលោមតាមវិធាន៨០ រួមទាំងឧបសម្ព័ន្ធសម្ងាត់១, ២ក, ២ខ, ៣ក, ៣ខ និង៤ ឯកសារE9/4/3 កថាខណ្ឌ៥ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១។ ឧបសម្ព័ន្ធ ១ ៖ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដោយមានពណ៌សម្គាល់ និងមានស្ថិតិរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើ ឯកសារE9/4/3.1 ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១។ ឧបសម្ព័ន្ធ ២ក ៖ បញ្ជីឈ្មោះសាក្សីដែលបានស្នើ (មិនទាមទារវិធានការការពារ) ដោយសហមេធាវីនាំមុខដើមបណ្តឹង-រដ្ឋប្បវេណី ឯកសារE9/4/3.2 ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១។ ឧបសម្ព័ន្ធ ២ខ ៖ បញ្ជីឈ្មោះសាក្សីដែលបានស្នើ (ដែលទាមទារវិធាន ការការពារ)- [សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី] ឯកសារE9/4/3.3 ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១។ ឧបសម្ព័ន្ធ ៣ក ៖ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើ (ដែលមិនទាមទារវិធានការការពារ) ឯកសារE9/4/3.4 ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១។ ឧបសម្ព័ន្ធ ៣ខ ៖ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើ (ទាមទារវិធានការការពារ) សុំដោយសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ឯកសារE9/4/3.5ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១។ ឧបសម្ព័ន្ធ៤៖ បញ្ជី ឈ្មោះអ្នកជំនាញដែលបានស្នើដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ E9/4/3.6 ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១១។

[6] បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំ ឯកសារE9/4/4 ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១១។ ឧបសម្ព័ន្ធ ក ៖ បញ្ជីឈ្មោះសាក្សីដែលស្នើសុំ (ដែលមិនទាមទារវិធានការការពារ)- ក្រុមមេធាវីការពារក្តី នួន ជា ឯកសារ E9/4/4.4 ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១។ ឧបសម្ព័ន្ធ ខ ៖ បញ្ជីឈ្មោះអ្នកជំនាញដែលស្នើសុំដោយក្រុមមេធាវីការពារក្តី នួន ជា ឯកសារE9/4/4.2 ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១។ ឧបសម្ព័ន្ធ គ ៖ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី (មិនទាមទារវិធានការការពារ) ដែលស្នើសុំដោយក្រុមមេធាវីការពារក្តី នួន ជា ឯកសារ E9/4/4.3 ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១១។

[7] បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញដែលស្នើសុំ ឯកសារE9/4/6 ថ្ងៃទី២១ កុម្ភៈ ឆ្នាំ២០១១ (ទោះបីជាយ៉ាងណាក៏ដោយ កត់សម្គាល់ឃើញថា បញ្ជីឈ្មោះនេះ គឺបណ្តោះអាសន្នប៉ុណ្ណោះ និងស្នើសុំអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យធ្វើការកែសម្រួលបញ្ជីឈ្មោះនេះនៅពេលក្រោយ)។ ឧបសម្ព័ន្ធ១ ៖ បញ្ជីឈ្មោះសាក្សីដែលស្នើសុំ (មិនទាមទារវិធានការការពារ) ស្នើដោយមេធាវីការពារក្តី ខៀវ សំផន, ឯកសារ E9/4/6.2 ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១១ (បង្ហាញថា សាក្សីចំនួន ២៦ រូប ដែលមេធាវីការពារក្តី ខៀវ សំផន ស្នើសុំ គឺមាននៅក្នុងបញ្ជីឈ្មោះសាក្សីរបស់សហព្រះរាជ-អាជ្ញា)។ ឧបសម្ព័ន្ធ ២ ៖ បញ្ជីឈ្មោះអ្នកជំនាញដែលស្នើសុំ ឯកសារE9/4/6.3 ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១១។

ទាំងអស់ចំនួន ៨ នាក់ និងអ្នកជំនាញ ១ នាក់[8]។ មេធាវីការពារក្តី អៀង សារី បានស្នើសុំឱ្យកោះហៅអ្នកជំនាញ ៥ នាក់ ប៉ុន្តែបានបញ្ជាក់ថា ខ្លួននឹងមិនបង្ហាញបុគ្គលដែលខ្លួនមានបំណងស្នើសុំឱ្យកោះហៅបន្ថែមទៀតនោះទេ រហូតទាល់តែភស្តុតាងទាំងអស់ប្រឆាំងនឹងជនជាប់ចោទត្រូវបានបង្ហាញជាមុនសិន។ មេធាវីការពារក្តី អៀង សារី ក៏បានស្នើសុំអង្គជំនុំជម្រះអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី អាចស្នើសុំកោះហៅសាក្សីបន្ថែមនៅក្នុងអំឡុងពេលសវនាការ ប្រសិនបើមានតម្រូវការធ្វើដូច្នេះ[9] ។ ក្រោយមក ភាគីនីមួយៗក៏បានដាក់សេចក្តីជំទាស់ទៅនឹងសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលភាគីផ្សេងៗទៀតស្នើសុំផងដែរ[10]។

## ២.១ កិច្ចប្រជុំរៀបចំសវនាការលើកទីមួយ និងសវនាការបឋម

6. នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ កាលពីខែមេសា ឆ្នាំ២០១១ ("កិច្ចប្រជុំរៀបចំសវនាការលើកទីមួយ") និងមុនពេលមានការបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងទៅភាគី អំពីបំណងរបស់ខ្លួនក្នុងការចាប់ផ្តើមសវនាការលើអង្គសេចក្តីនៅក្នុងសំណុំរឿង ០០២ តាមលំដាប់លំដោយដូចខាងក្រោម៖

---

[8] បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ឯកសារE9/4/5 ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ (ការរួមបញ្ចូល ដោយយោងទៅលើបញ្ជីឈ្មោះរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង) ។ ឧបសម្ព័ន្ធ៖ បញ្ជីឈ្មោះសាក្សីរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ឯកសារ E9/4/5.1 ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១។

[9] បញ្ជីស្នើឈ្មោះអ្នកជំនាញរបស់លោក អៀង សារី និងសេចក្តីជូនដំណឹងរបស់លោក អៀង សារី ទាក់ទងនឹងបញ្ជីឈ្មោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ឯកសារE9/4/2 ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១។ ឧបសម្ព័ន្ធ៖ បញ្ជីឈ្មោះអ្នកជំនាញដែលស្នើសុំដោយក្រុមមេធាវីការពារក្តី អៀង សារី ឯកសារ E9/4/2.2 ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១។

[10] *សូមមើលឧទា.* ការជំទាស់ជាបឋមរបស់លោក អៀង សារី ចំពោះសំណើសុំអ្នកជំនាញរបស់ ក.ស.ព និងសំណើសុំការអនុញ្ញាតដាក់សារណាបន្ថែមទៀតក្នុងរយៈពេល ៣០ ថ្ងៃ ឯកសារE9/4/9 ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១។ ការជំទាស់របស់លោក អៀង សារី ចំពោះសំណើរបស់ ក.ស.ព សុំកោះហៅ [TCE-69] មកធ្វើជាសាក្សី ឯកសារ E9/4/8 ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១។ សេចក្តីជំទាស់ទៅនឹងការចូលខ្លួនរបស់អ្នកជំនាញមួយចំនួន ឯកសារE9/4/10 ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១។ សេចក្តីបញ្ជាក់របស់អ្នកស្រី អៀង ធីរិទ្ធ អំពីចេតនាជំទាស់ទៅនឹងសាក្សី និងអ្នកជំនាញដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះសាក្សីរបស់សហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និង នួន ជា ឯកសារ E9/4/11 ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១។ សេចក្តីសង្កេតបឋមទាក់ទងនឹងសាក្សីដែលភាគីបានស្នើសុំ ឯកសារE9/4/12 ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១។ ការជំទាស់របស់សហព្រះរាជអាជ្ញាទៅនឹងសាក្សី និងអ្នកជំនាញដែលបានស្នើឡើងដោយភាគីផ្សេងទៀត ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ចំនួន១១ ឯកសារE9/14/1/1 ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១។

១) រចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ

២) តួនាទីរបស់ជនជាប់ចោទម្នាក់ៗ ក្នុងអំឡុងពេលមុនការបង្កើតកម្ពុជាប្រជាធិប-តេយ្យ រួមទាំងនៅពេលដែលជនជាប់ចោទបានទទួលតួនាទីនោះ

៣) តួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ជនជាប់ចោទតាមការចាត់តាំង វិសាលភាពនៃសិទ្ធិអំណាចរបស់ជនជាប់ចោទ និងខ្សែបណ្តាញទំនាក់ទំនងក្នុងអំឡុងពេលយុត្តាធិការរបស់ អ.វ.ត.ក និង

៤) គោលនយោបាយកម្ពុជាប្រជាធិបតេយ្យស្តីពីបញ្ហានានា ដែលបានលើកឡើងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[11]។

7. ភាគីត្រូវបានស្នើសុំឱ្យផ្តល់បញ្ជីឈ្មោះបន្ថែម អំពីបុគ្គលទាំងអស់ពីក្នុងបញ្ជីឈ្មោះដើម អនុលោមតាមវិធាន ៨០ ដែលភាគីយល់ឃើញថា មានភាពពាក់ព័ន្ធបំផុតដើម្បីស្តាប់សក្ខីកម្មទាក់ទិននឹងប្រធានបទនៃការជំនុំជម្រះនៅដំណាក់កាលដំបូងឱ្យត្រឹមថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១[12]។ អង្គជំនុំ-ជម្រះសង្កេតឃើញថា មានភាពចាំបាច់ក្នុងការកាត់បន្ថយចំនួនសាក្សីដែលនឹងត្រូវកោះហៅឱ្យមកផ្តល់សក្ខីកម្ម ដើម្បីជាប្រយោជន៍ដល់សិទ្ធិជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា បុគ្គលជាច្រើននៅក្នុងបញ្ជីឈ្មោះរបស់ភាគីអនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង គឺជាបញ្ជីឈ្មោះបន្ថែមទៅលើបុគ្គលទាំងឡាយណាដែលត្រូវបានស្តាប់សក្ខីកម្មនៅចំពោះមុខ ក.ស.ច.ស រួចហើយ។ ភាគីទាំងអស់ត្រូវបានស្នើសុំឱ្យបញ្ជាក់អំពីមូលដ្ឋាន ថាតើហេតុអ្វីបានជាបុគ្គលថ្មីទាំងនេះត្រូវបានស្នើសុំនៅពេលនេះ និងបញ្ជាក់ថាតើហេតុអ្វីបានជាបុគ្គលដែលស្នើសុំទាំងនេះ មិនត្រូវបានស្នើសុំឱ្យស្តាប់សក្ខីកម្មនៅចំពោះមុខ ក.ស.ច.ស (ឬ ប្រសិនបើត្រូវបានបដិសេធដោយ ក.ស.ច.ស សូមបង្ហាញអំពី

---

[11] ប្រតិចារឹក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១១ ទំព័រ ៥២។ *សូមមើលផងដែរ* របៀបវារៈសម្រាប់កិច្ចប្រជុំរៀបចំសវនាការ ឯកសារ E9/5/1 ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១។

[12] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើង "សេចក្តីណែនាំនៅមុនពេលសវនាការបឋមពាក់ព័ន្ធ និងសាក្សីដែលភាគីស្នើសុំកោះហៅ" ឯកសារE93 ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១។ *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ទំព័រ២៣-២៤។

សំអាងហេតុនៃការបដិសេធរបស់ ក.ស.ច.ស នេះផង ប្រសិនបើដឹង)[13]។ បញ្ជីឈ្មោះបន្ថែមទាំងនេះ រួមមានបុគ្គលចំនួន៧២៨ នាក់ ដែលក្នុងចំណោមនោះ បុគ្គលចំនួន ១៤៧ នាក់ត្រូវបានស្តាប់សក្ខីកម្មពីមុនដោយ ក.ស.ច.ស រួចហើយ ហើយបុគ្គលចំនួន ៥៨១ នាក់ គឺជាបុគ្គលថ្មី[14]។

8. នៅសវនាការបឋម អង្គជំនុំជម្រះបានស្នើបញ្ជីឈ្មោះបណ្តោះអាសន្នដែលមានបុគ្គលចំនួន ៥៦ នាក់ ដែលអង្គជំនុំជម្រះមានបំណងកោះហៅក្នុងអំឡុងពេលជំនុំជម្រះនៅដំណាក់កាលដំបូង

---

[13] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើង "សេចក្តីណែនាំនៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ" ឯកសារE93 ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១។

[14] ការចាត់ចំណាត់ថ្នាក់សាក្សី និងអ្នកជំនាញដែលស្នើសុំដើម្បីរៀបចំសវនាការបឋម ឯកសារE93/2 ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១១។ ឧបសម្ព័ន្ធ១៖ សាក្សីដែលបានស្តាប់រួចហើយដោយសហចៅក្រមស៊ើបអង្កេត ឯកសារ 93/2.1 ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ (ការស្នើសុំកោះហៅសាក្សីចំនួន ២០ នាក់ ដែលបានផ្តល់សក្ខីកម្មរួចហើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ។ សាក្សី ៨ នាក់ ក្នុងចំណោមសាក្សីទាំងនោះ ត្រូវបានផ្តល់សក្ខីកម្មរួចហើយ តាមសំណើរបស់សហព្រះរាជអាជ្ញា)។ ឧបសម្ព័ន្ធ២៖ សាក្សី និងអ្នកជំនាញថ្មី ឯកសារE93/2.2 ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១១។ ព័ត៌មានបន្ថែមរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញពាក់ព័ន្ធនឹងប្រធានបទជំនុំជម្រះទាំងបួនដំបូង និងសំណើសុំការគូសបញ្ជាក់អំពីចំណងជើងប្រធានបទទីបួន "គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ" ឯកសារE93/2/1 ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង នៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ ឯកសារE93/3 ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១។ ឧបសម្ព័ន្ធ ១ ៖ សាក្សីស្នើឡើងដោយសហព្រះរាជអាជ្ញាសម្រាប់ដំណាក់កាលទីមួយនៃសវនាការ ឯកសារE93/3.1 ថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០១១។ សេចក្តីសង្ខេបដែលត្រូវបានធ្វើបច្ចុប្បន្នភាពអំពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារE93/4 ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ ។ ភ័ស្តុតាងសម្រាប់ការរៀបចំកិច្ចដំណើរការនីតិវិធីតុលាការ បញ្ជីឈ្មោះសាក្សីបឋម សេចក្តីសង្ខេបដើមបណ្តឹងរដ្ឋប្បវេណី ក្រុមមេធាវីការពារក្តី នួន ជា ឯកសារE93/4.1 ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១។ ភ័ស្តុតាងសម្រាប់ការរៀបចំកិច្ចដំណើរការនីតិវិធីតុលាការ បញ្ជីឈ្មោះសាក្សីបឋម គុណវុឌ្ឍិ និងសេចក្តីសង្ខេបរបស់អ្នកជំនាញ ក្រុមមេធាវីការពារក្តី នួន ជា ឯកសារE93/4.2 ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១។ ភ័ស្តុតាងសម្រាប់ការរៀបចំកិច្ចដំណើរការនីតិវិធីតុលាការ បញ្ជីឈ្មោះសាក្សីបឋម សេចក្តីសង្ខេប សាក្សី ក្រុមមេធាវីការពារក្តី នួន ជា ឯកសារE93/4.3 ថ្ងៃទី២១ ខែ មិថុនា ឆ្នាំ ២០១១។ *សូមមើល ផងដែរ* ព័ត៌មានបន្ថែមរបស់សហមេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ចំពោះបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញពាក់ព័ន្ធនឹងប្រធានបទជំនុំជម្រះទាំងបួនដំបូង ឯកសារE93/1ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១។

និងអញ្ជើញឲ្យភាគីនានាផ្តល់មតិយោបល់លើបញ្ជីឈ្មោះនេះ[15]។ អង្គជំនុំជម្រះសាលាដំបូងបាន អនុញ្ញាតឲ្យភាគីដាក់សេចក្តីសង្កេតបន្ថែមលើបញ្ជីឈ្មោះបណ្តោះអាសន្ននេះជាលាយលក្ខណ៍អក្សរ ដោយអង្គជំនុំជម្រះបានបញ្ជាក់ថា ភាគីអាចកំណត់អត្តសញ្ញាណសាក្សី អ្នកជំនាញ ឬដើមបណ្តឹង រដ្ឋប្បវេណីបន្ថែមដែលខ្លួនយល់ថាសំខាន់ចាំបាច់ដើម្បីស្តាប់សក្ខីកម្ម ទាក់ទិននឹងប្រធានបទនៃការ ជំនុំជម្រះទាំងនេះ[16]។

9. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានស្នើសុំសាក្សីចំនួន ១៣ នាក់ និងអ្នកជំនាញ ២ នាក់ បន្ថែមទៀត[17]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំសាក្សីថ្មីមួយ នាក់ និងអ្នកជំនាញថ្មីមួយនាក់ ប៉ុន្តែបានបង្ហាញអំពីចេតនារបស់ខ្លួនក្នុងការបន្ថែមដើមបណ្តឹងរដ្ឋ ប្បវេណីច្រើននាក់ចូលទៅក្នុងបញ្ជីឈ្មោះ ដោយសារតែការបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៧២៨ នាក់ របស់អង្គបុរេជំនុំជម្រះ នាពេលថ្មីៗនេះ ទៅក្នុងសំណុំរឿង០០២[18]។ កាលពីថ្ងៃទី

---

[15] ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ៧-៩, ១៧-១៨, ២២-២៣។ សំណៅឯកសារក្រដាសនៃបញ្ជី ឈ្មោះនេះ ត្រូវបានចែកជូនភាគីនៅក្នុងសវនាការបឋម។ ឯកសារនេះ បង្កើតបានជាមូលដ្ឋាននៃឧបសម្ព័ន្ធសម្ងាត់ (ក) របស់អង្គជំនុំជម្រះ៖ ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការដំណាក់ កាលដំបូងនៃសំណុំរឿង០០២ ឯកសារE131/1.1 ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១។

[16] ប្រតិចារឹក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ២។

[17] សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យស្តាប់អ្នកជំនាញ ២ រូប និងសាក្សី១៣រូប បន្ថែម នៅក្នុងដំណាក់កាលដំបូងនៃ សវនាការ និងការជូនដំណឹងអំពីចេតនាដាក់ឈុតវីដេអូខ្លីៗចំនួន៧ ទាក់ទងទៅនឹង នួន ជា នៅចំពោះមុខអង្គជំនុំជម្រះ សាលាដំបូង ដោយអនុលោមតាមវិធាន៨៧(៤) ឯកសារE93/7 ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១។ ឧបសម្ព័ន្ធ ១ ៖ ឈុតខ្លីៗអំពីការសម្ភាសន៍ នួន ជា ឯកសារE93/7.2 ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១។ ឧបសម្ព័ន្ធ ២៖ ឈុតវីដេអូខ្លីៗ ចំនួន៧ ទាក់ទងនឹងការសម្ភាសន៍ នួន ជា ដោយថេត សម្បត្តិ ឯកសារE93/7.3 ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១។

[18] សេចក្តីសង្កេតរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅលើបញ្ជីឈ្មោះសាក្សី ដើមបណ្តឹង រដ្ឋប្បវេណី និងអ្នកជំនាញបណ្តោះអាសន្នដែលរៀបចំដោយអង្គជំនុំជម្រះសាលាដំបូង ឯកសារE93/6 ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១។ នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានអនុញ្ញាតតាមសំណើរបស់សហមេធាវី នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យពន្យារពេលក្នុងការដាក់បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីបន្ថែម ដោយសារ តែសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ បានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី បន្ថែមចំនួន ១៧២៨ នាក់ ឲ្យចូលរួមនៅក្នុងការជំនុំជម្រះ។ អង្គជំនុំជម្រះណែនាំឲ្យសហមេធាវីនាំមុខតំណាងដើម បណ្តឹងរដ្ឋប្បវេណីបញ្ជាក់ត្រឹមថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១ អំពីដើមបណ្តឹងរដ្ឋប្បវេណីណាខ្លះដែលត្រូវបានទទួល ស្គាល់ដោយសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ថាអាចពាក់ព័ន្ធដល់បញ្ហា

២៨ ខែ កក្កដា ឆ្នាំ ២០១១ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលបានកែសម្រួល ពាក់ព័ន្ធនឹងប្រធានបទជំនុំជម្រះចំនួនបួននៅដំណាក់កាលដំបូង ដោយស្នើសុំបន្ថែមដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៤ នាក់ ដើម្បីផ្តល់សក្ខីកម្ម[19]។ មេធាវីការពារក្តី នួន ជា បានស្នើសុំសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមចំនួន ៩៥ នាក់ ហើយមេធាវីការពារក្តី ខៀវ សំផន ស្នើសុំបន្ថែមសាក្សីចំនួន ១៨ នាក់ និងអ្នកជំនាញចំនួន ៣ នាក់[20]។ មេធាវីការពារក្តី អៀង សារី ស្នើសុំឲ្យអង្គជំនុំជម្រះបដិសេធសាក្សីជាច្រើនដែលស្នើសុំដោយភាគីនានា ប៉ុន្តែមេធាវីការពារក្តី អៀង សារី មិនបានស្នើសុំសាក្សីបន្ថែមឡើយ[21]។

---

អង្គហេតុ ដើម្បីធ្វើការសម្រេច ក្នុងអំឡុងដំណាក់កាលជំនុំជម្រះលើកដំបូង ព្រមទាំងប្រធានបទជំនុំជម្រះក្រោយៗទៀត។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើង "សេចក្តីណែនាំដល់ភាគី (មុនពេលមានការពិភាក្សានៅក្នុងកិច្ចសវនាការបឋមស្តីពីបញ្ជីឈ្មោះបណ្តោះអាសន្នរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី) ឯកសារE108 ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១)"។ *សូមមើលផងដែរ* ប្រតិចារិក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ទំព័រ ១១៥-១២១។

[19] ព័ត៌មានបន្ថែមរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលទាក់ទិននឹងប្រធានបទជំនុំជម្រះចំនួនបួនក្នុងដំណាក់កាលដំបូង ឯកសារE108/1 ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១១។ ឧបសម្ព័ន្ធ៖ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានកែសម្រួល ដោយសហមេធាវីនាំមុខ ដែលពាក់ព័ន្ធនឹងផ្នែកជំនុំជម្រះចំនួនបួននៅក្នុងដំណាក់កាលដំបូង ឯកសារE108/1.1 ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១។

[20] សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម ឯកសារE93/9 ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១។ ឧបសម្ព័ន្ធ៖ បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ឯកសារE93/9.1 ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១។ សំណើសុំដាក់បន្ថែមសាក្សីទៅក្នុងបញ្ជីបណ្តោះអាសន្ន សម្រាប់ដំណាក់កាលដំបូងៗនៃការជំនុំជម្រះ ឯកសារE93/8 ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១១។ ឧបសម្ព័ន្ធ១៖ សាក្សីដែលបានស្តាប់ចម្លើយរួចដោយសហចៅក្រមស៊ើបអង្កេត ឯកសារE93/8.1 ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១។ ឧបសម្ព័ន្ធ ២៖ សាក្សីថ្មី ឯកសារE93/8.2 ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១។

[21] សេចក្តីសង្កេតរួមរបស់លោក អៀង សារី ស្តីពីសាក្សី និងអ្នកជំនាញមួយចំនួនដែលសហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី នួន ជា បានស្នើសុំកោះហៅ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញបញ្ជីឈ្មោះសាក្សីបណ្តោះអាសន្ន ឯកសារE93/12 ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១។

## ២.២ ការកំណត់អត្តសញ្ញាណបុគ្គលដែលត្រូវស្តាប់ចម្លើយក្នុងអំឡុងពេលការជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

10. កាលពីថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ត្រូវបានបំបែក ហើយវិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានកំណត់ត្រឹមតែការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុងដំណាក់កាលទីមួយ និងទីពីរ[22]។ ដោយពិចារណាលើសារណារបស់ភាគីទាក់ទិននឹងបញ្ជីឈ្មោះដំបូងនៃបុគ្គលដែលត្រូវបានស្នើសុំនៅក្នុងសវនាការបឋម កាលពីថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះបានបង្ហាញអំពីការបង្កើនចំនួនបុគ្គលក្នុងបញ្ជីឈ្មោះដល់ទៅ ៦៥ នាក់ ដែលជាសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវស្នើសុំឱ្យកោះហៅស្តាប់សក្ខីកម្មទាក់ទិននឹងចំណុច អង្គហេតុជំនុំជម្រះចំនួនបួននៅដំណាក់កាលដំបូង[23]។ អង្គជំនុំជម្រះ

---

[22] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ឯកសារE124 ថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ២០១១ ("សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ")។ *សូមមើលផងដែរ* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន" ឯកសារE163/5 ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ (អនុញ្ញាតតាមសំណើរបស់សហព្រះរាជអាជ្ញាមួយផ្នែកសុំឱ្យពង្រីកវិសាលភាពសំណុំរឿង០០២/០១ និងបញ្ចូលបន្ថែមទៅក្នុងវិសាលភាពសំណុំរឿងអំពីការកាប់សម្លាប់នៅទួលពោធិ៍ជ្រៃក្រោយពីការជួលរំលំភ្នំពេញ)។ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E284, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ("សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ") (បញ្ជាក់ថាវិសាលភាពនៃផ្នែកអង្គហេតុក្នុងសំណុំរឿង០០២/០១ បានរួមបញ្ចូលទាំងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំក្នុងដំណាក់កាលទីមួយ និងទីពីរ និងការកាប់សម្លាប់នៅទួលពោធិ៍ជ្រៃ)។

[23] ឧបសម្ព័ន្ធសម្ងាត់ ក ៖ ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង០០២ ឯកសារ E131/1.1 ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១។ បញ្ជីនេះ រួមមានសាក្សីចំនួន ៥២ នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៧ នាក់ និងអ្នកជំនាញចំនួន ៦ នាក់។ ក្នុងចំណោមបុគ្គលទាំងនោះ សហព្រះរាជអាជ្ញាស្នើសុំឱ្យស្តាប់សក្ខីកម្មបុគ្គលទាំងនេះចំនួន ៥៧ នាក់ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ៤ នាក់, ក្រុមមេធាវីការពារក្តី ខៀវ សំផន ស្នើសុំស្តាប់សក្ខីកម្មបុគ្គលចំនួន ២១ នាក់, ក្រុមមេធាវីការពារក្តី នួន ជា ស្នើសុំស្តាប់សក្ខីកម្មបុគ្គល ១៧ នាក់ និង ក្រុមមេធាវីការពារក្តី អៀង សារី ស្នើសុំស្តាប់សក្ខីកម្មបុគ្គលចំនួន ៥ នាក់។

បានបញ្ជាក់ថា បញ្ជីឈ្មោះនេះមិនបានរួមបញ្ចូលសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលនឹងត្រូវកោះហៅពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទីមួយ និងទីពីរ ដែលនឹងត្រូវជូនដំណឹងដល់ភាគីនៅពេលក្រោយ[24]។

## ២.៣ ការកាត់បន្ថយឈ្មោះក្នុងបញ្ជីចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការលើកទីពីរ

11. សវនាការលើអង្គសេចក្ដីនៅក្នុងសំណុំរឿង ០០២/០១ បានចាប់ផ្ដើមកាលពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ។ ដោយពិចារណាទៅលើភ័ស្តុតាងទាំងអស់ដែលបានស្ដាប់នៅចំពោះមុខខ្លួនក្នុងអំឡុងពេលដំណាក់កាលដំបូងនៃការជំនុំជម្រះ កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះបានស្នើសុំឱ្យដកឈ្មោះចេញ ឬលើកពេលផ្ដល់សក្ខីកម្មរបស់បុគ្គលចំនួន ១៥ រូប នៅក្នុងបញ្ជីឈ្មោះចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០១១ ដោយសារតែអង្គជំនុំជម្រះចាត់ទុកភ័ស្តុតាងដែលស្នើសុំនេះទំនងជាច្រំដែលជាមួយនឹងភ័ស្តុតាងដែលមានស្រាប់នៅចំពោះមុខអង្គជំនុំជម្រះ[25]។ អង្គជំនុំជម្រះបញ្ជាក់បន្ថែមថា ដើម្បីជាប្រយោជន៍នៃប្រសិទ្ធភាពសវនាការ អង្គជំនុំជម្រះបានសម្រេចនាពេលថ្មីៗនេះថា សក្ខីកម្មរបស់អ្នកជំនាញមួយចំនួនពុំត្រូវស្ដាប់សក្ខីកម្មក្នុងអំឡុងពេលសវនាការដំណាក់កាលដំបូង ដោយហេតុថា (បន្ទាប់ពីមានដីកាបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០២) ភ័ស្តុតាងរបស់ពួកគាត់ហាក់ដូចជាលែងពាក់ព័ន្ធសំខាន់ទៅនឹងបទចោទ និងការចោទប្រកាន់អង្គហេតុនៅក្នុងសំណុំរឿង០០២/០១ ដែលមានចំនួនតិចជាងមុននោះ[26]។

---

[24] ឧបសម្ព័ន្ធសម្ងាត់ ក៖ ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង០០២ ឯកសារE131/1.1 ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ ទំព័រ១។

[25] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើង៖"ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ ក្នុងសំណុំរឿង០០២/០១ និងការអនុវត្តវិធានការបន្ថែមទៀតដែលបានរៀបចំឡើងដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ" ឯកសារ E218 ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ៥។

[26] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើង "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមទៀតដែលបានរៀបចំឡើងដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ" ឯកសារ

12. កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ កិច្ចប្រជុំរៀបចំសវនាការលើកទីពីរ ត្រូវបានកោះប្រជុំ ដោយនៅក្នុងកិច្ចប្រជុំនោះ អង្គជំនុំជម្រះបានស្នើសុំឱ្យភាគីនានាផ្តល់មតិយោបល់ទាក់ទិននឹងសំណើសុំទាំងនេះ។ អង្គជំនុំជម្រះក៏បានអញ្ជើញឱ្យភាគីផ្តល់ជាមតិយោបល់ទាក់ទិននឹងលទ្ធភាពកាត់បន្ថយបញ្ជីឈ្មោះនេះបន្ថែមទៀត[27]។ យន្តការផ្សេងទៀតត្រូវបានផ្តល់ឱ្យដល់ភាគីនានា ដើម្បីអាចឱ្យពួកគាត់បង្ហាញអំពីភស្តុតាងពាក់ព័ន្ធ និងជាភស្តុតាងដែលផ្តល់ការគាំទ្រជាសំខាន់នៅក្នុងសវនាការ ដោយមិនពន្យារពេលកិច្ចដំណើរការនីតិវិធីដោយមិនត្រឹមត្រូវនោះទេ[28]។

13. បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការលើកទីពីរ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលា-ដំបូង បានចងក្រងបញ្ជីឈ្មោះរបស់បុគ្គលទាំងអស់ ដែលត្រូវបានកំណត់អត្តសញ្ញាណសម្រាប់ការប្រជុំពិភាក្សាគ្នានៅក្នុងសវនាការនោះ។ បញ្ជីឈ្មោះរួមនេះ ត្រូវបានដាក់នៅក្នុងសំណុំរឿងបន្ទាប់ពីភាគីទាំងអស់បានបញ្ជាក់ច្បាស់លាស់ថា បញ្ជីឈ្មោះរួមនេះ ពិតជាឆ្លុះបញ្ចាំងត្រឹមត្រូវអំពីជំហររបស់ភាគីនានា ទាក់ទិននឹងបុគ្គលទាំងឡាយដែលភាគីយល់ឃើញថាគួរតែត្រូវបានស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១[29]។

---

E218 កថាខណ្ឌ៤ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២។ សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ ឯកសារE215 កថាខណ្ឌ ៣ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២។

[27] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើង “ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនា-ការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមទៀតដែលបានរៀបចំឡើងដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ” ឯកសារ E218 ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ៦, ១១។

[28] *សូមមើលឧទា.* សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារE96/7 ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ (ផ្អែកតាមកាលៈទេសៈមួយចំនួន អនុញ្ញាតឱ្យភាគីនានាដាក់ចម្លើយជាលាយលក្ខណ៍អក្សរជូនដល់អង្គជំនុំជម្រះដោយមិនបាច់មានសក្ខីកម្មផ្ទាល់មាត់របស់បុគ្គលនោះ នៅពេលដែលភស្តុតាងទំនងជាគាំទ្រភស្តុតាងផ្សេងទៀតនៅចំពោះមុខអង្គជំនុំជម្រះ)។

[29] បុគ្គលនានាដែលភាគីស្នើសុំផ្តល់សក្ខីកម្មនៅពេលសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាមៗ ឯកសារE236 ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២។

## ២.៤ បុគ្គលដែលស្នើសុំទាក់ទិននឹងការផ្លាស់ទីលំនៅប្រជាជន និងទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ

14. នៅមុនកិច្ចប្រជុំរៀបចំសវនាការលើកទី២ អង្គជំនុំជម្រះក៏បានស្នើឲ្យភាគីទាំងអស់បង្ហាញអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវស្តាប់សក្ខីកម្មទាក់ទិននឹងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ[30]។ ភាគីបានស្នើសុំឲ្យស្តាប់សក្ខីកម្មសរុបទាំងអស់ចំនួន ៥៣ នាក់ ទាក់ទិននឹងការចោទប្រកាន់ទាំងនេះ រួមមានបុគ្គលចំនួន ២១ នាក់ ដែលត្រូវបានស្នើសុំដោយសហព្រះរាជអាជ្ញា, បុគ្គលចំនួន ១៦ នាក់ ស្នើសុំដោយសហ-មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើបញ្ជីឈ្មោះអាទិភាព (និងបុគ្គលចំនួន ២១ នាក់បន្ថែមទៀត ដែលមាននៅក្នុងបញ្ជីឈ្មោះបន្ថែម) ហើយបុគ្គលចំនួន ១៦ នាក់ ត្រូវបានស្នើសុំដោយមេធាវីការពារក្តី នួន ជា[31]។ ក្រុមមេធាវីការពារក្តី អៀង សារី និង ខៀវ សំផន ពុំបានស្នើសុំឲ្យស្តាប់សក្ខីកម្មសាក្សីបន្ថែមទៀតទេ ទាក់ទិននឹងចំណុចអង្គហេតុនៃការជំនុំជម្រះទាំងនេះ។

15. កាលពីថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានកំណត់បញ្ជីឈ្មោះសាក្សីអាទិភាព និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៥ នាក់ ហើយបញ្ជីឈ្មោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីបម្រុងចំនួន ១១ នាក់ យកចេញពីបញ្ជីឈ្មោះបុគ្គលដែលភាគីបានស្នើសុំ[32]។ ក្នុងចំណោមបុគ្គលទាំង ២៥ នាក់ ដែលត្រូវបានបញ្ជាក់ថានឹងទំនងជាត្រូវបានអង្គជំនុំជម្រះស្តាប់សក្ខីកម្ម ដើម្បីគាំទ្រដល់ចំណុចអង្គហេតុនៃការជំនុំជម្រះក្តីនេះ សហព្រះរាជអាជ្ញាស្នើសុំឲ្យកោះហៅបុគ្គលចំនួន ១៤

---

[30] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើង "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង០០២/០១ និងការអនុវត្តវិធានការបន្ថែមទៀតដែលបានរៀបចំឡើងដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ" ឯកសារ E218 កថាខណ្ឌ១១ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២។

[31] បុគ្គលនានាដែលភាគីស្នើសុំផ្តល់សក្ខីកម្មនៅពេលសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាមៗ ឯកសារ E236 ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២។

[32] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើង "ការបញ្ជាក់ជាបឋមអំពីបុគ្គលដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងអំឡុងពេលសវនាការលើចំណុចអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន ក្នុងសំណុំរឿង ០២/០១" ឯកសារ E236/1 ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២។

នាក់, សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំ ១១ នាក់, មេធាវីការពារក្តី នួន ជា ស្នើសុំចំនួន ៣ នាក់ និង មេធាវីការពារក្តី ខៀវ សំផន ស្នើសុំឱ្យកោះហៅចំនួន ២ នាក់ [33]។

16. កាលពីថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានយល់ស្របតាមសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឱ្យដាក់បញ្ចូលការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ទៅក្នុងសំណុំរឿង ០០២/០១ ដោយសារការសម្លាប់ទាំងនេះពាក់ព័ន្ធនឹងហេតុការណ៍ដែលបានកើតឡើងភ្លាមៗ បន្ទាប់ពីមានការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ[34]។ ក្នុងការគាំទ្រដល់ការពង្រីកវិសាលភាពនេះ អង្គជំនុំជម្រះយល់ស្របជាមួយសហព្រះរាជអាជ្ញាដែលបានស្នើសុំឱ្យស្តាប់សក្ខីកម្មសាក្សីចំនួន ២ នាក់ ដើម្បីគាំទ្រដល់ចំណុចអង្គហេតុនៃការជំនុំជម្រះនេះ[35]។

---

[33] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានកម្មវត្ថុ "ការបញ្ជាក់ជាបឋមអំពីបុគ្គលដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងអំឡុងសវនាការលើចំណុចអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងសំណុំរឿង ០០២/០១" ឯកសារ E236/1 ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២។

[34] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើង "សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារE163/5" ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ៣ (ការកាប់សម្លាប់នៅទួលពោធិ៍ជ្រៃក្រោយពីការរួលរលំភ្នំពេញភ្លាមៗ គឺជាការពង្រីកវិសាលភាពសមស្របនៃការចោទប្រកាន់ដែលមានស្រាប់ក្នុងសំណុំរឿង ០០២/០១ ដែលអាចត្រូវបានដាក់បញ្ចូល បន្ទាប់ពីមានការពង្រីកវិសាលភាពនៃការជំនុំជម្រះ ប៉ុន្តែមិនបានរួមបញ្ចូលការពិចារណាលើការកាប់សម្លាប់នានាដែលបានកើតឡើងនៅចន្លោះឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៧ ឡើយ)។

[35] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើង"សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារE163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន ឯកសារ E163/5" ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ៣។ *សូមមើលផងដែរ* បុគ្គលនានាដែលភាគីស្នើសុំផ្តល់សក្ខីកម្មនៅពេលសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាមៗ ឯកសារE236 ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១២ (បញ្ចូលឈ្មោះបុគ្គលទាំងបួនរូបដែលភាគីស្នើសុំ ទាក់ទិននឹងចំណុចអង្គហេតុនៃការជំនុំជម្រះនៅទួលពោធិ៍ជ្រៃ)។

## ២.៥ សាក្សីដែលមេធាវីការពារក្តីស្នើសុំនៅក្នុងសំណុំរឿង ០០២/០១ បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការលើកទីពីរ

17. នៅកិច្ចប្រជុំរៀបចំសវនាការលើកទីពីរ និងក្រោយមកទៀត ភាគីត្រូវបានផ្តល់ឱកាសឲ្យកំណត់អត្តសញ្ញាណបុគ្គលបន្ថែមក្នុងចំនួនតិចតួចប៉ុណ្ណោះ ដែលភាគីចាត់ទុកថាសំខាន់ត្រូវស្តាប់សក្ខីកម្មនៅក្នុងសវនាការ។ អង្គជំនុំជម្រះបានគូសបញ្ជាក់យ៉ាងច្បាស់អំពីភាពចាំបាច់សម្រាប់ឲ្យក្រុមមេធាវីការពារក្តីបង្ហាញអំពីបុគ្គលណាខ្លះដែលខ្លួនចាត់ទុកថាសំខាន់ ដើម្បីបដិសេធការចោទប្រកាន់មកលើជនជាប់ចោទ[36]។ ក្នុងការឆ្លើយតប មេធាវីការពារក្តី អៀង សារី បានស្នើសុំឲ្យកោះហៅបុគ្គលចំនួន ២ នាក់ ហើយមេធាវីការពារក្តី ខៀវ សំផន បានស្នើសុំឲ្យកោះហៅបុគ្គលចំនួន ៦ នាក់[37]។

18. លើសពីនេះទៀត មេធាវីការពារក្តី នួន ជា បានស្នើសុំឲ្យស្តាប់សក្ខីកម្មបុគ្គលចំនួន ៦៦ នាក់ បន្ថែមទៀតដែលមិនទាក់ទិននឹងតួនាទីរបស់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ២០ នាក់ ទាក់ទិននឹងបរិបទព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ និង ៤៦ នាក់ ថែមទៀត ទាក់ទិននឹងដំណើរការ និងការអនុវត្ត

---

[36] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើង "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមទៀតដែលបានរៀបចំឡើង ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ" ឯកសារ E218 ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១២ កថាខណ្ឌ ១២ (ជនជាប់ចោទក៏ត្រូវបានស្នើឲ្យធ្វើការបញ្ជាក់ផងដែរថា បុគ្គលចំនួនតិចតួចណាខ្លះដែលខ្លួនចាត់ទុកថាជា "សាក្សីសំខាន់ ដើម្បីបដិសេធការចោទប្រកាន់មកលើជនជាប់ចោទ" ប៉ុន្តែអង្គជំនុំជម្រះរំឭកភាគីថា ដោយសារតែចំនួនបុគ្គលច្រើនពេកដែលភាគីបានស្នើសុំឲ្យកោះហៅក្នុងសំណុំរឿង ០០២ មានតែបុគ្គលដែលពាក់ព័ន្ធបំផុតក្នុងចំនួនតិចប៉ុណ្ណោះ ដែលអាចត្រូវបានអង្គជំនុំជម្រះស្តាប់សក្ខីកម្ម ក្នុងក្របខណ្ឌនៃការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស)។

[37] បុគ្គលនានាដែលភាគីស្នើសុំផ្តល់សក្ខីកម្មនៅពេលសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាមៗ ឯកសារ E236 ថ្ងៃទី ០២ ខែតុលា ឆ្នាំ ២០១២ កថាខណ្ឌ៥។

នៃការស៊ើបសួរតាមផ្លូវតុលាការរយៈពេល ៣ ឆ្នាំ នៅក្នុងសំណុំរឿង០០២ ឬដើម្បីគាំទ្រដល់ការចោទប្រកាន់ទូទៅទាក់ទិននឹងឯករាជ្យភាពនៃការជ្រៀតជ្រែកតុលាការ និងខាងនយោបាយ[38]។

## ២.៦ ការកំណត់អត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធនឹងដំណាក់កាលចុងក្រោយនៃការជំនុំជម្រះ

19. កាលពីខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានបញ្ជាក់ថា រយៈពេលកំណត់ជាក់លាក់មួយនៅក្នុងសវនាការ នឹងត្រូវផ្តល់ឲ្យសម្រាប់ការបង្ហាញភ័ស្តុតាងអំពីអាកប្បកិរិយា និងផលប៉ះពាល់ដល់ជនរងគ្រោះ និងបានស្នើឲ្យមេធាវីការពារក្តី និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញអត្តសញ្ញាណបុគ្គលទាំងនោះដែលខ្លួនចាត់ទុកថាចាំបាច់ ដើម្បីស្តាប់សក្ខីកម្មទាក់ទិន នឹងចំណុចអង្គហេតុនៃការជំនុំជម្រះចុងក្រោយទាំងនេះ[39]។ មេធាវីការពារក្តី ខៀវ សំផន ស្នើសុំឲ្យកោះហៅសាក្សីអត្តចរិតចំនួន ៥ នាក់ ក្នុងអំឡុងពេលបីថ្ងៃ ដែលត្រូវបានផ្តល់ឲ្យសម្រាប់គោលបំណងនេះ ហើយមេធាវីការពារក្តី នួន ជា បានស្នើសុំឲ្យកោះហៅសាក្សីមួយនាក់[40]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់បញ្ជីឈ្មោះបុគ្គលចំនួន ១៤ នាក់ (ដោយរួមបញ្ចូលអ្នកជំនាញចំនួនមួយនាក់) ដែលខ្លួនស្នើសុំឲ្យកោះហៅក្នុងអំឡុងពេលសវនាការដែលផ្តោតទៅលើព្យសនកម្មដែលជនរងគ្រោះទទួលរង ដោយជនរងគ្រោះមួយចំនួនបានផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍[41]។

---

[38] បុគ្គលនានាដែលភាគីស្នើសុំផ្តល់សក្ខីកម្មនៅពេលសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាមៗ ឯកសារ E236 ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ៥។

[39] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើង"សេចក្តីជូនដំណឹងបន្ថែមពាក់ព័ន្ធនឹងការកំណត់កាលបរិច្ឆេទនៃសវនាការ" ឯកសារE236/5 ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ២, ៤។

[40] បុគ្គលនានាដែលភាគីស្នើសុំផ្តល់សក្ខីកម្មនៅពេលសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងអំឡុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាមៗ ឯកសារE236 ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ៨។ សំណើសុំកោះហៅសាក្សី TCW-២២៣ ដែលពាក់ព័ន្ធនឹងអត្តចរិតរបស់ នួន ជា ឯកសារ E236/5/1 ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[41] សំណើរបស់សហមេធាវីនាំមុខ សុំឲ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណីដែលមាននៅក្នុងបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវបានកែប្រែ ដើម្បីផ្តល់សក្ខីកម្មក្នុងអំឡុងសវនាការស្តីពីផលប៉ះពាល់ (ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់) ឯកសារE236/5/3/1 ថ្ងៃទី០៦ ខែ ឧសភា ឆ្នាំ ២០១៣។ ឧបសម្ព័ន្ធ ១៖ ការកំណត់កាលបរិច្ឆេទដែលស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការលើផលប៉ះពាល់ជនរងគ្រោះ ឯកសារE236/5/3/1.1 ថ្ងៃទី ០៦

## ២.៧ កិច្ចប្រជុំរៀបចំសវនាការចុងក្រោយ និងសំណើសុំស្ដាប់សក្ខីកម្មបន្ថែមមុនពេលបញ្ចប់សំណុំរឿង ០០២/០១

20. បន្ទាប់ពីមានសវនាការលើការបំបែកកិច្ចដំណើរការនីតិវិធីនៅខែ កុម្ភៈ និងខែ មីនា ឆ្នាំ ២០១៣ នៅក្នុងសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាបានដាក់បញ្ជីឈ្មោះបុគ្គលដែលខ្លួនយល់ឃើញថាចាំបាច់ ក្នុងការស្ដាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ដើម្បីឱ្យស្របតាមបន្ទុកក្នុងការបង្ហាញភ័ស្ដុតាងក្នុងការជំនុំជម្រះក្ដី ដោយមានភ្ជាប់ក្នុងឧបសម្ព័ន្ធអំពីកាលបរិច្ឆេទជាសំណើសម្រាប់ការជំនុំជម្រះក្ដី[42]។

21. នៅថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានកំណត់ពេលបើកកិច្ចប្រជុំរៀបចំសវនាការចុងក្រោយ ("កិច្ចប្រជុំចុងក្រោយ") នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ដើម្បីអាចឱ្យពិភាក្សាពីបញ្ហានានា ដែលនៅសេសសល់មុនពេលបញ្ចប់កិច្ចដំណើរការនីតិវិធីលើភ័ស្ដុតាងក្នុងសំណុំរឿង០០២/០១[43]។ សេចក្ដីព្រាងឧបសម្ព័ន្ធនានាភ្ជាប់នឹងសេចក្ដីសម្រេចនេះត្រូវបានផ្ដល់ជូនភាគីមុនពេលកិច្ចប្រជុំរៀបចំសវនាការចុងក្រោយ ដើម្បីសម្រួលការពិភាក្សាទៅលើបញ្ជីឈ្មោះបុគ្គលទាំងអស់ដែលកំណត់ដោយអង្គជំនុំជម្រះថានឹងត្រូវកោះហៅមកផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ និងដើម្បីកំណត់បញ្ហានានាដែលនៅសេសសល់ពាក់ព័ន្ធនឹងឧបសម្ព័ន្ធទាំងនេះ និងបុគ្គល

---

ខែ ឧសភា ឆ្នាំ ២០១៣។ *សូមមើលផងដែរ* ដីកាបង្គាប់ឱ្យមានការរៀបចំផ្ដល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាមTCCP-13ឯកសារE236/5/3/2ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣។ អង្គជំនុំជម្រះអនុញ្ញាតឱ្យស្ដាប់សក្ខីកម្មបុគ្គលទាំងអស់ដែលសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្នើសុំទាក់ទិននឹងផលប៉ះពាល់ដល់ជនរងគ្រោះ ដោយរក្សាទុកថ្ងៃជំនុំជម្រះមួយចំនួនសម្រាប់គោលបំណងនេះ។ បុគ្គលទាំងអស់ចំនួន ១៦ នាក់ ដែលសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំដើម្បីគាំទ្រដល់ចំណុចអង្គហេតុនេះត្រូវបានស្ដាប់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ៖ ឧបសម្ព័ន្ធ ១ ផ្នែកទី ១០។

[42] ឧបសម្ព័ន្ធ ក៖ កាលវិភាគសម្រាប់សវនាការស្នើឡើងដោយសហព្រះរាជអាជ្ញាសម្រាប់ដំណាក់កាលចុងក្រោយនៃសំណុំរឿង០០២, ឯកសារ E273.1, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៣។

[43] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើង"ការជូនដំណឹងអំពីសវនាការដែលនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភ័ស្ដុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣", ឯកសារ E288, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣, កថាខណ្ឌ ២។

នានាដែលមានក្នុងបញ្ជីនេះ។ នៅឯកិច្ចប្រជុំរៀបចំសវនាការចុងក្រោយ និងក្រោយពេលកិច្ចប្រជុំនោះបានបញ្ចប់ភ្លាមៗ ភាគីបានស្នើសុំស្តាប់សក្ខីកម្មបុគ្គលដែលមានឈ្មោះសរុបចំនួន ១៦ នាក់ ក្នុងសំណុំរឿង ០០២/០១ មុនពេលបញ្ចប់សវនាការដេញដោលលើភ័ស្តុតាង (៥ នាក់ ទាក់ទិននឹងការផ្លាស់ទីលំនៅដោយបង្ខំ ២ នាក់ ទាក់ទិននឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន និង ៩ នាក់ ទាក់ទិននឹងទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ)[44]។

## ៣. សំអាងហេតុ

### ៣.១ ក្របខណ្ឌគតិយុត្តិ

22. ផ្អែកតាមក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងត្រូវជ្រើសរើសបុគ្គលទាំងឡាយណាដែលខ្លួនចាត់ទុកថាពិតជាអាចនាំទៅរកការបង្ហាញការពិត ដោយស្របទៅនឹងលក្ខខណ្ឌតម្រូវរួមដែលថា កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក "ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ" ហើយថា

---

44 ការជូនដំណឹងរបស់សហព្រះរាជអាជ្ញាក្នុងការឆ្លើយតបទៅនឹងសំណើរបស់មន្ត្រីជាន់ខ្ពស់ក្នុងការផ្តល់ព័ត៌មានមុនពេលកិច្ចប្រជុំរៀបចំសវនាការ,ឯកសារE288/3 ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣ (ដែលស្នើសុំស្តាប់សក្ខីកម្មបុគ្គល៥នាក់បន្ថែមទៀត ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅដោយបង្ខំ, សាក្សី ២ នាក់ទៀត ពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន និង ៣ នាក់ពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ)។ ការជូនដំណឹងរបស់សហព្រះរាជអាជ្ញានូវព័ត៌មានពិស្តារក្នុងការគាំទ្រដល់សំណើសុំកោះហៅសាក្សីបន្ថែមពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃអនុលោមតាមវិធាន ៨៧(៤), ឯកសារ E292/1, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ (ដែលស្នើសុំស្តាប់សក្ខីកម្មបុគ្គល ៥ នាក់បន្ថែមទៀត ពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ ក្នុងករណីដែលបុគ្គល ៣ នាក់ ត្រូវបានកំណត់អត្តសញ្ញាណក្នុងឯកសារ E288/3 មិនអាចត្រូវបានគេរកឃើញ)។ សំណើបន្ទាន់ស្នើសុំកោះហៅសាក្សីសំខាន់ៗទាក់ទិននឹងទួលពោធិ៍ជ្រៃ, ឯកសារ E291, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ (ដែលគាំទ្រដល់សំណើរបស់សហព្រះរាជអាជ្ញាសុំកោះហៅសាក្សី ៥ នាក់ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងឯកសារ E292/1 ទាក់ទិននឹងទួលពោធិ៍ជ្រៃ និងស្នើសុំថា បុគ្គលទី ៦ គួរតែត្រូវកោះហៅមកផ្តល់សក្ខីកម្ម)។ *សូមមើលផងដែរ,* សំណើសុំឱ្យទទួលយកភ័ស្តុតាងថ្មីសុំកោះហៅ Rob Lemkin និងសុំចាប់ផ្តើមកិច្ចស៊ើបសួរ, ឯកសារ E294, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៣។ សំណើសុំកោះហៅសាក្សី ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីគោលនយោបាយនៃការកំណត់មុខសញ្ញាមន្ត្រីសាធារណរដ្ឋខ្មែរ, ឯកសារ E291/2, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣ (ដែលស្នើសុំស្តាប់សក្ខីកម្មបុគ្គល ១១០ រូបបន្ថែមទៀត)។

“ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប”[45]។ ដោយមានឆន្ទានុសិទ្ធិរបស់ខ្លួន អង្គជំនុំជម្រះក៏អាចស្តាប់សក្ខីកម្មរបស់អ្នកជំនាញអំពីប្រធានបទណាមួយដែលចាត់ទុកថាសំខាន់នៅក្នុងសវនាការ[46]។

23. អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះអាចបដិសេធមិនស្តាប់សក្ខីកម្ម ដែល (ក) មិនជាប់ពាក់ព័ន្ធ ឬជាន់គ្នា (ខ) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ (គ) មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង (ឃ) ច្បាប់មិនអនុញ្ញាត ឬ (ង) មានចេតនាពន្យារពេលកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍[47]។

24. ទោះបីវិធាន ៨៤(១) នៃវិធានផ្ទៃក្នុងជាភាសាអង់គ្លេសចែងថា ជនជាប់ចោទ “ត្រូវមានសិទ្ធិផ្តាច់មុខក្នុងការស្នើសុំឱ្យកោះហៅសាក្សីដែលដាក់បន្ទុកដែលជនជាប់ចោទពុំទាន់មានឱកាសបានតទល់ក្នុងដំណាក់កាលមុនជំនុំជម្រះ” តែចំណុចនេះមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងវិធាននេះជាភាសាផ្សេងៗទេ[48]។ ក្នុងករណីណាក៏ដោយ អនុវិធាននេះត្រូវតែយកមកវាយតម្លៃឡើងវិញ ដោយ

---

[45] វិធាន ២១(១)(ក) និង ២១(៤) នៃវិធានផ្ទៃក្នុង; *សូមមើលផងដែរ* វិធាន ៨៥ នៃវិធានផ្ទៃក្នុង (ចែងថា ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឱ្យប្រព្រឹត្តទៅបានដោយសេរី និងអាចបដិសេធនូវរាល់នីតិវិធីដែលនាំឱ្យមានការពន្យាពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត)។

[46] វិធាន ៣១(១) នៃវិធានផ្ទៃក្នុង។

[47] វិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង; *សូមមើលផងដែរ រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច*, សាលក្រមសាលាដំបូង, អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក (សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧/អវតក/អជសដ), ឯកសារ E188, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ៤១; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Karemera និងអ្នកផ្សេងទៀត*, សេចក្តីសម្រេចទៅលើបណ្តឹងសាទុក្ខរបស់ Mathieu Ngirumpatse ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨, តុលាការកំពូលនៃតុលាការ ICTR (សំណុំរឿងលេខ ICTR-98-44-AR73.14), ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩, កថាខណ្ឌ ២៥ (ដោយបានសន្និដ្ឋានថា លក្ខណៈដដែលនៃសក្ខីកម្មត្រូវបានពិចារណាជាកត្តាមួយថាតើសក្ខីកម្មជាការចាំបាច់ឬយ៉ាងណា)។

[48] *ប្រៀបធៀប* វិធាន ៨៤(១) នៃវិធានផ្ទៃក្នុង៖ “*L'accusé a le droit d'exiger la comparution d'un témoin avec lequel il n'a pas eu l'occasion d'être confronté au stade de l'instruction*” និង “ជនជាប់ចោទមានសិទ្ធិស្នើសុំឱ្យកោះហៅសាក្សីដាក់បន្ទុកដែលជនជាប់ចោទ មិនទាន់មានឱកាស តទល់នៅដំណាក់កាលមុនពេលជំនុំជម្រះ”។

ពិចារណាទៅលើក្របខណ្ឌគតិយុត្តិទាំងមូលនៅ អ.វ.ត.ក ដែលសង្កត់ធ្ងន់ទៅលើតុល្យភាពនៃសិទ្ធិរបស់ភាគីទាំងអស់ និងតម្រូវការចាំបាច់ឱ្យមានការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស[49]។

25. វិធានស្តីពីនីតិវិធីនានាដែលត្រូវបានបង្កើតឡើងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏បានបង្ហាញថា ក្នុងការសម្រេចពីបុគ្គលដែលត្រូវផ្តល់សក្ខីកម្មនៅពេលសវនាការ ត្រូវមានតុល្យភាពរវាងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងចំពោះមុខជាមួយនឹងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយគ្មានការពន្យារពេលដោយមិនត្រឹមត្រូវ[50]។ ទាក់ទិននឹងការជំនុំជម្រះបទឧក្រិដ្ឋអន្តរជាតិដែលជាញឹកញាប់មានលក្ខណៈស្មុគស្មាញ និងមានវិសាល-ភាពទូលំទូលាយ ភារកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការធានានូវកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស ជាញឹកញាប់តម្រូវឱ្យមានតុល្យភាពរវាងផលប្រយោជន៍នានារួមទាំងភារកិច្ចរបស់ព្រះរាជអាជ្ញាក្នុងការបង្ហាញអំពីភស្តុតាងដែលមាន ដើម្បីបញ្ជាក់ពីរឿងក្តីរបស់ខ្លួន និងសិទ្ធិរបស់ជនជាប់ចោទ[51]។ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិ *មិនអចិន្ត្រៃយ៍* ភាគី

---

49 *សូមមើល* វិធាន ២១(១)(ក) និង ២១(៤) នៃវិធានផ្ទៃក្នុង; ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, មាត្រា ៣៣ ថ្មី។

50 *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ndayambaje និងអ្នកផ្សេងទៀត,* សេចក្តីសម្រេចលើសំណើរបស់ Joseph Kanyabashi សុំកែប្រែបញ្ជីសាក្សីរបស់គាត់ ចម្លើយតបរបស់មេធាវីការពារក្តីចំពោះដីកាកំណត់ពេលវេលាថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៦ និងសំណើរបស់ Ndayambaje សុំអូសបន្លាយពេលក្នុងការឆ្លើយតបទៅនឹងដីកាកំណត់ពេលវេលាថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៦, សាលាដំបូងនៃតុលាការ ICTR (សំណុំរឿងលេខ ICTR-98-42-T), ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៧, កថាខណ្ឌ ៣០; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Karemera និងអ្នកផ្សេងទៀត, ,* សេចក្តីសម្រេចទៅលើបណ្តឹងសាទុក្ខរបស់ Mathieu Ngirumpatse ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨, តុលាការកំពូលនៃតុលាការ ICTR (សំណុំរឿងលេខ ICTR-98-44-AR73.14), ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩, កថាខណ្ឌ ២៩។

51 *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Prlić និងអ្នកផ្សេងទៀត,* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់អយ្យការពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលកាត់បន្ថយរយៈពេលសម្រាប់ការចោទប្រកាន់របស់អយ្យការ, តុលាការកំពូលនៃតុលាការ ICTY (សំណុំរឿងលេខ IT-04-74-AR73.4), ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៧, កថាខណ្ឌ ១៤, ១៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Gotovina និងអ្នកផ្សេងទៀត,* សេចក្តីសម្រេចលើសំណើរបស់អយ្យការសុំបន្ថែមសាក្សីមួយរូបទៅក្នុងបញ្ជីឈ្មោះសាក្សីតាមវិធាន ៦៥ *ស្ទួនពីរ* និងសុំបន្ថែមឯកសារជំនួយចំនួន ៣ ទៅលើបញ្ជីវត្ថុតាង តាមវិធាន ៦៥ *ស្ទួនពីរ,* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (សំណុំរឿងលេខ IT-06-90-T), ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៨, កថាខណ្ឌ ៣; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Gotovina និងអ្នកផ្សេងទៀត,* សេចក្តីសម្រេច

ទទួលខុសត្រូវជាសំខាន់ ចំពោះការកំណត់អត្តសញ្ញាណសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះក្តី។ ផ្ទុយទៅវិញនៅ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងជាអ្នកទទួលបន្ទុកក្នុងការដឹកនាំសវនាការ និងមានការទទួលខុសត្រូវជាសំខាន់ ក្នុងការជ្រើសរើសបុគ្គលដែលនឹងត្រូវកោះហៅមកផ្តល់សក្ខីកម្មក្នុងសវនាការ។ ហេតុនេះ សញ្ញាណនៃសមាមាត្ររវាងការបែងចែកពេលវេលាសម្រាប់អយ្យការធ្វើការចោទប្រកាន់ និងសម្រាប់មេធាវីការពារក្តីដើម្បីការពារក្តីមានកម្រិតកំណត់នៅ អ.វ.ត.ក[52]។ ថ្វីត្បិតតែយ៉ាងនេះក្តី អង្គជំនុំជម្រះព្យាយាមស្តាប់សក្ខីកម្មសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលភាគីទាំងអស់បានស្នើសុំ[53]។

26. លក្ខណៈសំខាន់បន្ថែមមួយទៀតនៃក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក គឺតម្រូវការក្នុងការពិចារណាដល់ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលចូលរួមការជំនុំជម្រះក្តី ដើម្បីគាំទ្រដល់អយ្យការ និងស្វែងរកសំណងផ្លូវចិត្ត និងជាសមូហភាព ពាក់ព័ន្ធនឹងព្យសនកម្មដែលបានទទួលរងដោយសារបទឧក្រិដ្ឋនានាដែលជនជាប់ចោទត្រូវបានចោទប្រកាន់[54]។ ទោះបីជាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានអះអាង ពីសិទ្ធិផ្តាច់មុខក្នុងការសម្រេចអំពីថាតើ

---

លើសំណើទីពីរ និងទីបីរបស់មេធាវីការពារក្តី Čermak ដើម្បីបន្ថែមសាក្សីមួយរូបទៅក្នុងបញ្ជីឈ្មោះសាក្សីតាមវិធាន ៦៥ *ស្ទួនពីរ* (ង), អង្គជំនុំជម្រះសាលាដំបូងនៃ ICTY (សំណុំរឿងលេខ IT-06-90-T), ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០០៩, កថាខណ្ឌ ៧; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Gotovina និងអ្នកផ្សេងទៀត*, សេចក្តីសម្រេចលើសំណើទីបួនរបស់មេធាវីការពារក្តី Čermak សុំកែប្រែបញ្ជីសាក្សីតាមវិធាន ៦៥ *ស្ទួនពីរ* (ង), អង្គជំនុំជម្រះសាលាដំបូងនៃ ICTY (សំណុំរឿងលេខ IT-06-90-T), ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៩, កថាខណ្ឌ ៣។

[52] *សូមមើលឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Orić,* សេចក្តីសម្រេចបន្ទាន់បង្ខំស្តីពីរយៈពេលនៃការការពារក្តី, អង្គជំនុំជម្រះសាលាដំបូងនៃ ICTY (សំណុំរឿងលេខIT-03-68-AR73.2), ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៥, កថាខណ្ឌ ៨។

[53] ក្នុងចំណោមបុគ្គលចំនួន ៩២នាក់ ដែលត្រូវបានស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ទាំងមូល មានចំនួន៦០ នាក់ត្រូវបានស្នើឡើងដោយសហព្រះរាជអាជ្ញា, ២០ នាក់ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, ១៩ នាក់ដោយមេធាវីការពារក្តី នួន ជា, និង ២២ នាក់ដោយមេធាវីការពារក្តី ខៀវ សំផន។ បុគ្គលជាច្រើនក្នុងចំណោម ៩២ នាក់ត្រូវបានស្តាប់សក្ខីកម្មក្នុងពេលសវនាការដែលបានស្នើឡើងដោយភាគីជាច្រើន (*សូមមើល* ឧបសម្ព័ន្ធ ១)។

[54] វិធាន ២៣(១)(ក) និង (ខ) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* វិធាន ២១(១) នៃវិធានផ្ទៃក្នុង (ចែងថា ក្របខណ្ឌគតិយុត្តនៅអ.វ.ត.ក"ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់-ចោទ និងជនរងគ្រោះ")។

ដើមបណ្ដឹងរដ្ឋប្បវេណីណាខ្លះដែលនឹងត្រូវមកផ្ដល់សក្ខីកម្មនៅពេលជំនុំជម្រះ (និងកាត់បន្ថយឈ្មោះក្នុងបញ្ជីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងករណីចាំបាច់)[55]ក៏ដោយ ក៏អង្គជំនុំជម្រះបានសង្កត់ធ្ងន់ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីទាំងមូលថា នៅ អ.វ.ត.ក ការសម្រេចអំពីភ័ស្ដុតាងដែលត្រូវយកមកដេញដោលនៅក្នុងសវនាការ គឺជាសមត្ថកិច្ចផ្ដាច់មុខរបស់អង្គជំនុំជម្រះសាលាដំបូង[56]។

27. អាស្រ័យហេតុនេះ អង្គជំនុំជម្រះត្រូវស្វែងរកការពិត ខណៈដែលស្របពេលជាមួយគ្នានោះត្រូវជៀសវាង "ការចំណាយពេលមិនចាំបាច់"[57]។ ការស្វែងរកការពិតមិនតម្រូវដល់ការផ្ដល់សក្ខីកម្មពីសាក្សីដែលមានចំនួនមិនកំណត់ទេ ហើយថ្វីបើ អង្គជំនុំជម្រះសាលាដំបូងបានថ្លឹងថ្លែងយ៉ាងពេញលេញដល់ភាពស្មុគស្មាញនៃសំណុំរឿងនេះ និងភ័ស្ដុតាងដែលជនជាប់ចោទស្នើសុំក៏ដោយ ក៏វាបានបង្ហាញយ៉ាងច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យកាត់បន្ថយចំនួនសាក្សី ដែលភាគីនានាបានស្នើសុំឱ្យផ្ដល់សក្ខីកម្មដែរ[58]។ តុលាការ និងសាលាក្ដីអន្តរជាតិផ្សេងទៀតក៏បានស្វែងរកវិធានការដើម្បីធានាសេដ្ឋកិច្ចតុលាការ និងកាត់បន្ថយបញ្ជីឈ្មោះសាក្សីជាច្រើនរបស់ភាគីទៅតាមកាលៈទេសៈ ក្នុងករណីដែលការកាត់បន្ថយបញ្ជីឈ្មោះនោះមានសំអាងហេតុត្រឹមត្រូវ បន្ទាប់ពីបានពិភាក្សាដេញដោល និងពុំមានផលប៉ះពាល់ជាអវិជ្ជមានទៅលើភាពយុត្តិធម៌នៃការជំនុំជម្រះ ឬទៅលើសមត្ថភាពក្នុងការបង្ហាញការការពារក្ដីយ៉ាងមានប្រសិទ្ធភាពនោះ[59]។

---

[55] សំណើជាបន្ទាន់របស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំឱ្យមានការបញ្ជាក់បំភ្លឺ ព្រមទាំងសុំពន្យាពេលវេលា ក្នុងការឆ្លើយតបចំពោះសេចក្ដីណែនាំលេខ E93 របស់អង្គជំនុំជម្រះសាលាដំបូង, ឯកសារ E93/5, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១, កថាខណ្ឌ ២៥។

[56] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សេចក្ដីណែនាំដល់ភាគី (មុនពេលមានការពិភាក្សានៅក្នុងកិច្ចសវនាការបឋមស្ដីពីបញ្ជីបណ្ដោះអាសន្នឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី)", ឯកសារ E108, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១, កថាខណ្ឌ ៥; *សូមមើលផងដែរ* វិធាន ៨៥(១) នៃវិធានផ្ទៃក្នុង។

[57] វិធាន ៨៥(១) នៃវិធានផ្ទៃក្នុង។

[58] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Nshogoza,* សេចក្ដីសម្រេចលើសំណើសុំពិចារណាជាថ្មីលើដីការបស់អង្គជំនុំជម្រះបញ្ជូនរឿងឱ្យមេធាវីការពារក្ដីកាត់បន្ថយបញ្ជីឈ្មោះសាក្សីរបស់ខ្លួន, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (សំណុំរឿងលេខ ICTR-07-91-T), ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩, កថាខណ្ឌ ១, ៨។

[59] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Karemera និងអ្នកផ្សេងទៀត,* សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ Mathieu Ngirumpatse ពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨, តុលាការកំពូលនៃតុលាការ ICTR (សំណុំរឿងលេខ ICTR-98-44-AR73.14), ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩, កថាខណ្ឌ ១៧ ដល់

28. នៅចំពោះមុខ អ.វ.ត.ក សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការកោះហៅសាក្សី អាចបើកផ្លូវឱ្យប្តឹងសាទុក្ខបាន តែនៅពេលមានសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើអង្គសេចក្តីតែប៉ុណ្ណោះ[60]។

## ៣.២ មូលដ្ឋានសម្រាប់ការវិនិច្ឆ័យរបស់អង្គជំនុំជម្រះក្នុងការជ្រើសរើសបុគ្គលដែលត្រូវបានស្នើសុំទាក់ទងនឹងដំណាក់កាលផ្សេងៗនៃសវនាការលើសំណុំរឿង ០០២/០១

29. យោងទៅលើវិធីសាស្ត្រជាដំណាក់ៗរបស់អង្គជំនុំជម្រះក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលបានចាត់ទុកថាមានការពាក់ព័ន្ធបំផុតដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសវនាការ និងឱកាសជាច្រើនដែលត្រូវបានផ្តល់ជូនភាគីដើម្បីបញ្ចេញមតិទៅលើភស្តុតាងដែលបានស្នើសុំនោះ សេចក្តីសម្រេចនេះផ្តោតទៅលើបុគ្គលទាំងអស់ដែលអង្គជំនុំជម្រះ ឬភាគីបានកំណត់យ៉ាងជាក់លាក់ថាចាំបាច់ត្រូវស្តាប់សក្ខីកម្មនៅក្នុងអំឡុងពេលសវនាការក្នុងសំណុំរឿង ០០២/០១ ដែលបុគ្គលទាំងនោះមិនត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មនៅឡើយ។ ខាងក្រោមនេះ អង្គជំនុំជម្រះសូមផ្តល់មូលហេតុរបស់ខ្លួនចំពោះការមិនបានកោះហៅ ឬចំពោះការពន្យារការកោះហៅទៅសវនាការនាថ្ងៃខាងមុខ ចំនួនបុគ្គលដែលអង្គជំនុំជម្រះបានបញ្ជាក់ខាងដើមថា អង្គជំនុំជម្រះអាចនឹងកោះហៅ (ឬដែលត្រូវបានភាគីកំណត់ថា ចាំបាច់ត្រូវស្តាប់សក្ខីកម្មនៅក្នុងអំឡុងពេលសវនាការក្នុងសំណុំរឿង០០២/០១)។ បុគ្គលដែលនៅសេសសល់ពីរ ១.០៥៤ នាក់ ដែលត្រូវបានស្នើសុំនៅក្នុងសំណុំរឿង ០០២

២៧ (ដោយពិចារណាថា ការកាត់បន្ថយបញ្ជីសាក្សីរបស់ជនជាប់ចោទពីសាក្សីចំនួន ៣៥៤ នាក់មកត្រឹម ៣៥ នាក់ត្រូវបានអនុញ្ញាត ដោយសារថា ចំនួន ៣៥ នាក់នេះគ្រប់គ្រាន់សម្រាប់ឱ្យជនជាប់ចោទអាចការពារខ្លួនបានហើយ); *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Nshogoza,* សេចក្តីសម្រេចលើសំណើសុំឱ្យពិចារណាជាថ្មីលើដីការបស់អង្គជំនុំជម្រះបង្គាប់មេធាវីការពារក្តីកាត់បន្ថយបញ្ជីឈ្មោះសាក្សីរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងនៃតុលាការICTR (សំណុំរឿងលេខ ICTR-07-91-T), ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩, កថាខណ្ឌ ១, ៨ (ដែលបានអនុញ្ញាតឱ្យកាត់បន្ថយបញ្ជីសាក្សីមួយពីសាក្សីចំនួន ៤០ នាក់មកត្រឹម ១០ នាក់); *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Nyiramasuhuko និងអ្នកផ្សេងទៀត,* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ Joseph Kanyabashi ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង II ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៧ ដែលពាក់ព័ន្ធនឹងការបដិសេធសំណើសុំផ្លាស់ប្តូរបញ្ជីឈ្មោះសាក្សីរបស់គាត់, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR (សំណុំរឿងលេខ ICTR-98-42-AR73), ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៧។

[60] វិធាន ៨៤(៤) នៃវិធានផ្ទៃក្នុង។

01004687



ទាំងមូល (ដែលមិនត្រូវបានកំណត់អត្តសញ្ញាណថា ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដោយអង្គជំនុំជម្រះ ឬភាគីណាមួយនោះ) ត្រូវបានយកមកពិភាក្សានៅក្នុងផ្នែក ៣.៤។

### ៣.២.១ បុគ្គលនានាដែលត្រូវបានស្នើសុំទាក់ទងនឹងបរិបទប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍ផ្សេងទៀត ដែលស្ថិតនៅក្រៅអំឡុងពេលនៃការចោទប្រកាន់

30. ដោយយល់ឃើញទៅលើភាពពាក់ព័ន្ធមានកម្រិតនៃការពិចារណាទាំងនេះ និងចំនួនបុគ្គលដ៏ច្រើនដែលត្រូវបានស្នើសុំឱ្យស្តាប់សក្ខីកម្មទាក់ទងនឹងពួកគាត់ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ជូននៅដំណាក់កាលដំបូងនៃកិច្ចដំណើរការនីតិវិធីថា បញ្ហាបរិបទប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍នានាដែលស្ថិតនៅក្រៅយុត្តាធិការពេលវេលារបស់ អ.វ.ត.ក នឹងត្រូវបានយកមកពិចារណាតែក្នុងករណីដែលមានការពាក់ព័ន្ធជាក់ស្តែងទៅនឹងបញ្ហាទាំងឡាយដែលស្ថិតក្នុងយុត្តាធិការ អ.វ.ត.ក និងវិសាលភាពនៃសវនាការដែលបានកំណត់ដោយអង្គជំនុំជម្រះប៉ុណ្ណោះ[61]។ នៅក្នុងអំឡុងពេលសវនាការលើសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានកំណត់យ៉ាងជាក់លាក់ និងស្តាប់សក្ខីកម្មពីបុគ្គលពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រដូចខាងក្រោម៖

ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៨៥ ក្លាន ហ្វិត
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១២៣ រម៉ាម យុន
សាក្សី TCW-៣៩៥ ឡុង នរិន្ទ
សាក្សី TCW-៥៤២ ប្រាក់ យុត

31. ភស្តុតាងជាឯកសារសំខាន់ៗជាច្រើនដែលពាក់ព័ន្ធទៅនឹងស្ថានភាពមុនឆ្នាំ ១៩៧៥ ហើយដែលអាចពាក់ព័ន្ធនឹងបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក៏ត្រូវបានយកមកដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅក្នុងអំឡុងពេលធ្វើសវនាការលើសំណុំរឿង ០០២/០១។ លើសពីនេះទៀត នៅក្នុងពេលសវនាការ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ភស្តុតាងអំពីព្រឹត្តិការណ៍នានានៅមុនឆ្នាំ ១៩៧៥ លើបុគ្គលមួយចំនួនដូចខាងក្រោម៖

---

[61] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "សេចក្តីណែនាំនៅមុនពេលសវនាការបឋម ពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំឱ្យកោះហៅ ឯកសារ E93 ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១។

សាក្សី TCW-៥៣៦ Francois PONCHAUD
អ្នកជំនាញ TCE-១១ David CHANDLER
អ្នកជំនាញ TCE-៦៥ Philip SHORT
អ្នកជំនាញ TCE-៣៣ Stephen HEDER

32. នៅដំណាក់កាលដំបូងនៃកិច្ចដំណើរការនីតិវិធី និងម្តងទៀតនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យស្តាប់សក្ខីកម្មរបស់បុគ្គលមួយចំនួនធំ ពាក់ព័ន្ធនឹងបរិបទប្រវត្តិសាស្ត្រនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាពិសេសទាក់ទងនឹងតួនាទីរបស់សហរដ្ឋអាមេរិក និងប្រទេសវៀតណាម និងស្ថានភាពសង្គម និងសេដ្ឋកិច្ចមុនឆ្នាំ ១៩៧៥ នៅក្នុងប្រទេសកម្ពុជា[62]។ ដោយសារជនជាប់ចោទក្នុងសំណុំរឿង ០០២/០១ ត្រូវបានចោទប្រកាន់អំពីព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅក្រោយការដួលរលំនៃរបបទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងដោយសារចំនួនសក្ខីកម្មជាច្រើនត្រូវបានស្តាប់ ឬបើពុំនោះទេ មាននៅក្នុងភស្តុតាងទាក់ទងនឹងកត្តាប្រវត្តិសាស្ត្ររួចហើយ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសភស្តុតាងដែលជាប់ទាក់ទងខ្លាំងបំផុត នៅក្នុងពេលសវនាការ និងបានពិចារណាឃើញថា ការស្តាប់ចម្លើយសាក្សីបន្ថែមដែលបានស្នើសុំដោយក្រុមមេធាវីការពារក្តី នួន ជា មិនត្រូវបានអនុញ្ញាតឡើយ[63]។ ហេតុដូច្នេះ អង្គជំនុំជម្រះបដិសេធសំណើសុំរបស់ក្រុម

---

[62] *ជាឧទាហរណ៍ សូមមើល* បញ្ជីសាក្សីបន្ថែមទាក់ទងនឹងបរិបទប្រវត្តិសាស្ត្រ ឯកសារ E155/1 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២។ បញ្ជីសាក្សីបន្ថែមទាក់ទងនឹងបរិបទប្រវត្តិសាស្ត្រ ក្រុមមេធាវីការពារក្តី នួន ជា ឯកសារ E155/1.1 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២។

[63] សូមមើល សំណើសុំស្តាប់ចម្លើយសាក្សីរបស់មេធាវីការពារក្តី និងចាត់ឱ្យមានវិធានការដទៃទៀតខាងនីតិវិធី ដើម្បីវាយតម្លៃឱ្យបានត្រឹមត្រូវលើបរិបទប្រវត្តិសាស្ត្រ ឯកសារ E182 ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១" ឯកសារ E172 ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២ ទំព័រ ៤ ("អង្គជំនុំជម្រះកត់សម្គាល់ការដាក់សំណើនាពេលថ្មីៗដោយក្រុមមេធាវីការពារក្តី នួន ជា ស្តីពីបញ្ជីសាក្សីបន្ថែមទាក់ទងនឹងបរិបទប្រវត្តិសាស្ត្រ (E155/1.1) ដែលពួកគេបានស្នើសុំស្តាប់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ នូវសាក្សីចំនួន ៤៧ នាក់ បន្ថែមទៀត ទាក់ទងនឹងដំណាក់កាលសវនាការទៅលើបរិបទប្រវត្តិសាស្ត្រ)។ សាក្សីទាំងនេះត្រូវបានពិចារណាដោយអង្គជំនុំជម្រះ នៅក្នុងការរៀបចំបញ្ជីបណ្តោះអាសន្នរបស់ខ្លួនស្តីពីសាក្សី ឯកសារ E131/1.1 និងការដាក់សំណើសុំរបស់ក្រុមមេធាវីការពារក្តី នួន ជា កាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ ថា ខកខានមិនបានបង្ហាញថា

មេធាវីការពារក្ដី នួន ជា ដើម្បីស្ដាប់សក្ខីកម្មបុគ្គលដូចខាងក្រោម ដែលមេធាវីការពារក្ដីបានកំណត់ថា ចាំបាច់ត្រូវស្ដាប់ចម្លើយនៅក្នុងសំណុំរឿង ០០២/០១ ដោយសារតែមិនមានការពាក់ព័ន្ធ ឬច្រំដែល (វិធាន ៨៧(៣)(ក) នៃវិធានផ្ទៃក្នុង)៖

| | |
|---|---|
| សាក្សី TCW-១២២ | Avram Noam CHOMSKY |
| សាក្សី TCW-៤៤៦ | Stephen John MORRIS |
| សាក្សី TCW-៥៧២ | Donald RUMSFELD |
| អ្នកជំនាញ TCE-១០ | Nayan CHANDA |
| សាក្សី TCW-៦៥៦ | Frank Warren SNEPP |
| សាក្សី TCW-២២០ | ហែម សាមិន |
| សាក្សី TCW-២២២ | ហេង សំរិន |
| សាក្សី TCW-២៦៦ | អ៊ិន ស៊ីរុធ |
| សាក្សី TCW-៣០៥ | Penelope KEY |
| សាក្សី TCW-៣១១ | ខាង សារិន |
| សាក្សី TCW-៣៧១ | Melvin LAIRD |
| សាក្សី TCW-៤៣០ | ម៉ែន ចាន់ |
| សាក្សី TCW-៤៤២ | W. Stanley MOONEYHAM |
| សាក្សី TCW-៤៧៧ | Robert H. NOOTER |
| សាក្សី TCW-៥៥៩ | Phillipe RICHER |
| សាក្សី TCW-៦២៥ | James Rodney SCHLESINGER |

---

ហេតុអ្វីបានជាសាក្សីទាំង ៤៧ នាក់នេះ គួរតែត្រូវបានស្ដាប់សក្ខីកម្មជាបន្ទាន់នោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះបដិសេធសំណើសុំស្ដាប់សក្ខីកម្មសាក្សីទាំងនេះនាពេលនេះ។ អង្គជំនុំជម្រះបានណែនាំដល់ភាគីទាំងអស់បន្ថែមថា សាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលបានស្នើសុំទាំងអស់ដែលមាននៅក្នុងបញ្ជីស្នើសុំរបស់ភាគី (មានចំនួនសរុប ១.០៥៤ នាក់) គឺស្ថិតនៅក្រោមការពិចារណារបស់អង្គជំនុំជម្រះនៅឡើយ វៀរលែង និងលុះត្រាតែសាក្សីទាំងនោះអាចត្រូវបានកោះហៅឱ្យមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ឬត្រូវបានបដិសេធ ទៅតាមករណីដែលអាចកើតមានឡើង”)។

សាក្សី TCW-៧៤ Timothy CARNEY
សាក្សី TCW-៧៦៨ VO Dong Giang
សាក្សី TCW-៧៦៩ VO Nguyen Giap
សាក្សី TCW-៧៩១ យស់ ប៉ោ ។

33. អង្គជំនុំជម្រះបានកត់សម្គាល់បន្ថែមទៀតថា បុគ្គលជាច្រើនដែលមានឈ្មោះខាងលើហាក់មិនមានការដឹងឮដោយផ្ទាល់អំពីព្រឹត្តិការណ៍នានានៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលនៃការចោទប្រកាន់នោះទេ ហេតុដូច្នេះ អង្គជំនុំជម្រះបដិសេធទៀត យោងទៅលើភាពពាក់ព័ន្ធនេះ។ គួរបញ្ជាក់ផងដែរថា ចំនួនបុគ្គលដែលពិតជាបានផ្តល់សក្ខីកម្មនៅក្នុងសវនាការ បានផ្តល់ភស្តុតាងទាក់ទងនឹងស្ថានភាពដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាមុនឆ្នាំ ១៩៧៥ និងព្រឹត្តិការណ៍ដទៃទៀតរហូតដល់អំឡុងពេលនៃរបបខ្មែរក្រហម រួមទាំងផលប៉ះពាល់ពីការទម្លាក់គ្រាប់បែករបស់អាមេរិកក្នុងឆ្នាំ ១៩៧២ ផង[64]។

34. ទោះជាបដិសេធមិនស្តាប់សក្ខីកម្ម TCE-១០ ទាក់ទងនឹងព្រឹត្តិការណ៍មុនឆ្នាំ ១៩៧៥ ក៏ដោយ ក៏អង្គជំនុំជម្រះទទួលស្គាល់ថាសក្ខីកម្មរបស់គាត់អាចមានភាពពាក់ព័ន្ធ ចំពោះបញ្ហាអត្ថិភាពនៃជម្លោះប្រដាប់អាវុធ នៅក្នុងអំឡុងពេលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[65]។ ហេតុដូច្នេះ អង្គជំនុំជម្រះបានពន្យារការផ្តល់ភស្តុតាងរបស់គាត់ដែលទាក់ទងនឹងចំណុចនេះ ទៅសវនាការនាពេលក្រោយក្នុងសំណុំរឿង ០០២ ។

### ៣.២.២ បុគ្គលទាំងឡាយដែលត្រូវបានស្តាប់សក្ខីកម្មក្នុងអំឡុងពេលសវនាការទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនង រចនាសម្ព័ន្ធយោធា និងតួនាទីរបស់ជនជាប់ចោទ

35. បន្ថែមទៅលើភស្តុតាងទូទៅរបស់អ្នកជំនាញមួយចំនួន និងបុគ្គលដទៃទៀត ទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មបុគ្គលចំនួន ៣៥ នាក់ ដែល

---

[64] បន្ថែមទៅលើបុគ្គលទាំងឡាយដែលត្រូវបានកំណត់ខាងលើ *ជាអាទិ៍ សូមមើល* ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ ទំព័រ ៧៥ (ឈូក រីន)។

[65] កាំង *ហ្គេកអ៊ាវ ហៅ ឌុច* សាលក្រម សំណុំរឿង ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ ឯកសារ E188 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ពីកថាខណ្ឌ ៦៦ ដល់ ៦៨ និងកថាខណ្ឌ ៧០។

ត្រូវបានកំណត់យ៉ាងជាក់លាក់ថាមានការពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនង និងរចនាសម្ព័ន្ធយោធានៅក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យនៅលើចំណុចទាំងនេះផងដែរ[66]។ បុគ្គលដូចខាងក្រោមនេះ ត្រូវបានផ្តល់សក្ខីកម្មទូទៅលើផ្នែកទាំងនោះ៖

| | |
|---|---|
| អ្នកជំនាញ TCE-១១ | David CHANDLER |
| អ្នកជំនាញ TCE-៦៥ | Philip SHORT |
| សាក្សី TCW-២៨១ | កាំង ហ្កេកអ៊ាវ *ហៅ* ឌុច |

36. នៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះក៏បានបញ្ជាក់ផងដែរថា បុគ្គលដូចមានរាយឈ្មោះខាងក្រោមដែលនឹងត្រូវស្តាប់ចម្លើយនៅក្នុងសវនាការ ត្រូវបានកំណត់ដោយសារតែការដឹងឮរបស់ពួកគេចំពោះចំណុចខាងក្រោមដែលទាក់ទងនឹងអង្គហេតុ ក្នុងសំណុំរឿង ០០២/០១[67] ។ ទោះជាយ៉ាងណាក៏ដោយ គួរបញ្ជាក់ផងដែរថា ក្នុងចំណោមបុគ្គលទាំងនេះ មានបុគ្គលជាច្រើនបានផ្តល់សក្ខីកម្មនៅក្នុងសវនាការ ទាក់ទងនឹងចំណុចជាច្រើនដែលមានការពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១៖

### ៣.២.២.១ ប្រព័ន្ធទំនាក់ទំនង

| | |
|---|---|
| សាក្សី TCW-៤៨០ | នង សុផង់ |
| សាក្សី TCW-៦៩៥ | សួន កានិល |
| សាក្សី TCW-៣០៧ | ខាំ ផាន់ |

---

[66] *សូមមើល* ឧបសម្ព័ន្ធ I *ផ្នែកទី* iv *និង* v។ *សូមមើលផងដែរ* បញ្ជីចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១" ឯកសារ E172 ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១២។

[67] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១" ឯកសារ E172 ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១២។

### ៣.២.២.២ រថនាសម្ព័ន្ធរដ្ឋបាល រួមទាំង ក្រសួងនានា

សាក្សី TCW-៦២០ ស វី

សាក្សី TCW-៦១៧ សូត្រ ទៀង

សាក្សី TCW-៥០៤ ពាន ឃាន

សាក្សី TCW-៤៨៨ អឿន តាន

### ៣.២.២.៣ ក្រសួងនានា (មន្ទីរ ប-១ ក្រសួងការបរទេស)

សាក្សី TCW-៦៩៤ សួង ស៊ីគឿន

សាក្សី TCW-៥៨៦ សាឡុត បាន

សាក្សី TCW-៣២៣ ខឹម ងន

សាក្សី TCW-៤៨៧ នី កន

សាក្សី TCW-៥៦៤ រ៉ចាម តុន

### ៣.២.២.៤ មន្ទីរ ប-១ (បឹងត្របែក)

សាក្សី TCW-៤៩០ អុង ថុងហឿង

### ៣.២.២.៥ ក្រសួងឃោសនាការ/ការអប់រំនយោបាយដោយជនជាប់ចោទ

សាក្សី TCW-៤៧៥ នឹម សែម

សាក្សី TCW-៦០៩ ស សៀក

សាក្សី TCW-៣២០ ខៀវ អេន

សាក្សី TCW-៣៣៨ គឹម វុន

សាក្សី TCW-៩១ ជា សាយ

ដើមបណ្តឹងរដ្ឋប្បវេណី TCCP-២៨ ឯម អឿន

37. បន្ថែមលើនេះទៀត អង្គជំនុំជម្រះបានកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ស សារិន (TCCP-១៨៦) ដែលបានឆ្លើយនឹងសំណួរមួយចំនួនមុននឹងបញ្ជាក់ថា គាត់នឹងមិនផ្តល់សក្ខីកម្ម

បន្ថែមទៀតទេ លុះណាតែគាត់ត្រូវបានផ្តល់វិធានការការពារជាក់លាក់ ដូចជាការផ្តល់មន្ត្រីនគរបាលបួនរូប ដើម្បីការពារគាត់អស់មួយជីវិត[68]។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះត្រូវបានជូនដំណឹងមុនពេលឲ្យគាត់ចាកចេញទៅវិញថា ដោយសារតែសំណើរបស់គាត់មានភាពយឺតយ៉ាវ អង្គជំនុំជម្រះមិនមានមធ្យោបាយអនុវត្តជាក់ស្តែងចាំបាច់ ដើម្បីផ្តល់ការការពារដូចដែលគាត់បានស្នើសុំនោះទេ[69]។ សហព្រះរាជអាជ្ញាបានដាក់សំណើសុំឲ្យកោះហៅ ស សារិន ឡើងវិញ និងសុំឲ្យមានការវាយតម្លៃបន្ថែមទៅលើតម្រូវការវិធានការការពារ ដែលត្រូវបានបដិសេធដោយក្រុមមេធាវីការពារក្តី ខៀវ សំផន[70]។ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញរួចមក អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា វិធានការការពារនឹងមិនត្រូវបានផ្តល់ជូនឡើយ[71]។ ដោយកត់សម្គាល់ឃើញថា នៅក្នុងក្របខ័ណ្ឌច្បាប់នៃ អ.វ.ត.ក ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចត្រូវបានបង្ខំឲ្យផ្តល់ភ័ស្តុតាងបានទេ ហើយលោក ស សារិន ក៏បានបដិសេធមិនព្រមផ្តល់សក្ខីកម្ម បើមិនមានវិធានការការពារទេ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការកោះហៅលោក ស សារិន ឡើងវិញ ទំនងជាមិនផ្តល់ផលប្រយោជន៍ដល់ការស្វែងរកការពិត ឬ មិនមានផលប្រយោជន៍យុត្តិធម៌ឡើយ[72]។

---

[68] ប្រតិចារិក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ ទំព័រ ៤១ ដល់ ៤២ និងទំព័រ ៥៤។

[69] ប្រតិចារិក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ ទំព័រ ៦៤ ។

[70] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស សារិន សាជាថ្មី និងបង្គាប់ឲ្យមានការវាយតម្លៃជាផ្លូវការមួយពីតម្រូវការចាំបាច់សម្រាប់វិធានការការពារ ឯកសារ E286 ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣។ ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស សារិន សាជាថ្មី និង បង្គាប់ឲ្យមានការវាយតម្លៃជាផ្លូវការមួយពីតម្រូវការចាំបាច់សម្រាប់វិធានការការពារ ឯកសារ E286/1 ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣។

[71] ការវាយតម្លៃពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ - WESU Assessment 09-VU-00883 ឯកសារ E29/460 ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣។

[72] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សេចក្តីសម្រេចលើសំណើសុំវិធានការការពារទាំងអស់ក្នុងសំណុំរឿង ០០២/០១ និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស សារិន សាជាថ្មី និងបង្គាប់ឲ្យមានការវាយតម្លៃជាផ្លូវការមួយពីតម្រូវការចាំបាច់សម្រាប់វិធានការការពារ(E286), ឯកសារ E293 ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣ ពីកថាខណ្ឌ ១០ ដល់ ១៣។

38. សហព្រះរាជអាជ្ញា បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញ ទៅលើសេចក្តីសម្រេចរបស់ខ្លួនមិនកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស សារិន សាជាថ្មីនោះ[73]។ នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ក្រោយពីការស្តាប់សារណាផ្ទាល់មាត់របស់ភាគី និងការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ឈ្មោះ ស សារិន ដែលមានវត្តមាននៅក្នុងបន្ទប់សវនាការ បានឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ ។ ផ្ទុយទៅនឹងការអះអាងដែលលើកឡើងដោយមេធាវីតំណាងឱ្យរូបគាត់ លោក ស សារិន មិនបានត្រៀមខ្លួនផ្តល់សក្ខីកម្មទេ ប្រសិនបើមិនផ្តល់វិធាន-ការការពារដែលរូបគាត់បានស្នើសុំពីមុន បន្ថែមលើសំណើសុំផ្សេងទៀត។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបដិសេធសំណើសុំរបស់ ក.ស.ព ដោយយល់ឃើញថា បើទោះបីជាសំណើសុំនេះត្រូវបានចាត់ទុកថា ជាសំណើសុំថ្មីក៏ដោយ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាមិនបានលើកឡើងពីកាលៈ-ទេសៈថ្មីៗនោះទេ ហើយអង្គជំនុំជម្រះសាលាដំបូងក៏យល់ឃើញថា សំណើសុំនេះក៏មិនស្របតាមបទប្បញ្ញត្តិក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុងនោះឡើយ[74]។

39. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា វិធានផ្ទៃក្នុងមិនបានអនុញ្ញាតឱ្យមានការពិចារណាឡើងវិញទៅលើសេចក្តីសម្រេចនានារបស់ខ្លួនឡើយ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមិនទទួលយកសំណើសុំទាំងឡាយ ទាក់ទងនឹងបញ្ហាដែលអង្គជំនុំជម្រះបានសម្រេចរួចហើយនោះទេ។ ប៉ុន្តែ ភាគីអាចប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចណាមួយនៅក្នុងពេលវេលាសមស្របណាមួយបាន ឬ ដាក់សំណើសុំជាថ្មីនៅចំពោះមុខអង្គជំនុំជម្រះ នៅពេលណាមានកាលៈទេសៈថ្មីកើតឡើង[75]។ សហព្រះរាជអាជ្ញាមិនបានលើកឡើងថា នេះជាសំណើសុំថ្មីនោះទេ។ ទោះជាយ៉ាង

---

[73] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យមានកាពិចារណាឡើងវិញ លើសេចក្តីសម្រេចទាក់ទងនឹងការបដិសេធលើសំណើសុំឱ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស សារិន សាជាថ្មី ឯកសារ E293/1 ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៣ ។

[74] ប្រតិចារឹក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៦៧។

[75] សេចក្តីសម្រេចរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួនដែលថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងសំណើសុំបន្ថែម ឯកសារ E238/11/1 ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ៧។ សូមមើលផងដែរ សាលដីកាលើសំណុំរឿងរបស់ កាំង *ហ្កេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ត.ក ឯកសារ F28 ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៤៩១។

ណាក៏ដោយ អង្គជំនុំជម្រះបានបញ្ជាក់នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនពីមុនថា ដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចត្រូវបានបង្ខំឲ្យផ្ដល់ភស្ដុតាង និងសូមរំលឹកឡើងវិញថា ដោយសារតែឋានៈពិសេសរបស់ខ្លួន ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីគឺជាការស្ម័គ្រចិត្ត[76]។ បន្ថែមលើនេះទៅទៀត នៅក្នុងកាលៈទេសៈបែបនេះ វាមិនមែនជាការសមស្របទេក្នុងការចាត់វិធានការចំពោះការជ្រៀតជ្រែកដោយចេតនាពិតប្រាកដមកលើតុលាការនោះ។

### ៣.២.២.៦ ក្រសួងពាណិជ្ជកម្ម

សាក្សី TCW-៥៨៣ សគីម ល្មុត
សាក្សី TCW-៣២១ ខៀវ នៅ

### ៣.២.២.៧ រចនាសម្ព័ន្ធរដ្ឋបាល (ថ្នាក់ជាតិ)

សាក្សី TCW-៦០៤ សៅ សារុន
សាក្សី TCW-៧៩៧ យុន គីម

### ៣.២.២.៨ រចនាសម្ព័ន្ធយោធា

40. នៅថ្ងៃក្រោយមកទៀត អង្គជំនុំជម្រះក៏បានកំណត់កាលបរិច្ឆេទស្ដាប់សក្ខីកម្មរបស់បុគ្គល ៣ នាក់ ដូចខាងក្រោមដែលត្រូវបានដាក់ឈ្មោះទៅក្នុងបញ្ជីរបស់ខ្លួន ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ទាក់ទងទៅនឹងរចនាសម្ព័ន្ធយោធា៖

សាក្សី TCW-១១០ ឈូក រីន
សាក្សី TCW-៤២៨ មាស វឿន

---

76 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "សេចក្ដីសម្រេចលើសំណើសុំវិធានការការពារទាំងអស់ក្នុងសំណុំរឿង ០០២/០១ និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ ស សារិន សាជាថ្មី និងបង្គាប់ឲ្យមានការវាយតម្លៃជាផ្លូវការមួយពីតម្រូវការចាំបាច់សម្រាប់វិធានការការពារ(E286) ឯកសារ E293 ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ១៣។ វិធាន ២៣(៤) នៃវិធានផ្ទៃក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១២ មាត្រា ៣២៦ និងមាត្រា ៣៣៥។

សាក្សី TCW-១២៦ ជួន ធី

41. ជាដំបូងនេះផងដែរ ទាក់ទងនឹងរចនាសម្ព័ន្ធយោធាក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ អង្គជំនុំជម្រះបានស្ដាប់សក្ខីកម្មរបស់បុគ្គល ២ នាក់ បន្ថែមទៀត ដែលសក្ខីកម្មរបស់អ្នកទាំងនោះត្រូវបានស្នើសុំដោយសហព្រះរាជអាជ្ញានៅក្នុងពេល ឬ ក្រោយពេលកិច្ចប្រជុំរៀបចំសវនាការលើកទីពីរភ្លាមៗ[77]៖

សាក្សី TCW-១០០ ឆោម សែ

សាក្សី TCW-៧៥៤ អ៊ុង រ៉ែន

### ៣.២.២.៩ បុគ្គលមួយចំនួនបន្ថែមទៀត ដែលបានផ្ដល់សក្ខីកម្មនៅក្នុងដំណាក់កាលចុងក្រោយនៃការជំនុំជម្រះដែលស្នើសុំដោយភាគី

42. បន្ទាប់ពីការពិនិត្យឡើងវិញទៅលើភ័ស្តុតាងដែលបានស្ដាប់រហូតមកទល់នឹងថ្ងៃនេះ និងសំណើសុំរបស់ភាគីទាំងអស់ អង្គជំនុំជម្រះបានស្ដាប់ចម្លើយបុគ្គលមួយចំនួនបន្ថែមទៀតដូចមានឈ្មោះខាងក្រោម ទាក់ទងនឹងលក្ខណៈនៃរចនាសម្ព័ន្ធរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទនៅក្នុងដំណាក់កាលចុងក្រោយនៃការជំនុំជម្រះនេះ[78]៖

អ្នកជំនាញ TCE-៣៣ Stephen HEDER

សាក្សី TCW-១៦៤ ឯក ហេន

សាក្សី TCW-៦៤៨ ស៊ឹម ហារ

សាក្សី TCW-៥៤៨ ព្រុំ ស្វី

សាក្សី TCW-៥៧០ រស់ ស៊ុយ

---

[77] បុគ្គលនានាដែលភាគីបានស្នើសុំឲ្យមកផ្ដល់សក្ខីកម្មនៅក្នុងសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាមៗ ឯកសារ E236 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ផ្នែកទី ៣។

[78] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "ការជូនដំណឹងអំពីសវនាការអំពីការនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ E288 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ ពីកថាខណ្ឌ ៤ ដល់ ៦។

សាក្សី TCW-៣៨៤ ឡេង ឈឿង

43. អ្នកជំនាញ TCE-៣៣ សាក្សី TCW-៦៤៨ និងសាក្សី TCW- ១៦៤ ត្រូវបានស្នើសុំដោយសហព្រះរាជអាជ្ញានៅក្នុងកិច្ចប្រជុំរៀបចំសវនាការលើកទីពីរ និង/ឬនៅដំណាក់កាលបញ្ចប់នៃការជំនុំជម្រះឱ្យបន្ថែមទៅលើបញ្ជីនៃបុគ្គលនានាដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសវនាការ[79] ។ បើទោះបីជាមានការបដិសេធឋានៈជាអ្នកជំនាញក៏ដោយ ក៏អ្នកជំនាញ TCE-៣៣ បានផ្តល់សក្ខីកម្មក្នុងឋានៈជាសាក្សីលើអង្គហេតុដែរ[80]។ សក្ខីកម្មរបស់សាក្សី TCW-៥៤៨ ដែលស្នើឱ្យដកចេញដោយអង្គជំនុំជម្រះ នៅមុនកិច្ចប្រជុំរៀបចំសវនាការលើកទីពីរ ត្រូវបានរក្សាទុកវិញទៅតាមសំណើសុំរបស់សហព្រះរាជអាជ្ញា[81]។

44. សាក្សី TCW-៥៧០ និងសាក្សី TCW-៣៨៤ ត្រូវបានកំណត់អត្តសញ្ញាណដោយក្រុមមេធាវីការពារក្តី ខៀវ សំផន នៅក្នុងកិច្ចប្រជុំរៀបចំសវនាការលើកទីពីរថា ចាំបាច់ត្រូវស្តាប់

---

[79] បុគ្គលនានាដែលភាគីបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាមៗ ឯកសារ E236 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ផ្នែកទី ៣។ ឧបសម្ព័ន្ធ កៈ កាលវិភាគសវនាការដែលស្នើឡើងដោយសហព្រះរាជអាជ្ញាសម្រាប់សវនាការដំណាក់កាលចុងក្រោយលើសំណុំរឿង ០០២ ឯកសារ E273.1 ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣។

[80] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "ការជូនដំណឹងអំពីសវនាការអំពីការនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣" ឯកសារ E288 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ៤។ លោក Heder បានផ្តល់សក្ខីកម្មចាប់ពីថ្ងៃទី ០៩ ដល់ ១១ និងពីថ្ងៃទី ១៥ ដល់ ១៨ ខែ កក្កដា ឆ្នាំ ២០១៣។ គាត់ត្រូវបានកោះហៅដើម្បីឱ្យមកបកស្រាយជាចម្បងទៅលើឯកសារសំខាន់ៗមួយចំនួនដែលមាននៅក្នុងសំណុំរឿង ០០២ ដែលគាត់បាននិពន្ធ។ *សូមមើលផងដែរ* ប្រតិចារឹកចុះថ្ងៃទី ២៣ ដល់ ២៥ ខែ មករា ឆ្នាំ ២០១២ (វ៉ាន់ថាន់ ពៅដារា) និងប្រតិចារឹកចុះថ្ងៃទី០១ ថ្ងៃទី០២ និងថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ (យុ ឆាង) ដែលត្រូវបានកោះហៅទាក់ទងនឹងការទទួលយកឯកសារដែលមានប្រភពពីមជ្ឈមណ្ឌលឯកសារកម្ពុជា។

[81] បុគ្គលនានាដែលភាគីបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម ឯកសារ E236 ចុះថ្ងៃទី ០២ ខែតុលា ឆ្នាំ២០១២ ផ្នែកទី១។ ឧបសម្ព័ន្ធកៈ កាលវិភាគសវនាការស្នើឡើងដោយសហព្រះរាជអាជ្ញាសម្រាប់សវនាការដំណាក់កាលចុងក្រោយលើសំណុំរឿង ០០២ ឯកសារ E273.1 ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣។

ចម្លើយ ដើម្បីជំទាស់តវ៉ាទៅនឹងការចោទប្រកាន់នានាមកលើជនជាប់ចោទ[82]។ អង្គជំនុំជម្រះក៏បាន ពិចារណាផងដែរថា បុគ្គលទាំងនេះទំនងជាអាចផ្តល់ភ័ស្តុតាងពាក់ព័ន្ធ និងមានតម្លៃ ហើយសវនា-ការស្តាប់សក្ខីកម្មពួកគាត់អាចនាំឱ្យឆ្ពោះទៅរកការពិត ទាក់ទងនឹងការចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១។ អ្នកទាំងនេះបានផ្តល់ភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះកាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣។

### ៣.២.៣ បុគ្គលនានាដែលមិនអាចកោះហៅ ឬត្រូវបានយល់ថាមិនចាំបាច់ស្តាប់សក្ខីកម្ម ទាក់ទងនឹងរចនាសម្ព័ន្ធផ្សេងៗក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ឬតួនាទីរបស់ជនជាប់ចោទ

45. តាមពិតទៅ ភ័ស្តុតាងភាគច្រើនដែលត្រូវបានស្នើឡើងដោយអង្គជំនុំជម្រះ ឬ ដែលត្រូវបាន កំណត់ឡើងដោយភាគីថា មានសារៈសំខាន់ក្នុងការស្តាប់សក្ខីកម្មទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនង និងរចនាសម្ព័ន្ធយោធាក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ ជនជាប់ចោទ ត្រូវបានផ្តល់ចម្លើយនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងអំឡុងពេលសវនាការលើសំណុំ រឿង ០០២/០១ រួចហើយ។ ប៉ុន្តែ បុគ្គលមួយចំនួនតូចដែលអង្គជំនុំជម្រះបានកំណត់ទាក់ទងនឹង ចំណុចទាំងនេះ មិនអាចមកផ្តល់សក្ខីកម្មនៅក្នុងសវនាការបានទេ។ បុគ្គលមួយចំនួនក៏ត្រូវបាន យល់ថា មិនចាំបាច់ស្តាប់សក្ខីកម្មដែរ ដោយសារចំនួនភ័ស្តុតាងជាច្រើនមាននៅចំពោះមុខអង្គជំនុំ-ជម្រះរួចហើយ ឬលែងមានការពាក់ព័ន្ធទៅនឹងអង្គហេតុនៅក្នុងសំណុំរឿង ០០២/០១ ក្រោយពី មានការបំបែកជនជាប់ចោទទាំងពីរ ពីកិច្ចដំណើរការនីតិវិធីរួចមក។ ទាក់ទងនឹងបុគ្គល ២ នាក់ អង្គជំនុំជម្រះក៏មិនអាចមានការឯកភាពគ្នាអំពីភាពពាក់ព័ន្ធរបស់ពួកគេទៅនឹងអង្គហេតុក្នុងសំណុំ រឿង០០២/០១ នោះដែរ។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចស្តាប់ចម្លើយទៅលើភ័ស្តុតាងរបស់ពួក គេបានឡើយ។

---

[82] បុគ្គលនានាដែលភាគីបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់ របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬ ក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាមៗ ឯកសារ E236 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ផ្នែកទី ៥។

### ៣.២.៣.១ ប្រព័ន្ធទំនាក់ទំនង

46. បុគ្គល ៥ នាក់ មានឈ្មោះដូចខាងក្រោម ដែលអង្គជំនុំជម្រះបានកំណត់ថា អាចមានភាពពាក់ព័ន្ធទៅនឹងប្រព័ន្ធទំនាក់ទំនងនោះ ទីបំផុតមិនត្រូវបានកោះហៅឱ្យមកផ្តល់ភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ ឡើយ៖

សាក្សី TCW-៧៨០ យ៉េង លីន
សាក្សី TCW-៦៤៥ សៀង សេង
សាក្សី TCW-៦៧៩ សុវណ្ណ ហាន
សាក្សី TCW-៣២៦ ឃុន គីម ហៅ នួន ប៉ែត
សាក្សី TCW-៣៩៨ ឡុញ ដុស

47. នៅក្នុងកិច្ចប្រជុំរៀបចំសវនាការលើកទីពីរ អង្គជំនុំជម្រះបានលើកឡើងថា សាក្សី TCW-៧៨០ និងសាក្សី TCW-៦៤៥ គួរតែត្រូវបានដកចេញដោយសារមូលហេតុថា សក្ខីកម្មរបស់ពួកគេទំនងជាច្រំដែលជាមួយភ័ស្តុតាងដទៃទៀត ដែលបានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។ ដោយសារតែការស្នើសុំឱ្យដកសាក្សីទាំងពីរនាក់នេះ មិនត្រូវបានភាគីណាមួយជំទាស់នៅក្នុងកិច្ចប្រជុំរៀបចំសវនាការលើកទីពីរ ឬក៏កិច្ចប្រជុំក្រោយៗមកទៀត អង្គជំនុំជម្រះបានបដិសេធមិនស្តាប់ភ័ស្តុតាងរបស់ពួកគេនៅក្នុងសំណុំរឿង ០០២/០១ ទេ[83]។ ក្នុងការកែសម្រួលបញ្ជីរបស់ខ្លួនចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ បន្ថែមទៀត នៅពេលសវនាការដែលដំណើរការទៅមុខនោះ អង្គជំនុំជម្រះក៏បានសម្រេចថា សក្ខីកម្មរបស់សាក្សី TCW-៦៧៩ និងសាក្សី TCW-៣២៦ នៅចំពោះមុខអង្គជំនុំជម្រះ មានភាពច្រំដែល និង/ឬ មានភាពពាក់ព័ន្ធយ៉ាងច្រើនទៅនឹងសវនាការនាពេល

---

[83] បុគ្គលនានាដែលភាគីបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម ឯកសារ E236 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ផ្នែកទី ១ ឧសម្ព័ន្ធទី II ផ្នែកទី viii (ខ)។

ក្រោយ ឬចំពោះជនជាប់ចោទដែលត្រូវបានផ្តាច់ចេញពីសំណុំរឿង ០០២/០១ ហេតុដូច្នេះ អង្គជំនុំជម្រះក៏បានបដិសេធមិនស្តាប់សក្ខីកម្មរបស់ពួកគេនៅក្នុងសំណុំរឿង ០០២/០១ នោះដែរ[84]។

48. ចុងក្រោយបំផុត និងបន្ទាប់ពីមានការខិតខំប្រឹងប្រែងដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការស្វែងរកសាក្សី TCW-៣៩៨ អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានរាយការណ៍ថា សាក្សី TCW-៣៩៨ មិនអាចមកផ្តល់សក្ខីកម្មបានទេ ដោយសារតែមូលហេតុសុខភាព[85]។ នៅពេលដែលមានការលើកឡើងថា បុគ្គលណាម្នាក់ស្លាប់ ឬ មិនអាចមកផ្តល់សក្ខីកម្មបានដោយសារតែមានជំងឺ អង្គជំនុំជម្រះបានស្នើសុំឱ្យផ្តល់ព័ត៌មានតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីបញ្ជាក់ថា បុគ្គលនោះពិតជាមិនមានសមត្ថភាពមែន ឬ ដើម្បីទទួលបានលិខិតបញ្ជាក់មរណភាព។ នៅពេលណាដែលអាចធ្វើទៅបាន សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ ត្រូវបានប្រើប្រាស់ជាជម្រើស ជំនួសឱ្យការបដិសេធមិនស្តាប់សក្ខីកម្មរបស់សាក្សីដែលមានវ័យចាស់ ឬ សាក្សីដែលមានសុខភាពទ្រុឌទ្រោម[86]។

---

[84] សាក្សីចុងក្រោយ ដែលជាជនជាប់ឃុំឃាំង ក៏ត្រូវបានបញ្ជាក់ថាមានបញ្ហាសុខភាព និងបានបដិសេធការកោះហៅឱ្យចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ លិខិតរបស់ [TCW-326] ផ្ញើជូន អ.វ.ត.ក ឯកសារ E269 ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៣។ សូមមើលផងដែរ ឧសម្ព័ន្ធទី II ផ្នែកទី xi និងផ្នែកទី viii (ក)។

[85] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "សាក្សី TCW-398 លោក ឡុញ ដុស សម្បទាក្នុងការធ្វើដំណើរមកកាន់ អ.វ.ត.ក" ឯកសារ E172/29/1 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២។ អនុស្សរណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលមានចំណងជើងថា៖ "សាក្សី TCW-398 លោក ឡុញ ដុស សម្បទាក្នុងការធ្វើដំណើរមកកាន់ អ.វ.ត.ក" ឯកសារ E172/29/1.1 ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ (លើកឡើងថា មានការទាក់ទងជាច្រើនលើកច្រើនសាជាមួយសាក្សីរូបនេះ ខណៈដែលត្រូវបានសម្រេចថា សាក្សីរូបនេះទទួលរងការឈឺចាប់ពីបញ្ហាក្រលៀន និងតម្រូវឱ្យមានការបំបែកគ្រាប់ឈាម។ គាត់ក៏តម្រូវឱ្យមានការអនុញ្ញាតពីមេបញ្ជាការយោធារបស់គាត់ដើម្បីមកផ្តល់សក្ខីកម្មផងដែរ)។

[86] *ឧទាហរណ៍ សូមមើល* អនុស្សរណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលមានចំណងជើងថា៖ "TCW-៦០៤" ឯកសារ E141.1 ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ (បញ្ជាក់ពីការរាយការណ៍របស់ប្រធានភូមិថា សាក្សី TCW-៦០៤ បានទទួលមរណភាពហើយ)។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យមានកិច្ចស៊ើបសួរពាក់ព័ន្ធនឹងការស្លាប់របស់សាក្សី (E144)" ឯកសារ E144/1 ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១១ (បង្គាប់ឱ្យមានកិច្ចស៊ើបសួរទៅលើការស្លាប់របស់សាក្សី TCW-៦០៤)។ អនុស្សរណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដែលមានចំណងជើងថា៖ "ចម្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង- E144/1" ឯកសារ E144/1/1 ចុះថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១២ (បញ្ជាក់ថា សាក្សី TCW-៦០៤ មានវ័យ

### ៣.២.៣.២ រចនាសម្ព័ន្ធរដ្ឋបាល (ថ្នាក់មជ្ឈិម)

49. នៅមុនកិច្ចប្រជុំរៀបចំសវនាការលើកទីពីរ អង្គជំនុំជម្រះបានស្នើសុំមិនស្តាប់ចម្លើយពីបុគ្គល ២ នាក់ ដែលត្រូវបានកំណត់ពីដំបូងថាមិនមានការពាក់ព័ន្ធទៅនឹងសវនាការផ្នែកនេះ[87]។ សំណើសុំនេះមិនត្រូវបានភាគីណាមួយជំទាស់នៅក្នុងកិច្ចប្រជុំរៀបចំសវនាការលើកទីពីរ ឬ នៅពេលក្រោយមកទៀតនោះទេ[88]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានបដិសេធមិនស្តាប់សក្ខីកម្មរបស់សាក្សី ២ នាក់ ដោយយោងទៅលើមូលហេតុថា ភ័ស្តុតាងរបស់ពួកគេទំនងជាមានភាពច្រំដែលទៅនឹងសក្ខីកម្មដែលបានស្តាប់នៅចំពោះមុខអង្គជំនុំជម្រះរួចមកហើយ៖

សាក្សី TCW-៦៣៨ សេង លីថេង

សាក្សី TCW-៣៥៤ គង់ យឿង

---

ចាស់ជរា ប៉ុន្តែនៅមានជីវិតនៅឡើយ)។ ទីបំផុត សាក្សី TCW-៦០៤ ត្រូវបានស្តាប់ចម្លើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ប្រតិចារិក ចុះថ្ងៃទី ០៥ ទី ៦ ទី ៧ ទី ១១ ( ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១២។ *សូមមើលផងដែរ* ប្រតិចារិក ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១១ ពីទំព័រ ១ ដល់ ២ (ដែលសម្រេចថា សាក្សី TCW-៣៩៥ គួរតែត្រូវបានស្តាប់ចម្លើយតាមរយៈប្រព័ន្ធសោតទស្សន៍ ដោយសារតែស្ថានភាពសុខភាពរបស់គាត់)។ ប្រតិចារិក ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ ពីទំព័រ ៦៨ ដល់ ៧១ (យល់ព្រមតាមសំណើសុំដែលថា ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១ គួរតែត្រូវបានស្តាប់ចម្លើយតាមរយៈប្រព័ន្ធសោតទស្សន៍)។ សំណើសុំឱ្យបំពាក់ប្រព័ន្ធសោទស្សន៍សម្រាប់សាក្សី TCW-៦២៤ (Sydney SCHANBERG) និងសំណើសុំឱ្យទទួលយកកំណត់ត្រាប្រចាំថ្ងៃរបស់សាក្សី ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ឯកសារ E236/1/4/3 ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣។

[87] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ដែលអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ឯកសារ E172 ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ ២។

[88] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា ៖ "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមទៀតដែលរៀបចំឡើង ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ" ឯកសារ E218 ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១២ កថាខណ្ឌ ៥ ។ បុគ្គលនានាដែលភាគីបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសវនាការដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬ ក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាមៗ ឯកសារ E236 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ផ្នែកទី១។ *សូមមើលផងដែរ* ឧសម្ព័ន្ធទី II ផ្នែកទី viii (ខ)។

### ៣.២.៣.២.១ មន្ទីរ ប-១ (ក្រសួងការបរទេស)

50. អង្គជំនុំជម្រះសាលាដំបូង ក៏បានបដិសេធមិនស្តាប់សក្ខីកម្មរបស់បុគ្គលដែលមានឈ្មោះខាងក្រោម ដែលអង្គជំនុំជម្រះបានកំណត់នៅក្នុងបញ្ជីចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ថាមានការពាក់ព័ន្ធនឹងក្រសួងការបរទេស៖

សាក្សី TCW-៧២៤ ជួន ប្រសិទ្ធ

សាក្សី TCW-៧៩៦ យង់ យ៉ែម

ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៧៨ Laurence PICQ

51. ដោយសារតែអង្គជំនុំជម្រះសាលាដំបូង បានស្តាប់ភ័ស្តុតាងជាច្រើនពាក់ព័ន្ធទៅនឹងក្រសួងការបរទេស (សូមមើលបញ្ជីឈ្មោះបុគ្គលនានាដែលបានស្តាប់ចម្លើយនៅក្នុងចំណុច ៣.២.២.៣) អង្គជំនុំជម្រះយល់ឃើញថា វាមិនចាំបាច់ក្នុងការកោះហៅសាក្សីបន្ថែមដែលភ័ស្តុតាងរបស់សាក្សីទាំងនោះ អាចមានភាពច្រំដែលទៅលើទិដ្ឋភាពជាច្រើន ឬ ផ្ទុយទៅវិញ មានភាពពាក់ព័ន្ធខ្លាំងទៅនឹងជនជាប់ចោទ អៀង សារី (ដែលក្រោយមកបានទទួលមរណភាព)។ ហេតុដូច្នេះ អង្គជំនុំជម្រះបានសម្រេចថា មិនចាំបាច់កោះហៅសាក្សី TCW-៧២៤ និងសាក្សី TCW-៧៩៦ ដើម្បីឱ្យមកផ្តល់ភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ នោះទេ[89] ។ ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៧៨ ដែលរស់នៅប្រទេសបារាំង និងជាអតីតភរិយារបស់សាក្សី TCW-៦៩៤ បានបដិសេធមិនសហការជាមួយ អង្គជំនុំជម្រះ ហើយក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី គាត់មិនអាចត្រូវបានបង្ខំឱ្យផ្តល់ភ័ស្តុតាងនៅក្នុងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក បានទេ[90]។ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះក៏ត្រូវបានវិនិច្ឆ័យផងដែរថា ទំនងជាមានភាពច្រំដែលយ៉ាងខ្លាំងទៅនឹងសក្ខីកម្មដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះ។

### ៣.២.៣.២.២ មន្ទីរ ប-១ (បឹងត្របែក)

---

[89] ឧសម្ព័ន្ធទី II ផ្នែកទី xi។

[90] វិធាន ២៣(៤) នៃវិធានផ្ទៃក្នុង។

01004703



52. នៅទីបំផុត បុគ្គលដែលមានឈ្មោះដូចខាងក្រោមនេះ មិនត្រូវបានស្តាប់ចម្លើយទាក់ទងនឹងដំណាក់កាលសវនាការនេះទេ ដោយហេតុថា មិនអាចរកឃើញទីតាំងដែលពួកគេរស់នៅបាន ដែលពាក់ព័ន្ធជាខ្លាំងទៅនឹងជនជាប់ចោទដែលត្រូវបានបំបែកចេញពីកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ ឬដោយសារសំណើសុំដកឈ្មោះពួកគេចេញពីបញ្ជី មិនត្រូវបានភាគីណាមួយជំទាស់នៅក្នុងកិច្ចប្រជុំរៀបចំសវនាការឡើយ[91]៖

សាក្សី TCW-៧០៧ តាន់ វ៉ាដឺនី
សាក្សី TCW-៧៩៤ អ៊ី ផាន់ដារ៉ា
សាក្សី TCW-២៣៤ ហ៊ីង អ៊ុន

### ៣.២.៣.២.៣ ក្រសួងឃោសនាការ និងការអប់រំនយោបាយដោយជនជាប់ចោទ

53. ទាក់ទងនឹងបុគ្គលនានាដែលត្រូវបានកំណត់ថា មានការពាក់ព័ន្ធនឹងការអប់រំនយោបាយដែលត្រូវបានចោទថា បានធ្វើឡើងដោយជនជាប់ចោទ និងក្រោយពីបានស្តាប់សក្ខីកម្មរបស់បុគ្គល ៧ នាក់ ពាក់ព័ន្ធនឹងចំណុចនេះ នៅចំណុច ៣.២.២.៥ អង្គជំនុំជម្រះបានបដិសេធមិនស្តាប់

[91] ឧសម្ព័ន្ធទី II ផ្នែកទី xii(ឃ) ផ្នែកទី xi និង viii(ខ)។ *សូមមើលផងដែរ* បុគ្គលនានាដែលភាគីបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬ ក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម ឯកសារ E236 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ផ្នែកទី ១ (ទាក់ទងនឹងសាក្សី TCW-២៣៤)។ អនុស្សរណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដែលមានចំណងជើងថា៖ "សាក្សីដែលរស់នៅប្រទេសបារាំង" ឯកសារ E205ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១២ (ទាក់ទងនឹងសាក្សី TCW-៧០៧, សាក្សី TCW-៧៩៤ និងសាក្សី TCW-២៣៤)។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ" ឯកសារ E218 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ៥ (ដែលស្នើសុំឱ្យដកចេញសាក្សី TCW-៧០៧ សាក្សី និងសាក្សី TCW-២៣៤)។ សេចក្តីជូនដំណឹងស្តីពីគោលជំហររបស់សហព្រះរាជអាជ្ញាលើបញ្ហាសំខាន់ៗដែលនឹងត្រូវពិភាក្សាក្នុងកិច្ចប្រជុំរៀបចំសវនាការ នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ (ដោយមានឧបសម្ព័ន្ធសម្ងាត់ (ក)) ឯកសារ E218/2 ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ (ការយល់ស្របឱ្យដកចេញសាក្សី TCW-២៣៤ ហើយសាក្សី TCW-៧០៧ និងសាក្សី TCW-៧៩៤ ត្រូវលើកទៅពេលក្រោយ)។

សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-៩៤ (នូ សារ៉េម) ទេ[92]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំដដែលៗឱ្យស្តាប់សក្ខីកម្មរបស់គាត់នៅក្នុងសវនាការ ដោយសារតែសារៈសំខាន់របស់គាត់ក្នុងនាមជាតំណាងឱ្យសមាគមខ្មែរ-អាមេរិកកាំង[93]។

54. នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ អង្គជំនុំជម្រះបានលើកពេលស្តាប់សក្ខីកម្មរបស់គាត់ ដោយសារតែមូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងទៀត គឺការមិនមានប្រតិចារឹកនៃបទសម្ភាសន៍តាមវិទ្យុសម្លេងសហរដ្ឋអាមេរិក ដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ជូន[94]។ ទីបំផុត អង្គជំនុំជម្រះយល់ឃើញថា មិនចាំបាច់ស្តាប់ចម្លើយរបស់គាត់នៅក្នុងសវនាការនោះទេ ដោយសារតែភ័ស្តុតាងជាច្រើនត្រូវបានផ្តល់ជូននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ទាក់ទងនឹងសវនាការវគ្គនេះ និងដោយសារថា ដើមបណ្តឹងរដ្ឋប្បវេណីមិនមានវត្តមាននៅក្នុងទីក្រុងភ្នំពេញទេ នៅពេលមានការជម្លៀសប្រជាជនដោយបង្ខំនោះ។ បើទោះបីជាមានការទទួលស្គាល់ពីសារៈសំខាន់របស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-៩៤ ថា តំណាងឱ្យជនរងគ្រោះនៃសមាគមខ្មែរ-អាមេរិកកាំង ក៏ដោយ ក៏អង្គជំនុំជម្រះកត់សម្គាល់ឃើញថាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មិនត្រូវបានសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជ្រើសរើសជាបុគ្គលម្នាក់ចាំបាច់ ដើម្បីស្តាប់សក្ខីកម្មពាក់ព័ន្ធនឹងព្យសនកម្មដែលជនរងគ្រោះបានទទួលនោះទេ[95]។ ហេតុដូច្នេះ អង្គជំនុំជម្រះបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន មិនស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះនៅក្នុងសវនាការដើម្បីជាផលប្រយោជន៍ក្នុងការសន្សំសំចៃថវិការបស់តុលាការ។

---

[92] ឧបសម្ព័ន្ធទី II ផ្នែកទី viii(ក)។

[93] ប្រតិចារិកសវនាការ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ ពីទំព័រ ១៦ ដល់ទំព័រ ១៩។

[94] ប្រតិចារិកសវនាការ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ២៩។

[95] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "ការជូនដំណឹងអំពីសវនាការដែលនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភ័ស្តុតាងនៅក្នុងសំណុំរឿង០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣" ឯកសារ E288 ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៣ ឧបសម្ព័ន្ធ ក៖ កាលបរិច្ឆេទសវនាការដែលបានស្នើដោយ ក.ស.ព សម្រាប់សវនាការដំណាក់កាលចុងក្រោយលើសំណុំរឿង ០០២ ឯកសារ E273.1 ចុះថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០១៣។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ I ផ្នែកទី x។

### ៣.២.៣.៣ រចនាសម្ព័ន្ធរដ្ឋបាល (ថ្នាក់ជាតិ)

55. ក្រោយពីបានស្តាប់សក្ខីកម្មរបស់បុគ្គល ២ នាក់ ជាពិសេស ទាក់ទងនឹងសវនាការវគ្គនេះ និងទោះបីជាមានសំណើមុនៗសុំឱ្យរក្សាទុកសាក្សីរូបនេះនៅក្នុងបញ្ជីចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ របស់អង្គជំនុំជម្រះក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា វាមិនចាំបាច់ត្រូវស្តាប់សក្ខីកម្មពីបុគ្គលដែលមានឈ្មោះខាងក្រោមនេះទេ ដោយសារតែមូលហេតុសន្សំសំចៃថវិការបស់តុលាការ[96]។

ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៤២ សេង សឿន

### ៣.២.៣.៤ បុគ្គលដទៃទៀតដែលមានឈ្មោះនៅក្នុងបញ្ជីចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ដែលមិនទាន់បានស្តាប់សក្ខីកម្មនៅក្នុងសវនាការនៅឡើយ

56. អង្គជំនុំជម្រះសាលាដំបូងមិនអាចស្តាប់សក្ខីកម្មរបស់បុគ្គលមួយចំនួនតូចបន្ថែមទៀតដែលអង្គជំនុំជម្រះយល់ឃើញថាមានការពាក់ព័ន្ធនឹងវគ្គសវនាការមុនៗក្នុងសំណុំរឿង ០០២/០១ ក្នុងនោះមាន៖

សាក្សី TCW-២៨៥ កង សូផាត

សាក្សី TCW-៦៧៦ [កោសលុប]

សាក្សី TCW-៤២៥ [កោសលុប]

សាក្សី TCW-២៩៧ កែ ពេជ្រវណ្ណៈ

សាក្សី TCW-៦០១ សៅ ផេន

---

[96] *សូមមើល* បុគ្គលនានាដែលភាគីបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម ឯកសារ E236 ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១២ ផ្នែកទី១ (ការជំទាស់ទៅនឹងសំណើរបស់អង្គជំនុំជម្រះដែលសុំឱ្យដកចេញដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៤២)។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៤២ មិនត្រូវបានកំណត់ដោយសហព្រះរាជអាជ្ញា ទោះជានៅក្នុងបញ្ជី ចុះខែមីនា ឆ្នាំ ២០១៣ ក្តី ឬនៅក្នុងកិច្ចប្រជុំរៀបចំសវនាការចុងក្រោយក្តី ថាចាំបាច់ត្រូវស្តាប់សក្ខីកម្មមុនពេលបិទសវនាការទៅលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ នោះទេ។ សូមមើល៖ ឧបសម្ព័ន្ធ ក៖ កាលបរិច្ឆេទសវនាការដែលបានស្នើសុំដោយ ក.ស.ព សម្រាប់ដំណាក់កាលចុងក្រោយនៃសវនាការលើសំណុំរឿង ០០២ ឯកសារ E273.1 ចុះថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០១៣។ ការជូនដំណឹងរបស់សហព្រះរាជអាជ្ញាក្នុងការឆ្លើយតបទៅនឹងសំណើរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ សុំឱ្យផ្តល់ព័ត៌មាន មុនកិច្ចប្រជុំរៀបចំសវនាការ ឯកសារ E288/3 ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣។

01004706



សាក្សី TCW-៤៨២ នរោត្តម សីហនុ

57. អង្គជំនុំជម្រះមិនអាចស្តាប់សក្ខីកម្មរបស់សាក្សី TCW-៤២៥ បាននោះទេ ដោយសារតែការការពារប្រឆាំងនឹងការដាក់ពិរុទ្ធភាពលើខ្លួនឯង ដែលមានចែងក្នុងវិធាន ២៤(៤) នៃវិធានផ្ទៃ-ក្នុង[97]។ នៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១២ សម្តេច សីហនុ ទ្រង់សោយទីវង្គត នាំឱ្យសំណើទាំងអស់ដែលសុំឱ្យស្តាប់សក្ខីកម្មរបស់ព្រះអង្គនៅក្នុងសវនាការ និងសារណាផ្សេងៗទៀត លែងមានសារៈសំខាន់ទៀតហើយ[98]។ សាក្សី TCW-២៨៥ និងសាក្សី TCW-៦៧៦ ក៏បានទទួលមរណភាពដែរ ចំណែកឯសាក្សី TCW-៦០១ មិនអាចមកផ្តល់សក្ខីកម្មបានទេ ដោយសារមូលហេតុមានជំងឺ[99]។

---

[97] *សូមមើល* ឧបសម្ព័ន្ធ II ផ្នែកទី xii(ច)។ *សូមមើលផងដែរ* ការជូនដំណឹង និងការលះបង់សិទ្ធិ ការជូនដំណឹងរបស់សាក្សី TCW-៤២៥" អំពីគោលបំណងក្នុងការអនុវត្តសិទ្ធិរក្សាការស្ងៀមស្ងាត់មិនឆ្លើយតប និងការលះបង់សិទ្ធិចំពោះទំនាស់ផលប្រយោជន៍ចម្បងៗ ឯកសារ E236/2/4/1.2 ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣។ វិធាន២៤(៤) នៃវិធានផ្ទៃក្នុងចែងថា៖ "សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះមិនត្រូវកោះហៅក្នុងនាមជាសាក្សីទេ ចំពោះបុគ្គលណាដែលមានភស្តុតាងបង្ហាញថា មានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តបទឧក្រិដ្ឋ លើកលែងតែបទប្បញ្ញត្តិដែលមានចែងក្នុងអនុវិធាន ២៨"នៃវិធានផ្ទៃ) ។ សូមមើល បុគ្គលនានាដែលភាគីបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសវនាការដែលភាគីបានទាក់ទងទៅកាន់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬ ក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម ឯកសារ E236 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ផ្នែកទី ៥។

[98] *សូមមើលឧទាហរណ៍* សារណាស្តីពីរបៀបស្តាប់ចម្លើយសាក្សី ព្រះបាទ នរោត្តម សីហនុ ឯកសារ E93/9/1 ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១។ ញត្តិរបស់លោក អៀង សារី សុំឃាង និងកោះអញ្ជើញសម្តេចព្រះវររាជបិតា នរោត្តម សីហនុ, សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន, ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ, និងសម្តេច ជា ស៊ីម ឯកសារ E85, ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១១។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះញត្តិរបស់ អៀង សារី ក្នុងការកោះហៅព្រះបាទ នរោត្តម សីហនុ ឯកសារ E93/9/1 ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១។ ញត្តិរបស់លោក អៀង សារី សុំឃាង និងកោះអញ្ជើញសម្តេចព្រះវររាជបិតា នរោត្តម សីហនុ, សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន, ព្រះអង្គម្ចាស់ នរោត្តមរណឫទ្ធិ, និងសម្តេចជា ស៊ីម ឯកសារ E85/4 ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១១។

[99] ឧបសម្ព័ន្ធ II ផ្នែកទី xii(ក) និង (ខ)។ *សូមមើលផងដែរ* អនុស្សរណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលមានចំណងជើងថា៖ "មរណភាពរបស់សាក្សី TCW-២៨៥" ឯកសារ E140/2 ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២។ អនុស្សរណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលមានចំណងជើងថា៖ "ចម្លើយតបពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំឱ្យមានការវាយតម្លៃផ្នែកវេជ្ជសាស្ត្រដោយឯករាជ្យទៅលើសម្បទារបស់សាក្សី TCW-៦០១ ដើម្បីមកផ្តល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក" ឯកសារ E172/23 ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១២។

58. បន្ថែមលើនេះ អង្គជំនុំជម្រះបានសម្រេចលើកពេល ឬបដិសេធមិនស្តាប់សក្ខីកម្មរបស់អ្នកជំនាញមួយចំនួនដែលត្រូវបានដាក់បញ្ចូលតាំងពីដំបូង ទៅក្នុងបញ្ជីចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ របស់ខ្លួន ដោយយោងទៅលើមូលហេតុដែលថា សក្ខីកម្មទាំងនោះអាចមានភាពច្រំដែលយ៉ាងខ្លាំងទៅនឹងសក្ខីកម្មរបស់អ្នកជំនាញដែលបានផ្តល់រួចហើយ និង/ឬ អាចមានភាពពាក់ព័ន្ធយ៉ាងច្រើនទៅនឹងសវនាការនាពេលខាងមុខក្នុងសំណុំរឿង ០០២[100]៖

អ្នកជំនាញ TCE-២៧ Anne Yvonne GUILLOU

អ្នកជំនាញ TCE-៨០ Elizabeth BECKER

អ្នកជំនាញ TCE-៨១ Henri LOCARD

59. អ្នកជំនាញដទៃទៀតដែលអង្គជំនុំជម្រះបានស្នើសុំ បានបដិសេធការតែងតាំងឱ្យមានឋានៈជាអ្នកជំនាញក្នុងសំណុំរឿង ០០២/០១ ហេតុដូច្នេះ មិនអាចមកផ្តល់សក្ខីកម្មនៅក្នុងសវនាការបានទេ[101]៖

---

[100] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ដែលអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មក្នុងសំណុំរឿង០០២/០១" ឯកសារ E172 ចុះថ្ងៃទី២១ ខែ កុម្ភៈ ឆ្នាំ២០១២ ។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "សវនាការនៅថ្ងៃទី១៧ ខែ តុលា ឆ្នាំ ២០១២" ឯកសារ E172/25 ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២។ សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ ឯកសារ E215 ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២។ ដោយយោងទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះកោះអញ្ជើញអ្នកជំនាញមួយចំនួនដោយមានកម្រិតឱ្យមកផ្តល់សក្ខីកម្ម ហេតុដូច្នេះ ការជំទាស់ទៅនឹងការស្តាប់សក្ខីកម្មរបស់អ្នកជំនាញមួយចំនួនអាចចោទជាបញ្ហា (*ជាឧទាហរណ៍សូមមើល* ការជំទាស់ជាបឋមរបស់លោក អៀង សារី ចំពោះសំណើសុំអ្នកជំនាញរបស់ ក.ស.ព និងសំណើសុំការអនុញ្ញាតដាក់សារណាបន្ថែមទៀតក្នុងរយៈពេល ៣០ ថ្ងៃ ឯកសារ E9/4/9 ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១)។

[101] *សូមមើល* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "សក្ខីកម្មរបស់ Benedict KIERNAN ដែលភាគីបានស្នើសុំនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ឯកសារ E166/1/4 ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០១២ (ដោយការលើកឡើងថា នៅពេលដែលមានការខិតខំប្រឹងប្រែងរួមគ្នារវាងទាំងអង្គជំនុំជម្រះ និងស្ថាប័ននានានៃសហរដ្ឋអាមេរិកដែលគាំទ្រ អ.វ.ត.ក ដើម្បីទទួលបានសក្ខីកម្មរបស់គាត់ តាមតថភាពពិត អ.វ.ត.ក មានមធ្យោបាយអនុវត្តជាក់ស្តែងតិចតួចណាស់ដើម្បីបង្ខំឱ្យមានវត្តមានរបស់អ្នកជំនាញដែលមិនសហការនោះ។ ដោយការខិតខំប្រឹងប្រែងគ្រប់មធ្យោបាយប្រកបដោយហេតុផលដើម្បីទទួលបានសក្ខីកម្មពីសាស្ត្រាចារ្យ KIERNAN និងដោយ

អ្នកជំនាញ TCE-៤៤ អៀ ម៉េងទ្រី

អ្នកជំនាញ TCE-៣៨ Benedict KIERNAN

### ៣.២.៤ បុគ្គលដែលត្រូវបានស្នើសុំទាក់ទងនឹងការជម្លៀសប្រជាជន

60. ទាក់ទងនឹងការជម្លៀសប្រជាជននៅដំណាក់កាលទី១ និងដំណាក់កាលទី២ អង្គជំនុំជម្រះបានកំណត់ពីបញ្ជីរាយឈ្មោះនូវបុគ្គលជាអាទិភាពចំនួន ៥៣ នាក់ ដែលភាគីទាំងអស់បានស្នើសុំឱ្យស្តាប់សក្ខីកម្មរបស់ពួកគាត់ទាក់ទងទៅនឹងដំណាក់កាលនានានៃសវនាការនេះ។ អង្គជំនុំជម្រះយល់ឃើញថា បុគ្គលចំនួន២៥ នាក់ ទំនងជាមានការពាក់ព័ន្ធបំផុតត្រូវស្តាប់សក្ខីកម្មនៅក្នុងសវនាការ។ អង្គជំនុំជម្រះបានផ្តល់បញ្ជីសាក្សីបម្រុងចំនួន ១១ នាក់ ក្នុងករណីដែលបុគ្គលមានចំនួនដ៏ច្រើននេះ មិនអាចមកផ្តល់សក្ខីកម្មបាន[102]។ បុគ្គលចំនួន ២១ នាក់ ខាងក្រោមដែលយកចេញពីបញ្ជីក្រោយៗនេះ ត្រូវបានស្តាប់សក្ខីកម្មនៅក្នុងសវនាការរួចមកហើយ[103]៖

---

យោងទៅលើភាពស្មាក់ស្មើររបស់អ្នកជំនាញដែលបានស្នើសុំឱ្យជួយដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិត ដូច្នេះអង្គជំនុំជម្រះបានសម្រេចមិនស្តាប់សក្ខីកម្មរបស់គាត់នៅក្នុងសំណុំរឿង ០០២/០១ នេះទេ)។

[102] បុគ្គលនានាដែលភាគីបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬ ក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម ឯកសារ E236 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ផ្នែកទី ៤ [ដោយកំណត់អត្តសញ្ញាណបុគ្គល ២១ នាក់ ដែលបានស្នើសុំដោយភាគី (២១ នាក់ ស្នើសុំដោយសហព្រះរាជអាជ្ញា, ៣៧ នាក់ ស្នើសុំដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង ២១ នាក់ ផ្សេងទៀតស្ថិតនៅក្នុងបញ្ជីបំពេញបន្ថែម) និង ១៦ នាក់ ស្នើសុំដោយក្រុមមេធាវីការពារក្តីលោក នួន ជា] ដើម្បីស្តាប់សក្ខីកម្មទាក់ទងនឹងការជម្លៀសប្រជាជននៅដំណាក់កាលទីមួយ និងដំណាក់កាលទីពីរ។ *សូមមើលផងដែរ* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "ការបញ្ជាក់ជាបឋមអំពីបុគ្គលដែលអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មក្នុងអំឡុងសវនាការលើចំណុចអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងសំណុំរឿង ០០២/០១" ឯកសារ E236/1 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ឧបសម្ព័ន្ធ II ផ្នែកទី vi ។

[103] សាក្សី TCW-៥៦៥ [Al ROCKOFF] គឺជាករណីលើកលែងតែមួយគត់ ដែលត្រូវបានកំណត់ដោយអង្គជំនុំជម្រះថាទំនងជាមានការពាក់ព័ន្ធតិចតួចក្នុងការផ្តល់សក្ខីកម្មនៅក្នុងសវនាការ។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា៖ "ការបញ្ជាក់ ជាបឋមអំពីបុគ្គលដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្ម ក្នុងអំឡុងសវនាការលើចំណុចអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន ក្នុងសំណុំរឿង ០០២/០១" ឯកសារ E236/1 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ៦។ ដោយយោងទៅលើការលះបង់សិទ្ធិដោយផ្តល់ដោយក្រុមមេធាវីការពារក្តីលោក អៀង សារី ក្នុងការស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះ ដោយមិនមានវត្តមានរបស់ជនជាប់ចោទ ហើយដោយសារ

ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-១៦៩ យឹម សុវណ្ណ

ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-២៥ ជុំ សុខា

ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-៦៤ ឡាយ បូនី

សាក្សី TCW-៦៦១ សុខ ឈិន

សាក្សី TCW-៣៦២ គង់ គីម

សាក្សី TCW-៦៩០ ស៊ុំ ជា

សាក្សី TCW-៨៩ ម៉ុម សំអឿន

សាក្សី TCW-៥០៧ ប៉េជុយ ជីបសែ

ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-៨២ មាស សារ៉ាន់

ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-១០៥ អោ រី

ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-១៨៧ ចៅ នី

ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-១៨៨ ទឹង សុខា

ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-១០៨ ពេជ ស្រីផល

ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-៥៩ គីម វ៉ាន់ឌី

សាក្សី TCW-២៤៧ ហ៊ុន ឈុនលី

ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-១ AFFONCO Denise

សាក្សី TCW-៥៦៥ Al ROCKOFF

ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-១១៦ ពិន យ៉ាថៃ

សាក្សី TCW-៥៣៦ Francois PONCHAUD

សាក្សី TCW-២៥៣ អៀង ផាន

សាក្សី TCW-៦២៤ Sydney Hillel SCHANBERG

---

សាក្សីរូបនេះត្រូវបានស្នើសុំដោយសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្ដីរបស់លោក នួន ជា សាក្សីរូបនេះ បានផ្ដល់សក្ខីកម្មពីថ្ងៃទី ២៨ ដល់ ២៩ ខែ មករា ឆ្នាំ ២០១៣ នៅពេលដែលជនជាប់ចោទ នួន ជា អវត្តមាននៅក្នុងកិច្ចដំណើរការនីតិវិធី និងមិនអាចចូលរួមក្នុងសវនាការបានដោយសារតែមូលហេតុសុខភាព។ ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ ពីទំព័រ ១ ដល់ ២ និងប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ ទំព័រ ១។

61. ក្នុងការឆ្លើយតបទៅនឹងសំណើចុងក្រោយរបស់ភាគី អង្គជំនុំជម្រះក៏បានកោះហៅបុគ្គលមួយចំនួនបន្ថែមទៀតទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំ[104]៖

សាក្សី TCW-៨០១ នូ ម៉ៅ ហៅ មោក

សាក្សី TCW-៥០៥ ពេជ្រ ជឹម

សាក្សី TCW-៣៨៦ ឡេីវ ឡាំ

62. ចំពោះបុគ្គលដែលនៅសល់ក្នុងបញ្ជីឈ្មោះបុគ្គលនានារបស់អង្គជំនុំជម្រះ ដែលត្រូវបានចាត់ទុកតាំងពីដំបូងថា មានការពាក់ព័ន្ធបំផុតដែលត្រូវស្តាប់សក្ខីកម្មទាក់ទងនឹងការជម្លៀសប្រជាជននោះ អង្គជំនុំជម្រះមិនអាចស្តាប់សក្ខីកម្មបុគ្គលដែលមានឈ្មោះខាងក្រោមនេះបានទេ៖

សាក្សី TCW-២៨៥ កង សូផាត

ដើមបណ្តឹងរដ្ឋប្បវេណី TCCP-៣៥៦ កុយ ម៉ុន

សាក្សី TCW-១៦១ Jean DYRAC

សាក្សី TCW- ៧០១ Jon SWAIN

ដើមបណ្តឹងរដ្ឋប្បវេណី TCCP- ៤៥ គៀង វណ្ណារី

63. បន្ទាប់ពីមានបំណងកោះហៅសាក្សី TCW-២៨៥ និងដើមបណ្តឹងរដ្ឋប្បវេណី TCCP-៣៥៦ អង្គជំនុំជម្រះបានទទួលដំណឹងថា អ្នកទាំងពីរនេះបានទទួលមរណភាពទៅហើយ[105]។

---

[104] *ជាឧទាហរណ៍ សូមមើល* ឧបសម្ព័ន្ធ ក៖ កាលបរិច្ឆេទសវនាការដែលបានស្នើសុំដោយ ក.ស.ព សម្រាប់ដំណាក់កាលចុងក្រោយនៃសវនាការលើសំណុំរឿង ០០២ ឯកសារ E273.1 ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣។ ការជូនដំណឹងរបស់សហព្រះរាជអាជ្ញាក្នុងការឆ្លើយតបទៅនឹងសំណើរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ សុំឱ្យផ្តល់ព័ត៌មានមុនកិច្ចប្រជុំរៀបចំសវនាការ ឯកសារ E288/3 ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣។ សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យបើកកិច្ចស៊ើបសួរស្របតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង អំពីកន្លែងស្នាក់នៅរបស់សាក្សី នូ មុក ឯកសារ E266 ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "សំណើរបស់សហព្រះរាជអាជ្ញាស្របតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ទាក់ទងនឹងសាក្សីសក្តានុពល នូ មោក ព្រមទាំង សំណើសុំឱ្យស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះ (E266)" ឯកសារ E266/3 ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣។

[105] ឧបសម្ព័ន្ធ II ផ្នែកទី xii(ក)។ *សូមមើលផងដែរ* អនុស្សរណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលមានចំណងជើងថា៖ "មរណភាពរបស់សាក្សី TCW-២៨៥" ឯកសារ E140/2 ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២។

សាក្សី TCW-១៦១ មិនអាចមកផ្តល់សក្ខីកម្មបានទេ ដោយសារតែមូលហេតុសុខភាព ចំណែកឯសាក្សី TCW-៧០១ មិនត្រូវបានគេដឹងពីទីកន្លែងដែលគាត់ស្នាក់នៅឡើយ[106]។ ដើមបណ្តឹងរដ្ឋប្បវេណី TCCP-៤៥ បានបោះបង់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ហើយក្រោយមក សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដកសំណើសុំស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះ[107]។

64. អង្គជំនុំជម្រះបានសម្រេចថាបុគ្គល ២ នាក់ ខាងក្រោម ដែលត្រូវបានកំណត់អត្តសញ្ញាណពីដំបូងនៅក្នុងបញ្ជីអាទិភាពរបស់ខ្លួនដើម្បីស្តាប់សក្ខីកម្មទាក់ទងនឹងការជម្លៀសប្រជាជននោះ ទំនងជាមានភាពច្រំដែលយ៉ាងខ្លាំងទៅនឹងសក្ខីកម្មដទៃទៀត ដែលត្រូវបានផ្តល់ជូនតុលាការមកទល់នឹងសព្វថ្ងៃនេះ។ ហេតុដូច្នេះ មិនចាំបាច់ស្តាប់សក្ខីកម្មរបស់ពួកគេទេ[108]៖

ដើមបណ្តឹងរដ្ឋប្បវេណី TCCP-៩ ឆេន ប៊ុនឈីញ

---

អនុស្សរណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលមានចំណងជើងថា៖ "មរណភាពរបស់សាក្សី TCW-៣៥៦ ហ៊ិន មុន ហៅ កុយ ម៉ុន" ឯកសារ E236/1/3 ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣។ អនុស្សរណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលមានចំណងជើងថា៖ "សាក្សី TCW-៦០៤៖ លោក សៅ សារុន" ឯកសារ E141.1 ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១។ អនុស្សរណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលមានចំណងជើងថា៖ "សាក្សី TCW-២៩៧៖ លោក កែ ពេជ្រវណ្ណៈ" ឯកសារ E141.2 ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[106] ឧបសម្ព័ន្ធ II ផ្នែកទី xii(ខ)។ អនុស្សរណៈរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលមានចំណងជើងថា៖ "សាក្សី Jean DYRAC (TCW-១៦១)" ឯកសារ E236/2/1 ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២, ឧបសម្ព័ន្ធ II ផ្នែកទី xii(ឃ)។

[107] ឧបសម្ព័ន្ធ II ផ្នែកទី xii(ង)។ *សូមមើលផងដែរ* សំណើរបស់សហព្រះរាជអាជ្ញាស្តីពីសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ ឯកសារ E236/1/2 ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "ការកំណត់កាលបរិច្ឆេទរួមគ្នាស្តាប់សក្ខីកម្មរបស់សាក្សី និងអ្នកជំនាញសម្រាប់ដើមឆ្នាំ ២០១៣" ឯកសារ E236/4 ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៣។ ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត TCCP-២១៣ (ផ្លុង គីមអ៊ិន) ក៏បានបោះបង់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ក្នុងអំឡុងពេលសវនាការ ហើយដែលក្រោយមក សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដកសំណើសុំស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ៖ ឧបសម្ព័ន្ធ II ផ្នែកទី xii(ង)។ ប្រតិចារឹកសវនាការ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១២ ទំព័រ ៧៧។

[108] ឧបសម្ព័ន្ធ II ផ្នែកទី xii(គ)។

ដើមបណ្តឹងរដ្ឋប្បវេណី TCCP-៣៥ ហែម សុវណ្ណ

65. ដោយយោងទៅលើបរិមាណភ័ស្តុតាងដ៏ច្រើន ដែលទទួលបាននៅក្នុងសវនាការ អង្គជំនុំជម្រះ យល់ឃើញថា សក្ខីកម្មរបស់បុគ្គលដែលមានឈ្មោះខាងក្រោមនៅក្នុងបញ្ជីបម្រុងរបស់អង្គជំនុំជម្រះ មិនចាំបាច់ត្រូវស្តាប់ទាក់ទងនឹងការជម្លៀសប្រជាជននោះទេ[109]៖

ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៥០ សូ សារី
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-៥៤ ឃឹម សម្បត្តិ
សាក្សី TCW-៦៤៣ William SHAWCROSS
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-៦២ គង់ ស្រីទូច
សាក្សី TCW-២៥៨ Paul IGNATIEFF
សាក្សី TCW-៦៧៤ សុះ ប៊ុនយ៉ាមីន
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៧០ យិន រំដួល
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១១៧ ប៉ូ ឌីណា[110]

66. ទោះជាយល់ឃើញថាមានភាពច្រំដែលនឹងការជម្លៀសប្រជាជនក៏ដោយ បុគ្គល ២ នាក់ចុងក្រោយនេះ បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះរួចហើយ ទាក់ទងនឹងព្យសនកម្មដែលជនរងគ្រោះបានទទួលរងនោះ[111]។

67. អង្គជំនុំជម្រះក៏បានបដិសេធមិនស្តាប់សក្ខីកម្មបុគ្គលដែលមានឈ្មោះខាងក្រោម ដែលសហព្រះរាជអាជ្ញាបានស្នើសុំឱ្យស្តាប់សក្ខីកម្មនៅក្នុងដំណាក់កាលចុងក្រោយនៃការជំនុំជម្រះ[112]។

---

[109] ឧបសម្ព័ន្ធ II ផ្នែកទី xii(គ)។

[110] ទោះបីជាយ៉ាងណា អង្គជំនុំជម្រះកត់សម្គាល់ថា ក្រោយមក ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៧០ និងដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៧៧ បានផ្តល់សក្ខីកម្មទាក់ទងនឹងផលប៉ះពាល់មកលើជនរងគ្រោះ។

[111] ឧបសម្ព័ន្ធ II ផ្នែកទី x។

[112] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា ឆ្លើយតបទៅនឹងសំណើរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ សុំឱ្យផ្តល់ព័ត៌មាននៅមុនកិច្ចប្រជុំរៀបចំសវនាការ ឯកសារ E288/3 ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣។ *សូមមើលផងដែរ* សម្ព័ន្ធ II ផ្នែកទី vii(ក)។

01004713



សាក្សី TCW-២៦៩ អ៊ិត សែន

68. ទោះបីជាសហព្រះរាជអាជ្ញាបានកំណត់នៅក្នុងកិច្ចប្រជុំរៀបចំសវនាការជាចុងក្រោយថាមានសារៈសំខាន់ក្នុងការស្ដាប់សក្ខីកម្ម មុននឹងបិទសវនាការសួរដេញដោលទៅលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ ក៏ដោយ អង្គជំនុំជម្រះបានយល់ឃើញថា សក្ខីកម្មរបស់សាក្សី TCW-២៦៩ មានការពាក់ព័ន្ធច្រើនទៅនឹងការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ហេតុដូច្នេះ អង្គជំនុំជម្រះបានសម្រេចលើកការស្ដាប់សក្ខីកម្មរបស់គាត់ទៅសវនាការនាពេលខាងមុខ។

69. ទោះបីជាអង្គជំនុំជម្រះបានវាយតម្លៃទៅលើសក្ខីកម្មរបស់សាក្សី TCW-៩២ (ជា ស៊ីម) ថាមានការពាក់ព័ន្ធតិចតួចដែលត្រូវកោះហៅ ទាក់ទងទៅនឹងការជម្លៀសប្រជាជន និង/ឬទំនងជាច្រំដែលទៅនឹងសក្ខីកម្មលើភ័ស្តុតាងក៏ដោយ ក៏ក្រុមមេធាវីការពារក្ដីលោក នួន ជា បានដាក់សារណាបួនដងនៅចំពោះមុខអង្គជំនុំជម្រះ ស្នើសុំឱ្យកោះហៅសាក្សីរូបនេះមកផ្ដល់សក្ខីកម្មទៅលើប្រធានបទដូចតទៅនេះ (១) ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ (២) តួនាទី និងការដឹងឮរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (៣) ក្នុងឋានៈគាត់ជាសាក្សីមួយរូប ក្នុងចំណោមសាក្សីដែលមិនអាចកាត់ផ្ដាច់បានចំពោះរឿងក្ដីរបស់ នួន ជា និងជាពិសេសនៅក្នុងការវាយសម្រុកចូលទីក្រុងភ្នំពេញនៅក្នុងខែ មេសា ឆ្នាំ១៩៧៥ និង (៤) ក្នុងចំណោមបុគ្គលទាំង ១១០ នាក់ ទាក់ទងនឹងការចោទប្រកាន់ថាមានគោលនយោបាយសម្លាប់អតីតមន្ត្រីរបប លន់ នល់[113]។

---

[113] *សូមមើល* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "ការបញ្ជាក់ជាបឋមអំពីបុគ្គលដែលអង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មក្នុងអំឡុងពេលសវនាការលើអង្គហេតុ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅរបស់ប្រជាជនក្នុងសំណុំរឿង ០០២/០១ ឯកសារ E236/1 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌ ៦។ ។ សម្ព័ន្ធ II ផ្នែកទី viii (គ)។ យោង សំណើសុំឱ្យបើកកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឯកសារ E82 ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១១ កថាខណ្ឌ ៣១។ សំណើរួមលើកទីមួយសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម ឯកសារ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ កថាខណ្ឌ ៣(ញ)។ សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម ឯកសារ E93/9 ចុះថ្ងៃទី០៦ ខែ កក្កដា ឆ្នាំ ២០១១ កថាខណ្ឌ ៧។ ឧបសម្ព័ន្ធ៖ សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម ឯកសារ E93/9.1 ពីទំព័រ ក-៦ ដល់ ក-៨។ សំណើសុំឱ្យកោះហៅសាក្សីពាក់ព័ន្ធនឹងការចោទប្រកាន់អំពីគោលនយោបាយនៃការកំណត់មុខសញ្ញាមន្ត្រីរបបសាធារណរដ្ឋខ្មែរ ឯកសារ E291/2 ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ កថាខណ្ឌ២៦។ ឧសបសម្ព័ន្ធ ក៖ សាក្សីនានាដែល ស.ច.ស និងសហព្រះរាជអាជ្ញាចង្អុលបង្ហាញថា ជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីគោល

អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មដែលបានស្មានទុកជាមុនរបស់សាក្សី TCW-៩២ ទៅលើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលត្រូវបានបញ្ជាដោយមជ្ឈិមបក្ស ហើយត្រូវបានបង្ហាញពីដំបូងថា ជាការឆ្លើយបណ្ដោះអាសន្នចំពោះការភ័យខ្លាចថា ទីក្រុងភ្នំពេញអាចត្រូវបានទម្លាក់គ្រាប់ដាក់ដោយយន្តហោះអាមេរិកនោះ មានភាពច្រំដែល យ៉ាងខ្លាំងទៅនឹងភ័ស្តុតាងដែលបានបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះរួចហើយ[114]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានបញ្ជាក់អះអាងទៅលើការវាយតម្លៃពីមុនរបស់ខ្លួន អំពីភាពដែលអាចមានការពាក់ព័ន្ធនៃសក្ខីកម្មរបស់សាក្សី TCW-៩២ នៅក្នុងឯកសារ E236/1 និងបដិសេធមិនកោះហៅសាក្សីរូបនេះនៅក្នុងសំណុំរឿង ០០២/០១។ ហេតុដូច្នេះ សំណើនានារបស់ក្រុមមេធាវីការពារក្ដី នួន ជា សុំឱ្យស្ដាប់សក្ខីកម្មរបស់សាក្សីរូបនេះ ត្រូវច្រានចោល។

### ៣.២.៥ សាក្សីនានាដែលត្រូវបានស្នើសុំឱ្យកោះហៅ ទាក់ទងនឹងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ

70. ទាក់ទងនឹងសវនាការផ្នែកនេះ ដែលត្រូវបានដាក់បន្ថែមទៅក្នុងសំណុំរឿង ០០២/០១ បន្ទាប់ពីមានការអនុញ្ញាតផ្នែកខ្លះរបស់អង្គជំនុំជម្រះទៅលើសំណើសុំរបស់សហព្រះរាជអាជ្ញា ដើម្បីពង្រីកវិសាលភាពសវនាការនេះ អង្គជំនុំជម្រះយល់ស្របជាមួយសហព្រះរាជអាជ្ញាថា មានតែបុគ្គល ២ នាក់ទេដែលត្រូវស្ដាប់សក្ខីកម្ម ដើម្បីគាំទ្រដល់ការចោទប្រកាន់ពាក់ព័ន្ធនឹងអង្គហេតុទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ[115]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានកោះហៅសាក្សី ២ នាក់ ដែលមានឈ្មោះខាងក្រោមឱ្យមកផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១[116]៖

---

នយោបាយនៃការកំណត់មុខសញ្ញាទាហាន និងមន្ត្រីរបប លន់ នល់ ដើម្បីសម្លាប់ចោល ឯកសារ E291/2.1 ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ១។

[114] *ជាឧទាហរណ៍ សូមមើល* កិច្ចសម្ភាសន៍ជាមួយលោក ជា ស៊ីម នៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៨១ និងកិច្ចសម្ភាសន៍ជាមួយលោក ហេង សំរិន នៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៨១ ឯកសារ E3/1568 ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១។

[115] បុគ្គលនានាដែលភាគីបានស្នើសុំឱ្យមកផ្ដល់សក្ខីកម្មនៅក្នុងសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម ឯកសារ E236 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ផ្នែកទី ៦ (ដែលបានកំណត់បុគ្គលចំនួន ៦ នាក់ ថា ចាំបាច់ត្រូវស្ដាប់សក្ខីកម្មដើម្បីគាំទ្រដល់

សាក្សី TCW-៧៥២ អ៊ុង ឆាត់

សាក្សី TCW-៣៨៩ លឹម សាត

71. នៅក្នុងកិច្ចប្រជុំរៀបចំសវនាការលើកទីពីរ បុគ្គលពីរនាក់ផ្សេងទៀតត្រូវបានស្នើសុំឱ្យកោះហៅដោយភាគីដទៃទៀតទាក់ទងនឹងសវនាការផ្នែកនេះ[117]។ អង្គជំនុំជម្រះបានសម្រេចបដិសេធសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើសុំឱ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ២ នាក់ ដែលមានឈ្មោះដូចខាងក្រោម ដែលសហចៅក្រមស៊ើបអង្កេតមិនទាន់បានស្តាប់ចម្លើយនៅឡើយ ដោយសំអាងទៅលើមូលហេតុថា ទំនងជាច្រំដែលទៅនឹងសក្ខីកម្មរបស់សាក្សី TCW-៧៥២ និងសាក្សី TCW-៣៨៩[118]៖

សាក្សីថ្មី D22/2062 ចាន់ ផៃ

សាក្សីថ្មី D22/2076 ទិត ម៉ាន

72. ក្រោយពីបានស្តាប់សក្ខីកម្មរបស់សាក្សី TCW-៧៥២ និងសាក្សី TCW-៣៨៩ រួចមកក្រុមមេធាវីការពារក្តីរបស់ នួន ជា បានស្នើសុំឱ្យស្តាប់សក្ខីកម្មរបស់បុគ្គលប្រាំមួយនាក់ផ្សេងទៀតដើម្បីជំទាស់តវ៉ាទៅនឹងការចោទប្រកាន់ថា ជនជាប់ចោទបានចូលរួមក្នុងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ("បកក") ដែលកំណត់គោលដៅចំពោះអតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ និងដោយយល់ឃើញថា សក្ខីកម្មមានកម្រិត ឬសក្ខីកម្មផ្ទុយគ្នារបស់សាក្សី TCW-៧៥២ និងសាក្សី TCW-៣៨៩ ទាក់ទងនឹងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ នៅខែ មេសា ១៩៧៥[119]៖

---

សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពង្រីកវិសាលភាពសវនាការរហូតដល់ស្រុក ១២ ដែលក្នុងនោះ សាក្សី ៥ នាក់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១ និង សាក្សី ២ នាក់ ពាក់ព័ន្ធនឹងទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ)។

[116] ឧបសម្ព័ន្ធ I ផ្នែកទី vii ។

[117] បុគ្គលនានាដែលភាគីបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬ ក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម ឯកសារ E236 ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ផ្នែកទី ៧។

[118] ឧបសម្ព័ន្ធ II ផ្នែកទី v ។

[119] សំណើបន្ទាន់សុំឱ្យកោះហៅសាក្សីសំខាន់ៗទាក់ទងនឹងទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ឯកសារ E291 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣។

សាក្សី TCW-២២៣ ហេង សំរិន
សាក្សី TCW-៦៤៤ សៀម សឿម
សាក្សី TCW-៦៨៩ ស៊ុម អាឡាត់
សាក្សី TCW-៦៩៩ ស៊ុយ សេងឆន
សាក្សី TCW-៨០៣ ចក់ មួលី
សាក្សី TCW-៨០២ អក ឈឿន

73. អង្គជំនុំជម្រះបានយល់ស្របថា ការកោះហៅសាក្សី TCW-៦៨៩ អតីតទាហាន លន់ នល់ ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនៅសាលាខេត្តពោធិ៍សាត់ មុនការសម្លាប់នៅទួលពោធិ៍ជ្រៃមាន សារៈប្រយោជន៍ចំពោះយុត្តិធម៌ និងទំនងជាអាចជួយដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិត[120]។ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះកាលពីថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣[121]។ ក្រុមមេធាវីការពារក្តីរបស់ នួន ជា លើកឡើងថា សាក្សី TCW-២២៣ បានអះអាងយ៉ាងជាក់ច្បាស់ថា នួន ជា មិនបានបញ្ជាឲ្យសម្លាប់អតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ ហេតុដូច្នេះ ការបដិសេធនេះ គឺជាភ័ស្តុតាងដោះបន្ទុក និងចាំបាច់ត្រូវស្តាប់សក្ខីកម្មនៅក្នុងសវនាការ[122]។ សំអាង-ហេតុដែលធ្វើឲ្យអង្គជំនុំជម្រះមិនអាចកោះហៅសាក្សី TCW-២២៣ ត្រូវបានបកស្រាយខាងក្រោម (ចំណុច ៣.២.៨)។

74. ទាក់ទងទៅនឹងបុគ្គលផ្សេងៗទៀតដែលភាគីបានស្នើសុំឲ្យកោះហៅ ពាក់ព័ន្ធទៅនឹងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃនៅក្នុងដំណាក់កាលសវនាការបិទបញ្ចប់ការជំនុំជម្រះ ក្រុមមេធាវីការពារក្តីរបស់ នួន ជា លើកឡើងថា សាក្សី TCW-៨០៣ ទំនងជាអាចរៀបរាប់អំពីរថយន្តដែលដឹកជញ្ជូនអតីតទាហានរបបសាធារណរដ្ឋខ្មែរដែលស្លៀកពាក់ឯកសណ្ឋានទាហាន និងមាន

---

[120] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុំ អាឡាត់ ឯកសារ D125/48 ចុះថ្ងៃទី ២០ ខែ មករា ឆ្នា ២០០៩។

[121] ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ ២០១៣ ។

[122] សំណើបន្ទាន់សុំឲ្យកោះហៅសាក្សីសំខាន់ៗទាក់ទងនឹងទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ឯកសារ E291 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ពីកថាខណ្ឌ ៣១ ដល់ ៣៣ *ដែលសង្កត់ទៅលើ*កិច្ចសម្ភាសន៍របស់ ជា ស៊ីម នៅភ្នំពេញ កាលពីថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩១ និងកិច្ចសម្ភាសន៍របស់ ហេង សំរិន នៅភ្នំពេញ កាលពីថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩១ ឯកសារ E3/1568 ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ ទំព័រ ២៣។

ពាក់ស័ក្តិសម្គាល់។ ក្រុមមេធាវីការពារក្តីលើកឡើងថា ការមិនមានភ័ស្តុតាងដោយផ្ទាល់ណាមួយបញ្ជាក់ថា គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការសម្លាប់អតីតទាហាននៃរបបសាធា-រណរដ្ឋខ្មែរ ឬ ថាមានការសម្លាប់នៅទួលពោធិ៍ជ្រៃនោះ ចំនួន ឋានន្តរស័ក្តិ និងប្រភពដើមរបស់ជនរងគ្រោះ គឺជាចំណុចសំខាន់ជាគន្លឹះចំពោះការវាយតម្លៃទៅលើការទទួលខុសត្រូវរបស់ នួន ជា[123]។ ក្រុមមេធាវីការពារក្តីបានលើកឡើងថា ភ័ស្តុតាងបង្ហាញថា ប្រសិនបើមានការសម្លាប់នៅទួលពោធិ៍ជ្រៃនៅក្រោយថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥ មែននោះ ជនរងគ្រោះ គឺជាពលទាហានធម្មតា និងមន្ត្រីរដ្ឋការតូចតាច ដែលត្រូវបានកោះហៅដោយគ្មានបញ្ហាឲ្យមកកាន់សាលាខេត្តដោយអាជ្ញាធរមូលដ្ឋាន ហើយថា “សេចក្តីសន្និដ្ឋានតែមួយគត់គឺ អាជ្ញាធរមូលដ្ឋានទាំងនោះបានប្រព្រឹត្តឡើងដោយឯកឯង ដើម្បីសងសឹកគូរប្រជែងរបស់ខ្លួនប៉ុណ្ណោះ”[124]។

75. ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះយល់ឃើញថា មិនចាំបាច់កោះហៅសាក្សី TCW-៨០៣ នេះទេ។ សាក្សីរូបនេះគឺជាអតីតទាហាន លន់ នល់។ ចំណែកឯភ័ស្តុតាងរបស់គាត់ទៀតសោត គឺទំនងជាគ្រាន់តែបញ្ជាក់ទៅលើតែអង្គហេតុដែលថា មានការកាប់សម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃនៅក្រោយការជម្លៀសចេញពីទីក្រុងភ្នំពេញនេះឯង។ ម្យ៉ាងទៀត គាត់ទំនងជាគ្មានអ្វីដែលអាចឆ្លើយបំភ្លឺបានពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទក្នុងព្រឹត្តិការណ៍ទាំងអស់នោះបានឡើយ[125]។ ចំពោះសាក្សី TCW-៨០២ ក្រុមមេធាវីការពារក្តី នួន ជា ទទួលស្គាល់ថា សាក្សីរូបនេះមិនបានចូលរួមក្នុងកិច្ចប្រជុំដែលពាក់ព័ន្ធនៅសាលា ខេត្តពោធិ៍សាត់ ឬមិនបានដឹងថា នរណាជាអ្នកចាត់ចែងកិច្ចប្រជុំនោះ ឬ មិនបានដឹងថា កិច្ចប្រជុំនោះគេនិយាយអំពីអ្វី ឬ មិនបានឃើញគេយកអ្នកចូលរួមប្រជុំណាខ្លះចេញទៅនោះទេ[126]។ អង្គជំនុំជម្រះបានសម្រេចថា សក្ខីកម្មរបស់គាត់ទំនងគ្រាន់តែជាការគូសបញ្ជាក់ទៅលើអង្គហេតុតែប៉ុណ្ណោះ ហេតុដូច្នេះ អង្គជំនុំជម្រះពុំចាំបាច់ស្តាប់សក្ខីកម្ម

---

[123] សំណើបន្ទាន់សុំឲ្យកោះហៅសាក្សីសំខាន់ៗទាក់ទងនឹងទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ឯកសារ E291 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ពីកថាខណ្ឌ ២១ ដល់ ២៥។

[124] សំណើបន្ទាន់សុំឲ្យកោះហៅសាក្សីសំខាន់ៗទាក់ទងនឹងទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ឯកសារ E291 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ២៥។

[125] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចក់ មល្លី, D125/174, ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រទី ២-៤។

[126] សំណើបន្ទាន់សុំកោះហៅសាក្សីសំខាន់ៗពាក់ព័ន្ធទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ, E291, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣, កថាខណ្ឌទី ១៩។

គាត់ក្នុងសវនាការឡើយ[127]។ ចំណែកឯសំណើសុំស្តាប់សក្ខីកម្មរបស់សាក្សី TCW-៦៤៤ ដែលក្នុងព្រឹត្តិការណ៍កាលណោះ គាត់មានអាយុត្រឹមតែ ១៦ ឆ្នាំប៉ុណ្ណោះ ទំនងជាបានដឹងតិចតួចត្រឹមតែការបញ្ជូនមនុស្សទៅទួលពោធិ៍ជ្រៃតែប៉ុណ្ណោះ ហេតុដូច្នេះ ភ័ស្តុតាងនេះគឺច្រំដែលជាមួយនឹងភ័ស្តុតាងដែលអង្គជំនុំជម្រះធ្លាប់បានស្តាប់ពីមុនរួចមកហើយ[128]។

76. ជាចុងក្រោយ ក្រុមមេធាវីការពារក្តី នួន ជា លើកឡើងថា ការកោះហៅសាក្សី TCW-៦៩៩ គឺមានសារៈសំខាន់ខ្លាំង ដោយមូលហេតុថា គាត់បានរៀបរាប់ប្រាប់សហចៅក្រមស៊ើប-អង្កេតថា "មានរថយន្តធំចំនួន ១០០ គ្រឿងបានដឹកជញ្ជូនអតីតមន្ត្រីយោធានៃរបបសាធារណរដ្ឋ-ខ្មែរ អភិបាលខេត្ត និងមន្ត្រីរាជការស៊ីវិល ទៅកាន់ទួលពោធិ៍ជ្រៃ" ដោយប៉ាន់ប្រមាណថាមានមនុស្សប្រហែល ៣០០០ នាក់ត្រូវបានគេសម្លាប់នៅទីនោះ ពោលគឺដោយផ្អែកលើចំនួនរថយន្តធំដែលគាត់បានឃើញ និងព័ត៌មានដែលគាត់ឮពីគេ[129]។ នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៣ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានជម្រាបជូនអង្គជំនុំជម្រះថា សាក្សី TCW-៦៩៩ រូបនេះបានទទួលមរណភាពទៅហើយ[130]។

77. កាលក្នុងកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យស្តាប់សក្ខីកម្មបុគ្គលច្រើនរូបបន្ថែមទៀត ពាក់ព័ន្ធនឹងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ។ សហព្រះរាជអាជ្ញាលើកឡើងថា មនុស្សទាំង ៥ នាក់ ដែលឃើញក្នុងខ្សែអាត់វីដេអូដែលជាភ័ស្តុតាងក្នុងសំណុំរឿង០០២/០១ ពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃនេះ គប្បីស្វែងរកឱ្យឃើញ ដើម្បីយកមកស្តាប់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដ្បិតសហព្រះរាជអាជ្ញាអះអាងថា អ្នកទាំងនេះទំនងជាអាចផ្តល់ភ័ស្តុតាងសំខាន់បំផុត ស្តីពីការចោទប្រកាន់ក្នុងដីកាដំណោះស្រាយពាក់ព័ន្ធនឹងទីតាំង

---

127 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ឆឹម, D232/13, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩។

128 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [TCW-៦៤៤], D125/175, ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩។

129 សំណើបន្ទាន់សុំកោះហៅសាក្សីសំខាន់ៗពាក់ព័ន្ធទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ, E291, ១៧ មិថុនា ឆ្នាំ ២០១៣, កថាខណ្ឌទី ១៧។

130 អនុស្សារណៈរបស់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ដែលមានចំណងជើងថា "សាក្សីដែលបានទទួលមរណភាព TCW-៦៩៩", E292/1/3, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៣; សំបុត្រមរណភាព, E292/1/3.1, ខែ កក្កដា ឆ្នាំ ២០១៣។

បទល្មើសមួយនេះ[131]។ កាលពីមុន អង្គជំនុំជម្រះសាលាដំបូងមិនអាចរកភ័ស្តុតាងរបស់អ្នកផលិតខ្សែអាត់វីដេអូដែលជាសាក្សី TCW-៧២០[132] នេះបាន។ ប្រសិនបើអ្នកដែលមានវត្តមានក្នុងខ្សែអាត់វីដេអូ E189.1R មិនអាចមកផ្តល់ភ័ស្តុតាងបាន សហព្រះរាជអាជ្ញាយល់ស្របជាមួយក្រុមមេធាវីការពារក្តី នួន ជា ថា អង្គជំនុំជម្រះគួរស្តាប់សក្ខីកម្មមនុស្សមួយចំនួនផ្សេងទៀតដែលសហ-ព្រះរាជអាជ្ញាបានកំណត់អត្តសញ្ញាណរួច ជំនួសវិញ[133]។

78. សហព្រះរាជអាជ្ញា និង ក្រុមមេធាវីការពារក្តី នួន ជា យល់ស្របគ្នាថា អង្គជំនុំជម្រះគប្បីស្តាប់សក្ខីកម្មសាក្សី TCW-៦៤៥[134]។ គាត់ជាអ្នកស្រុកនៅមូលដ្ឋាននោះ ដែលទំនងជាបានផ្តល់សក្ខីកម្មថា គាត់បានឃើញរថយន្តធំៗ ដឹកជញ្ជូនមនុស្សទៅកាន់ទួលពោធិ៍ជ្រៃ និងក្រោយមកបន្ទាប់ពីមានការកាប់សម្លាប់ភ្លាមៗ គាត់បានទៅមើលទីតាំងនោះ[135]។ ទោះបីជាសក្ខីកម្មរបស់គាត់ផ្តល់នូវធាតុផ្សំថ្មីបន្ថែមខ្លះយ៉ាងណាក្តី ក៏អង្គជំនុំជម្រះចាត់ទុកថា ភ័ស្តុតាងនេះច្រំដែលដូចគ្នានឹងភ័ស្តុ-តាងឯទៀតពាក់ព័ន្ធនឹងបញ្ហានេះ និងដោយសារភាគីដែលស្នើសុំឱ្យស្តាប់សក្ខីកម្មសាក្សីរូបនេះ ត្រូវបានធ្វើឡើងកៀកចុងបញ្ចប់ពេក ហេតុដូចនេះ អង្គជំនុំជម្រះយល់ថា វាមិនមែនជាការសមស្របឡើយក្នុងការកោះហៅបុគ្គលរូបនេះ ។

---

[131] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីសេចក្តីលម្អិតបន្ថែមការគាំទ្រសំណើអនុលោមតាមវិធាន ៨៤(៤) នៃវិធានផ្ទៃក្នុង ឱ្យកោះហៅសាក្សីបន្ថែមទាក់ទងនឹងទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ, E292/1, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌទី ១។

[132] ឧបសម្ព័ន្ធ II, ផ្នែក xii(ង) (កត់សម្គាល់ការលំបាកក្នុងការទទួលបានសក្ខីកម្មរបស់បុគ្គលជាក់លាក់មួយចំនួនដែលជាបុគ្គល មើលទៅដូចជាមិនព្រមសហការ និងដែលអង្គជំនុំជម្រះពុំមានជម្រើសផ្សេងដើម្បីអាចយកសក្ខីកម្មបាន ដ្បិតបុគ្គលទាំងនេះមិនរស់នៅក្នុងប្រទេសកម្ពុជា)។

[133] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា ឆ្លើយតបទៅនឹងសំណើរបស់មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ សុំឱ្យផ្តល់ព័ត៌មានមុនកិច្ចប្រជុំរៀបចំសវនាការ, E288/3, ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣។

[134] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីសេចក្តីលម្អិតបន្ថែមការគាំទ្រសំណើអនុលោមតាមវិធាន ៨៤(៤)នៃវិធានផ្ទៃក្នុង ឱ្យកោះហៅសាក្សីបន្ថែមទាក់ទងនឹងទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ, E292/1, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌទី ១ ។ *សូមមើលផងដែរ* សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា ឆ្លើយតបទៅនឹងសំណើរបស់មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់ សុំឱ្យផ្តល់ព័ត៌មានមុនកិច្ចប្រជុំរៀបចំសវនាការ, E288/3, ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ ឧបសម្ព័ន្ធ ក។

[135] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [TCW-៦៤៥], D125/175, ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៩។

01004720



79. នៅថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានជម្រាបអង្គជំនុំជម្រះថា មនុស្សទាំងប្រាំរូបខាងក្រោម ដែលឃើញនៅក្នុងខ្សែអាត់វីដេអូ E186.1R នោះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញរកពួកគាត់មិនឃើញទេ[136]៖

- ប៉ូ ជាន រកមិនឃើញ
- អ៊ុន ធឿន រកមិនឃើញ
- អ៊ុត អ៊ី រកមិនឃើញ
- ព្រំ ប្រ៉េន រកមិនឃើញ
- ទិត ប៊ុនចាន់ រកមិនឃើញ

### ៣.២.៦ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានស្តាប់សក្ខីកម្មទាក់ទិននឹងផលប៉ះពាល់មកលើជនរងគ្រោះ

80. កាលពីថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះអនុញ្ញាតឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញភ័ស្តុតាងក្នុងសវនាការរយៈពេលមួយសប្តាហ៍ អំពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងផលប៉ះពាល់នៃឧក្រិដ្ឋកម្មដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១[137]។ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញខាងក្រោម បានផ្តល់សក្ខីកម្មអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្មដែលត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ មកលើជនរងគ្រោះ៖

---

136 អនុស្សរណៈរបស់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ដែលមានចំណងជើងថា "សាក្សីសក្តានុពល- មិនអាចរកឃើញ", E292/1/2, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣។

137 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/-០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ" ឯកសារ E218 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ១៨ ។ *សូមមើលផងដែរ* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "សេចក្តីជូនដំណឹងបន្ថែមពាក់ព័ន្ធនឹងការកំណត់កាលបរិច្ឆេទនៃសវនាការ" ឯកសារ E236/5 ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ។ ឧបសម្ព័ន្ធ ១៖ កាលបរិច្ឆេទដែលដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឡើង សម្រាប់សវនាការលើផលប៉ះពាល់មកលើជនរងគ្រោះ ឯកសារ E236/5/3/1.1 ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៣។

ដើមបណ្តឹងរដ្ឋប្បវេណី TCCP-២ អ៊ូន ផល្លី
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-៤ ប៉ែ សុផានី
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-៧ ចាន់ សុជាតិ ហៅ សុភាព
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៣ ឆេង អេងលី
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១០០ នូវ ហ៊ាន់
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១១៧ ប៉ូ ឌីណា
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១២៩ សាំង វ៉ាត់
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៤១ សេង ស៊ីវុត្ថា
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៤៥ សឿន សុវណ្ណី
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៤៩ សូផាន់ សុវណ្ណី
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៥១ ស៊ូ សូធារី
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៥៦ ធុច ផាន់ដារ៉ា
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៧០ យិន រំដួល
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៧២ យស់ ផល
ដើមបណ្តឹងរដ្ឋប្បវេណី TCCP-១៩៨ ហួ ចន្ថា
អ្នកជំនាញ TCE-១២ ឈឹម សុធារ៉ា

### ៣.២.៧ សាក្សីបន្ថែមដែលមេធាវីការពារក្តីបានស្នើសុំក្នុងសំណុំរឿង ០០២/០១

81. នៅក្នុងកិច្ចប្រជុំរៀបចំសវនាការលើកទីពីរ អង្គជំនុំជម្រះបានស្នើឲ្យក្រុមមេធាវីការពារក្តីកំណត់អត្តសញ្ញាណមនុស្សបន្ថែមណាផ្សេងទៀត ដែលខ្លួនយល់ថា មានសារៈសំខាន់ក្នុងការកោះហៅមកផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះ ដើម្បីតតាំងទៅនឹងការចោទប្រកាន់មកលើជនជាប់ចោទ ដើម្បីជាប្រយោជន៍នៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងចំពោះមុខ[138]។ ជាការឆ្លើយ

---

[138] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែម ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ", E218, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌទី ១២។

តបក្រុមមេធាវីការពារក្តី ខៀវ សំផន ស្នើសុំឱ្យស្តាប់សក្ខីកម្មបុគ្គលខាងក្រោមនេះ នៅពេលជំនុំជម្រះក្តី៖

- សាក្សី TCW-៣៨៤ ឡេង ឆឹង
- សាក្សី TCW-៥៧០ រស់ ស៊ុយ
- សាក្សី TCW-៦៧៣ សូ សុជាតិ
- សាក្សី TCW-៦៦៥ សុខ រឿ
- សាក្សី TCW-៦៨១ ស្រី ខែម
- សាក្សី TCW-៦៦៣ សុខ សុង

82. បុគ្គលបួនរូបខាងដើមត្រូវបានអង្គជំនុំជម្រះស្តាប់សក្ខីកម្មរួចហើយ។ អង្គជំនុំជម្រះសម្រេចមិនស្តាប់សក្ខីកម្មសាក្សី TCW-៦៨១ និងសាក្សីTCW-៦៦៣ ទេ ដោយហេតុថា ពួកគាត់មានទំនាក់ទំនងតិចតួចជាមួយនឹងជនជាប់ចោទ ហើយសក្ខីកម្មរបស់ពួកគាត់អាចមានលក្ខណៈច្រំដែលដូចគ្នានឹងសក្ខីកម្មរបស់សាក្សីឯទៀតពាក់ព័ន្ធនឹងកិច្ចប្រជុំនយោបាយនេះ[139]។

83. ក្រុមមេធាវីការពារក្តី នួន ជា ស្នើសុំឱ្យស្តាប់សក្ខីកម្មបុគ្គល ១៣ នាក់ដូចខាងក្រោម ដ្បិតខ្លួនយល់ថា សក្ខីកម្មរបស់ពួកគាត់មានភាពចំបាច់ ដើម្បីតតាំងទៅនឹងសក្ខីកម្មដាក់បន្ទុក និងជាពិសេស ដើម្បីបង្ហាញអំពីការទទួលខុសត្រូវដែលរងការចោទប្រកាន់ពីមន្ត្រីក្រោមឱវាទ៖

- អ្នកជំនាញ TCE-៣៣ Steven HEDER
- សាក្សី TCW-៣៨៩ លឹម សាត
- សាក្សី TCW-១២៦ ជួន ធី
- សាក្សី TCW-៦៧៦ [កោសលុប]
- សាក្សី TCW-៨៥ ជា ជឿម
- អ្នកជំនាញ TCE-២០ Sheila FITZPATRICK
- អ្នកជំនាញ TCE-២៣ John Arch GETTY
- សាក្សី TCW-២៤ Wendy GOLDMAN

---

[139] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រី ខែម E3/546, ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២។

- អ្នកជំនាញ TCE-២៨ Paul HAGENLOH
- អ្នកជំនាញ TCE-៤០ Hiroaki KUROMIYA
- អ្នកជំនាញ TCE-៥៦ Gabor Tamas RITTERSPORN
- អ្នកជំនាញ TCE-៧៥ Lynne VIOLA
- សាក្សី TCW-៣០១ Keith FINDLAY

84. អ្នកជំនាញ TCE-៣៣ សាក្សី TCW-៣៨៩ និង សាក្សី TCW-១២៦ សុទ្ធតែត្រូវបានស្តាប់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះរួចហើយ។ អង្គជំនុំជម្រះមិនអាចស្តាប់សក្ខីកម្មរបស់សាក្សី TCW-៦៧៦ ទេ ដោយសារគាត់បានទទួលមរណភាព[140]។ ចំពោះបុគ្គលប្រាំបួននាក់ចុងក្រោយដែលក្រុមមេធាវីការពារក្តី នួន ជា ស្នើសុំឱ្យស្តាប់សក្ខីកម្មពាក់ព័ន្ធនឹងរចនាសម្ព័ន្ធបញ្ជាមួយបែបទៀតដែលរងការចោទប្រកាន់ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ភាគច្រើននៃអ្នកទាំងនេះគឺជាអ្នកជំនាញដែលទំនងជាមានព័ត៌មានពាក់ព័ន្ធតិចតួច ឬមិនពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ ឬលក្ខណៈនៃតួនាទីរបស់ជនជាប់ចោទឡើយ។ អ្នកជំនាញ TCE-២០, អ្នកជំនាញ TCE-២៨, អ្នកជំនាញ TCE-២៣, អ្នកជំនាញ TCE-២៤, អ្នកជំនាញ TCE-៤០, អ្នកជំនាញ TCE-៥៦, និង អ្នកជំនាញTCE-៧៥ ត្រូវបានក្រុមមេធាវីការក្តី នួន ជា ពិពណ៌នាថា ជាប្រវត្តិវិទូនៃសហភាពសូវៀត ឬប្រទេសរុស្ស៊ី[141]។ បើទោះបីជា ក្រុមមេធាវីការពារក្តី នួន ជា អះអាងថា សក្ខីកម្មរបស់សាក្សី TCW-៨៥ និងសាក្សី TCW-៣០១ ទំនងជាអាចដោះបន្ទុកបាននោះ ផ្ទុយទៅវិញ អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មរបស់ពួកគាត់ទំនងជាពុំពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ នេះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចមិនកោះហៅបុគ្គលទាំងនេះ ដើម្បីស្តាប់សក្ខីកម្មក្នុងសវនាការនេះឡើយ។

85. លើសពីនេះទៅទៀត ក្រុមមេធាវីការពារក្តី នួន ជា បានដាក់សំណើសុំជាលាយលក្ខណ៍អក្សរនៅចំពោះមុខអង្គជំនុំជម្រះ ដោយសុំឱ្យស្តាប់សក្ខីកម្មរបស់បុគ្គលមួយចំនួនតូចបន្ថែមទៀតដែលខ្លួនអះអាងដដែលៗថា ពួកគាត់អាចផ្តល់ភ័ស្តុតាងដោះបន្ទុកក្នុងសំណុំរឿង ០០២/០១។ ក្រុមមេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យស្តាប់សក្ខីកម្មសាក្សីTCW-២៩២ ដោយសំអាងថា សាក្សី

---

[140] *សូមមើល* ឧបសម្ព័ន្ធ II, ផ្នែក xii(ច)។

[141] ឧបសម្ព័ន្ធ ខ៖ បញ្ជីស្នើសាក្សីជំនាញ– ក្រុមមេធាវីការពារក្តី នួន ជា, E9/4/4.2, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១។

រូបនេះដឹងអំពី "របចនាសម្ព័ន្ធបញ្ជាមួយបែបទៀតនៅក្នុងរបបខ្មែរក្រហមព្រមទាំងស្ថានការណ៍ទូទៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"[142]។ ក្រុមមេធាវីការពារក្តី នួន ជា ក៏បានស្នើសុំឱ្យកោះហៅសាក្សីTCW-២៤៣ ដើម្បីបំភ្លឺពាក់ព័ន្ធនឹងការជ្រៀតជ្រែកខាងនយោបាយដល់កិច្ចការរបស់ អ.វ.ត.ក និងដោយសារគាត់ដឹងអំពីស្ថានការណ៍នៅមុនឆ្នាំ១៩៧៥ ផ្អែកលើតំណែងពីមុនរបស់គាត់នៅក្នុងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ និងវត្តមាន និងការជាប់ឃុំឃាំងរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[143]។ ក្រោយមកទៀត ក្រុមមេធាវីការពារក្តី នួន ជា ដាក់ពាក្យសុំមួយទៀត ដោយលើកឡើងថាសាក្សី TCW-២៩២ "ធ្លាប់ជាសមាជិកជាន់ខ្ពស់ម្នាក់នៃក្រសួងការបរទេស ដោយមានទំនាក់ទំនងច្រើនជាមួយនឹង អៀង សារី"[144]។ ពាក់ព័ន្ធនឹងសាក្សី TCW-២៤៣ ក្រុមមេធាវីការពារក្តី នួន ជា លើកឡើងថា គាត់"ធ្លាប់កាន់មុខតំណែងទូតនៅទីក្រុងប៉ារីស និងប្រទេសគុយបា ពីឆ្នាំ ១៩៦៧-១៩៧៥ និងត្រូវបានពួកខ្មែរក្រហមឃុំខ្លួននៅបឹងត្របែកពីឆ្នាំ ១៩៧៥-

[142] សំណើសុំបន្ថែមសាក្សី និង បន្តសវនាការបឋម, E93/9,1 ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ ឧបសម្ព័ន៖ សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម, E93/9, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ ទំព័រទី ២០។ *សូមមើលផងដែរ* សំណើសុំបើកការស៊ើបសួរពាក់ព័ន្ធនឹងវិធាន ៣៥, E82 នៃវិធានផ្ទៃក្នុង ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌទី ៣១។

[143] សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម, E93/9, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ ឧបសម្ព័ន៖ សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម, E93/9, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ ឧបសម្ព័ន្ធ៖ សំណើសុំបន្ថែមសាក្សី និង បន្តសវនាការបឋម, E93/9.1 ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ ទំព័រទី ១៧។

[144] ញត្តិគាំទ្រសំណើ អៀង សារី ស្នើសុំស្តាប់សក្ខីកម្មសាក្សី [TCW-២៤៣] និង [TCW-២៩២], E228/2, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌទី ៣។ ចម្លើយតបទៅនឹងការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិចំពោះញត្តិរបស់ នួន ជា គាំទ្រសំណើ អៀង សារី ស្នើសុំស្តាប់សក្ខីកម្មសាក្សី [TCW-២៤៣] និង [TCW-២៩២], E228/4, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌទី ៥ (ការចោទប្រកាន់បន្ថែមថា សាក្សី TCW-២៩២ អាចផ្តល់សក្ខីកម្មពាក់ព័ន្ធនឹង "នរណានៅក្នុងរចនាសម្ព័ន្ធបក្ស ដែលមានអំណាចគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើអ្នកដែលត្រូវគេចាប់ខ្លួន និងបោសសម្អាត កម្រិតដែលបុគ្គលដែលមានឋានៈនៅក្រោមជនជាប់ចោទ មានការទទួលខុសត្រូវដោយឯករាជ្យក្នុងការបង្កើត "ពិធីសារ" និង "របចនាសម្ព័ន្ធរាយការណ៍" នៅក្នុងមន្ទីរនៃរបបកម្ពុជាប្រជាធិបតេយ្យ និងការដឹងដែលប្រធានមន្ទីរនេះទំនងជាមាន និង ទំនាក់ទំនងដោយផ្ទាល់រវាង ប៉ុល ពត និងបុគ្គលដែលនៅថ្នាក់ក្រោមជនជាប់ចោទ")។ សាក្សីTCW-២៩២ ដំបូងឡើយត្រូវបានស្នើសុំការដឹងរបស់គាត់អំពីរចនាសម្ព័ន្ធបញ្ជាផ្សេងទៀតនៅក្នុងសម័យខ្មែរក្រហមព្រមទាំងពាក់ព័ន្ធទៅនឹងការចោទប្រកាន់ជាទូទៅលើការជ្រៀតជ្រែកខាងនយោបាយ ៖ សំណើសុំបើកការស៊ើបសួរអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, E82, ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌទី ៣១។ សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម, E93/9, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ ឧបសម្ព័ន៖ សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម, E93/9.1, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ ទំព័រទី ២០។

១៩៧៩”[145]។ ការលើកឡើងពាក់ព័ន្ធនឹងបឹងត្របែកនេះ មានភាពពាក់ព័ន្ធតិចតួចទៅនឹងសំណុំរឿង ០០២/០១ ហើយអង្គជំនុំជម្រះពិចារណាឃើញថា សក្ខីកម្មរបស់បុគ្គលទាំងពីររូបនេះទំនងជាពាក់ព័ន្ធខ្លាំងតែទៅនឹងជនជាប់ចោទ អៀង សារី តែប៉ុណ្ណោះ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចមិនស្ដាប់ភ័ស្ដុតាងរបស់ពួកគេក្នុងសំណុំរឿង ០០២/០១ នេះឡើយ[146]។

### ៣.២.៨ សំណើសុំឱ្យកោះហៅសាក្សីដែលមិនមានការឯកភាពគ្នាជាឯកច្ឆ័ន្ទ

86. អង្គជំនុំជម្រះសាលាដំបូងមិនអាចឈានទៅដល់ការឯកភាពគ្នាជាឯកច្ឆ័ន្ទមួយថា តើត្រូវកោះហៅសាក្សី TCW-២២៣ និង TCW-៤៩៤ ដែលត្រូវបានស្នើសុំដែរឬយ៉ាងណា។ ដោយសារតែមិនអាចឈានដល់ការទទួលបានសម្លេងគាំទ្រពីចៅក្រម ៤ រូប អនុលោមតាមមាត្រា ១៤*ថ្មី* នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ជាហេតុនាំឱ្យមិនមានសាក្សីណាមួយត្រូវបានកោះហៅនោះទេ។ មតិយោបល់ដាច់ដោយឡែកចំនួនពីរត្រូវបានលើកឡើងពាក់ព័ន្ធនឹងចំណុចនេះ។

---

[145] សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម, E93/9, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ ឧបសម្ព័ន៖ សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម, E93/9.1, ថ្ងៃទី០៦ ខែ កក្កដា ឆ្នាំ ២០១១ ទំព័រទី ១៥។ *សូមមើលផងដែរ* ញត្តិគាំទ្រសំណើរបស់ អៀង សារី សុំស្ដាប់សក្ខីកម្មសាក្សី [TCW-២៤៣] និង [TCW-២៩២], E228/2, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១២, កថាខណ្ឌទី៣ (“តាមចម្លើយសាក្សីពីរនាក់ថា សាក្សី [TCW-២៤៣] ធ្លាប់ធ្វើជាប្រធានមន្ទីរបឹងត្របែកបានមួយរយៈ ទីនេះហើយដែល នួន ជា ត្រូវបានចោទប្រកាន់ថាបានទទួលខុសត្រូវចុងក្រោយគេ”)។ ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះញត្តិរបស់ នួន ជា គាំទ្រសំណើរបស់ អៀង សារី សុំស្ដាប់សក្ខីកម្មសាក្សី [TCW-២៤៣] និង [TCW-២៩២], E228/4, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌទី ៥ (ចោទប្រកាន់ថា សក្ខីកម្មរបស់សាក្សី TCW-២៤៣ មានភាពចាំបាច់ពាក់ព័ន្ធនឹង “តួនាទីរបស់ ប៉ង់ ដែលជាអន្តរការីរវាងគណមជ្ឈិម និងមន្ទីរស-២១ ដែលបើតាមសម្ដី កាំង ហ្កេកអ៊ាវ បាននាំសារដោយផ្ទាល់រវាងគាត់ និង ប៉ុល ពត។ ស្វ័យតភាពរបស់គាត់ ក្នុងការគ្រប់គ្រង មន្ទីរបឹងត្របែក ដែល នួន ជា ត្រូវបានចោទប្រកាន់ថាជាអ្នកទទួលខុសត្រូវ និងទំនាក់ទំនងរវាងប្រធានក្រសួង និង បុគ្គលក្រោមឱវាទរបស់គាត់”)។ សំណើរបស់ អៀង សារី ពាក់ព័ន្ធនឹងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ស្នើសុំស្ដាប់សក្ខីកម្មរបស់សាក្សី [TCW-២៩២ និង TCW-២៤៣], E228, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២។ *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ ទំព័រទី ១៦, ២០, ២៣-២៤។

[146] សំណើរបស់ អៀង សារី ពាក់ព័ន្ធនឹងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ស្នើសុំស្ដាប់សក្ខីកម្មរបស់សាក្សី [TCW-២៩២ និង TCW-២៤៣], E228, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ កថាខណ្ឌទី ១៧-២២។

## មតិយោបល់របស់ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និង ចៅក្រម យូរ ឧត្តរា

87. យើងសម្រេចថា សាក្សី TCW-២២៣ និង TCW-៤៩៤ ដែលត្រូវបានស្នើសុំឱ្យកោះហៅ មិនគួរត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះទេ។ សេចក្តីសម្រេចរបស់យើងខុសគ្នាពីសេចក្តីសម្រេចរបស់ចៅក្រមដែលជាសហសេវិករបស់យើង ហេតុដូច្នេះយើងសូមសង្ខេបសំអាងហេតុរបស់យើងដូចតទៅ។

88. វិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិការកោះហៅ *បុគ្គលណាម្នាក់* ក្នុងឋានៈជាសាក្សីដែលខ្លួនចាត់ទុកថាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត [147]។ វិធានផ្ទៃក្នុងក៏បានចែងផងដែរ ដោយសង្ខេបអំពីមូលដ្ឋានផ្សេងៗដែលអង្គជំនុំជម្រះអាចបដិសេធចោលសំណើសុំឱ្យពិនិត្យភស្តុតាង[148]។ សម្រាប់គោលបំណងនៃសេចក្តីសម្រេចរបស់យើង ដោយមិនចាំបាច់សម្រេចអំពីចំណុចខាងលើនេះ យើងសន្មតថា អំណាចនេះផ្តល់សិទ្ធិឱ្យអង្គជំនុំជម្រះសាលាដំបូងអាចកោះហៅសាក្សី TCW-២២៣ និង TCW-៤៩៤ ដែលសាក្សីទាំងពីររូបនេះគឺជាសមាជិកសភារបស់ប្រទេសកម្ពុជា។

89. យើងពិចារណាឃើញថា គោលការណ៍ខាងក្រោមនេះផ្តល់នូវការណែនាំពាក់ព័ន្ធក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ផ្អែកតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង[149]។ ដីកាកោះ

---

[147] វិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។

[148] វិធាន៨៧(៣) នៃវិធានផ្ទៃក្នុង។

[149] សូមមើល មាត្រា ១២(១) នៃកិច្ចព្រមព្រៀង៖ "នៅពេលណាដែលច្បាប់កម្ពុជា ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬ ក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នា រវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ" និងមាត្រា ៣៣*ថ្មី* នៃច្បាប់ អ.វ.ត.ក៖ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ "ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ"។

គឺជាដីកាបង្គាប់ដល់បុគ្គលណាម្នាក់ឱ្យបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក[150]។ ករណីដែលមិនបាន អនុវត្តតាមដីកាកោះនេះទេនោះ អាចនឹងនាំឱ្យមានការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ។ ប្រសិនបើការ ផ្តល់សក្ខីកម្ម មានភាពចាំបាច់សម្រាប់ការប្រព្រឹត្តិទៅ ក៏ដូចជា យុត្តិធម៌ នៃការជំនុំជម្រះទាំងមូល ។ យើងពិចារណាឃើញថា ដីកាកោះគួរតែចេញ និងបង្ខំឱ្យអនុវត្ត ដោយមិនចាំបាច់ពិចារណាទៅលើទស្សនៈដែលលើកឡើងដោយភាគីមិនស្ថិតនៅក្នុងរឿងក្តី ថាតើបុគ្គលរូបនោះគួរត្រូវបានកោះហៅ ឬ មិនគួរត្រូវបានកោះហៅនោះទេ។ ទោះបីជាយ៉ាងនេះក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលនៃ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានក្រើនរម្លឹកថា ដីកាបង្គាប់ឱ្យនាំខ្លួនមិនគួរចេះតែធ្វើឡើងដោយមិនបានពិចារណាឱ្យបានហ្មត់ចត់នោះទេ[151] ការផ្តួចផ្តើមប្រើប្រាស់អំណាចតុលាការដើម្បីចាប់បង្ខំ គួរថ្លឹងថ្លែងជាមួយនឹងភាពចាំបាច់ក្នុងការបម្រើផលប្រយោជន៍រួម នៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ[152]។ តុលាការអន្តរជាតិនានាបានដាស់តឿនឱ្យមានការប្រុង

---

[150] វិធាន៤៥(១) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤៧៧ (“ដីកាកោះហៅសាក្សីត្រូវបញ្ជាក់ថា៖ ការមិនចូលបង្ហាញខ្លួននៅពេលសវនាការ ការមិនព្រមឆ្លើយឱ្យព័ត៌មានក្នុងឋានៈជាសាក្សី ឬការឆ្លើយឱ្យព័ត៌មានក្លែងក្លាយត្រូវផ្តន្ទាទោសតាមច្បាប់”)។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៥៣៨៖ បទបដិសេធក្នុងការចូលខ្លួន (“រាល់បុគ្គលណា ដែលត្រូវបានកោះហៅឱ្យមកឆ្លើយជាសាក្សីនៅមុខអយ្យការ ឬចៅក្រមស៊ើបសួរ ឬមុខតុលាការព្រហ្មទណ្ឌ ហើយមិនព្រមចូលខ្លួនតាមដីកាកោះហៅនោះដោយគ្មានមូលហេតុសមស្រប ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល”)។

[151] *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Halilović*រឿងក្តីលេខ IT-01-48-AR73 *សេចក្តីសម្រេចលើការចេញដីកាបង្គាប់ឱ្យនាំខ្លួន* (ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៤) (“សេចក្តីសម្រេចលើរឿងក្តី *Halilovi*”) កថាខណ្ឌ ៥-៦។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Brđanin និង Talic* រឿងក្តីលេខ 1T -99-36- AR73.9 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ខំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៣១។ សូមមើលផងដែរ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Miloševi ć*រឿងក្តីលេខ IT-02-54-T *សេចក្តីសម្រេចលើពាក្យសុំរបស់មេធាវីដែលត្រូវបានចាត់តាំង ស្នើសុំស្តាប់ចម្លើយ និងសក្ខីកម្មរបស់ Tony Blair និង Gerhard Schroeder* (ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៥) ត្រង់កថាខណ្ឌ ៣៥ និង ៤៨។ យើងពិចារណាឃើញថា គោលការណ៍ស្តីពីការប្រុងប្រយ័ត្ននេះអនុវត្តដូចគ្នាចំពោះដីកាកោះនៅ អ.វ.ត.ក ពីព្រោះដីកាកោះ (Summonses) មិនខុសពីដីកាបង្គាប់ឱ្យនាំខ្លួន (Subpoenas) គឺជាដីកាដែលមានអានុភាពប្រើប្រាស់អំណាចចាប់បង្ខំបាន។

[152] *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karemera និងជនផ្សេងទៀត* រឿងក្តីលេខ ICTR-98-44-T *សេចក្តីសម្រេចលើញត្តិរបស់ Joseph Nzirorera ស្នើសុំដីកាបង្គាប់ឱ្យនាំខ្លួន Leon Mugesera និងប្រធានាធិបតី Paul Kagame* (ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៨) កថាខណ្ឌ ៥។

ប្រយ័ត្នថា តុលាការមិនគួរបំពាន ឬ យកយន្តការចាប់បង្ខំនេះមកប្រើប្រាស់ជាយុទ្ធសាស្ត្រនៃការជំនុំជម្រះក្តីឡើយ[153]។

90. នៅក្នុងការវាយតម្លៃរបស់យើង សារតារនីតិវិធីនៃបញ្ហានេះបានបង្ហាញច្បាស់ថា សាក្សី TCW-២២៣ និងសាក្សី TCW-៤៩៤ បានបដិសេធមិនមកផ្តល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក។ បញ្ហានេះបានទុកឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចថាតើគួរ ឬ មិនគួរប្រើប្រាស់វិធានការចាប់បង្ខំ។ នៅក្នុងដំណាក់កាលមុនការជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានព្យាយាមកោះហៅសាក្សីTCW-២២៣ និងសាក្សីTCW-៤៩៤ ក្នុងចំណោមសាក្សីផ្សេងទៀត ក្នុងគោលបំណងស្តាប់ចម្លើយពួកគេក្នុងនាមជាសាក្សី[154]។ នៅពេលបុគ្គលទាំងនេះមិនបានធ្វើការឆ្លើយតប សហ-ចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា ពួកគេបានបដិសេធមិនព្រមមកផ្តល់សក្ខីកម្ម[155]។ ក៏ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំបានជម្រុញបញ្ហាទាំងនេះបន្ថែមទៀតនោះទេ ដោយគ្រាន់តែបានកត់សម្គាល់ថា "ការអនុវត្តវិធានការចាប់បង្ខំអាចបង្កើតឱ្យមានផលវិបាកជាក់ស្តែងនានា" ដែលអាចនាំឱ្យមានការ "ពន្យារពេលដល់ការបិទកិច្ចស៊ើបសួរ"[156]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទុកបញ្ហានេះឱ្យអង្គជំនុំជម្រះសាលាដំបូង "សម្រេចថា តើការប្រើប្រាស់វិធានការចាប់បង្ខំនានា មានភាពចាំបាច់ ឬយ៉ាងណា"[157]។

---

[153] *សេចក្តីសម្រេចលើរឿងក្តី* *Halilović*កថាខណ្ឌ ១០។ *សូមមើល* ផងដែរ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Karadžić* រឿងក្តីលេខ 1T-95-5/18-T *សេចក្តីសម្រេចលើញត្តិលើកទីពីររបស់ជនជាប់ចោទស្នើសុំដីកាបង្គាប់ឱ្យនាំខ្លួនប្រធានាធិបតី* *Bill Clinton* *ដើម្បីយកមកស្តាប់ចម្លើយ* (ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២) កថាខណ្ឌ ១៦។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Karemera* *និងអ្នកផ្សេងទៀត* រឿងក្តីលេខ ICTR-98-44-T សេចក្តីសម្រេចលើបណ្តឹងរបស់មេធាវីការពារក្តីឱ្យនាំខ្លួនសាក្សីរបស់រដ្ឋអាជ្ញា ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ កថាខណ្ឌ ១៣។

[154] ពាក់ព័ន្ធនឹងសាក្សី TCW-223 ឯកសារ D136/3/1 ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៩។ ពាក់ព័ន្ធនឹងសាក្សី TCW-494 ឯកសារ D298/1 ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៩។

[155] ដីកាសម្រេច ឯកសារ D301 ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ទំព័រ ៣ ("ដូច្នេះ យើងមើលឃើញយ៉ាងច្បាស់ថាបុគ្គលពាក់ព័ន្ធទាំងនោះបានបដិសេធក្នុងការមកផ្តល់សក្ខីកម្ម")។

[156] ដីកាសម្រេច ឯកសារ D301 ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ទំព័រ ៣។

[157] ដីកាសម្រេច ឯកសារ D301 ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ទំព័រ ៤។

91. ក្រោយមក បញ្ហានេះត្រូវបានប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ អង្គបុរេជំនុំជម្រះបានធ្វើការរិះគន់លើសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត ក៏ប៉ុន្តែបានយល់ស្របថា បញ្ហានេះគួរទុកឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេច។ អង្គបុរេជំនុំជម្រះមិនបានសម្រេចលើភាពអាចអនុវត្តបាននៃអភ័យឯកសិទ្ធិនោះទេ ប៉ុន្តែ អង្គបុរេជំនុំជម្រះជឿជាក់ថា "លទ្ធភាពនៃការដកអភ័យឯកសិទ្ធិសភានឹងអាចមានការពន្យារពេលយូរទម្រាំដល់ពេលបុគ្គល...ទាំងនេះ អាចមកផ្ដល់សក្ខីកម្មនៅក្នុងដំណាក់កាលស៊ើបអង្កេត"[158]។ ហេតុដូច្នេះ វាមានការលំបាកជាក់ស្ដែងធំធេងក្នុងការទទួលបានសក្ខីកម្មពីបុគ្គលទាំងនេះ។

92. នាពេលនេះ យើងធ្វើការឆ្លើយតបជាបឋមទៅលើខ្លឹមសារនៃសំណើសុំស្ដាប់សក្ខីកម្មសាក្សី TCW-២២៣ ។ ក្រុមមេធាវីការពារក្ដី នួន ជា បានផ្ដល់ហេតុផលជាច្រើនអំពីមូលហេតុដែលពួកគេបានលើកឡើងថាហេតុអ្វីបានជាពួកគេត្រូវការសក្ខីកម្មទាំងនេះ។ នៅក្នុងខែ មិថុនា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្ដី នួន ជា ស្នើឡើងថា អង្គជំនុំជម្រះគួរកោះហៅសាក្សី TCW-២២៣ ឱ្យមកផ្ដល់សក្ខីកម្មអំពីតួនាទីរបស់វៀតណាម អំពី "វចនាសម្ព័ន្ធនៃការបញ្ជា" នៅក្នុងរបបខ្មែរក្រហម និងអំពីការជ្រៀតជ្រែកខាងនយោបាយនៅក្នុងប្រតិបត្តិការរបស់ អ.វ.ត.ក[159]។ ក្រុមមេធាវីការពារក្ដី នួន ជា បានលើកឡើងថា សាក្សី TCW-២២៣ "មានសារសំខាន់មិនអាចខ្វះបាន" សម្រាប់រឿងក្ដីរបស់ នួន ជា។ នៅក្នុងឱកាសក្រោយមកទៀត ក្រុមមេធាវីការពារក្ដី នួន ជា បានលើកឡើងហេតុផលបន្ថែមទៀតអំពីមូលហេតុដែលគួរកោះហៅសាក្សីរូបនេះ ដោយក្រុមមេធាវីបានលើកឡើងនៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១២ ថា សាក្សី TCW-២២៣ អាចផ្ដល់សក្ខីកម្មអំពីបរិបទប្រវត្តិសាស្ត្រ[160] ហើយបានលើកឡើងនៅក្នុងនៅក្នុងសារណារបស់ខ្លួនទៅកាន់អង្គជំនុំជម្រះតុលាការកំពូល កាលពីខែ សីហា ឆ្នាំ ២០១២ ថា សាក្សី TCW-២២៣ មាន "តួនាទីជាន់ខ្ពស់

---

[158] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ឯកសារ D314/2/7 ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៦៩។

[159] សម្ភារៈសម្រាប់ត្រៀមរៀបចំសម្រាប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដី ឯកសារ E93/4.3 ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១។

[160] បញ្ជីសាក្សីបន្ថែមទាក់ទងនឹងបរិបទប្រវត្តិសាស្ត្រ ឯកសារ E155/1.1 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៣-៥។

ផ្សេងៗគ្នា” និងថាសាក្សីរូបនេះបានចូលរួមនៅក្នុងកិច្ចប្រជុំនាថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ ដោយថានៅក្នុងកិច្ចប្រជុំនោះ មានពាក្យសម្ដីជាក់លាក់ដែលបានប្រើប្រាស់ដោយ នួន ជា[161]។ ក្រុមមេធាវីការពារក្ដីក៏បានស្នើសុំនៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១៣ ថា សាក្សី TCW-២២៣ គួរឱ្យមកផ្ដល់សក្ខីកម្មអំពីអត្តចរិតរបស់ នួន ជា តែប៉ុណ្ណោះ[162] និងបានស្នើឡើងនៅក្នុងខែ មិថុនា ឆ្នាំ ២០១៣ ថា សាក្សី TCW-២២៣ គួរឱ្យមកផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងចេតនារបស់ នួន ជា មកលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ដោយបានគូសបញ្ជាក់សាជាថ្មីអំពីពាក្យសម្ដីដែល នួន ជា បាននិយាយ នៅក្នុងពេលប្រជុំនាថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥[163]។ ចំណុចចុងក្រោយ ក្រោយពេលអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីអំពីបញ្ជីឈ្មោះសាក្សីចុងក្រោយរួចមក ដែលនៅក្នុងបញ្ជីនោះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា សាក្សី TCW-២២៣ នឹងមិនត្រូវបានកោះហៅ ទេនោះ ក្រុមមេធាវីការពារក្ដី នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញលើសេចក្ដីសម្រេចរបស់ខ្លួន[164]។

93. ផ្អែកតាមការយល់ឃើញរបស់យើង មេធាវីការពារក្ដី នួន ជា និយាយបំផ្លើសអំពីភាពចាំបាច់របស់សាក្សី TCW-២២៣ ដែលថា ជាសាក្សីសក្ខានុពល។ ការស្នើសុំឱ្យស្ដាប់សក្ខីកម្មអំពីការជ្រៀតជ្រែកខាងនយោបាយ ធ្លាប់ត្រូវបានអង្គជំនុំជម្រះសាលាដំបូងដោះស្រាយរួចរាល់អស់ហើយនៅក្នុងសំណើសុំ និងសេចក្ដីសម្រេចនានាជាច្រើន ហើយសំណើសុំទាំងនោះត្រូវបាន

---

[161] សូមមើល សំណើសុំស្ដាប់សាក្សីទាក់ទងនឹងការផ្លាស់ទីលំនៅរបស់ប្រជាជនដំណាក់កាលទី ១ និងទី ២ ឯកសារ E189/3/1/7.1.5 កថាខណ្ឌ ៣២-៣៣។ សូមមើល កិច្ចប្រជុំរៀបចំសវនាការលើកទី២ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/114.1 ERN00840238 សំណើសុំស្ដាប់សក្ខីកម្មសាក្សីទាក់ទងទៅនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងដំណាក់កាលទី២ ឯកសារ E189/3/1/7.1.5 ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១២ (ត្រូវបានសង្ខេបនៅក្នុង សំណើលើកទី៦ និងចុងក្រោយសុំកោះហៅសាក្សី TW-223 ឯកសារ E236/5/1/1ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១២ កថាខណ្ឌ ៥។)

[162] សំណើសុំកោះហៅសាក្សី TCW-២២៣ ដែលពាក់ព័ន្ធនឹងអត្តចរិតរបស់ នួន ជា ឯកសារ E236/5/1 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[163] សំណើបន្ទាន់កោះហៅសាក្សីគន្លឹះពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ ឯកសារ E291 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣១-៣២។

[164] សំណើសុំលើកទី ៦ និងជាចុងក្រោយ ឱ្យកោះហៅសាក្សី TCW-២២៣ ឯកសារ E236/5/1/1 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៣។

អង្គជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទបដិសេធចោល[165]។ ការស្នើសុំស្តាប់សក្ខីកម្មអំពីតួនាទីរបស់វៀតណាម គឺមិនពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១ នោះទេ។ ការស្នើសុំឱ្យស្តាប់សក្ខីកម្មរបស់សាក្សី TCW-២២៣ អំពីរចនាសម្ព័ន្ធយោធាគឺមានភាពច្រំដែល។ សាក្សីជាច្រើនបានផ្តល់សក្ខីកម្មអំពីរចនាសម្ព័ន្ធយោធាក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[166]។ មេធាវីការពារក្តី នួន ជា បានបង្ហាញអំពីកំណត់ហេតុស្តាប់ចម្លើយសាក្សី TCW-២២៣ ដែលធ្វើឡើងដោយ Benedict KIERNAN នៅឆ្នាំ១៩៨១ និងឆ្នាំ១៩៨២។ ទោះបីជាយ៉ាងណាក៏ដោយ យើងកត់សម្គាល់ឃើញថា សាក្សី TCW-២២៣ មិនបានអះអាងថា បានចូលរួមនៅក្នុងកិច្ចប្រជុំរៀបចំផែនការឱ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ទេ[167]។ មេធាវីការពារក្តី នួន ជា ផ្អែកលើកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលបានលើកឡើងថា នៅខែ មេសា ឆ្នាំ ១៩៧៥ សាក្សី TCW-២២៣ បានបញ្ជាវរសេនាធំលេខ ១២៦ ដែលជាវរសេនាធំមួយក្នុងចំណោមវរសេនាធំបីនៅក្នុងកងពលធំលេខ១ នៃភូមិភាគបូព៌ា[168]។ នៅក្នុងតួនាទីនេះកាលពីពេលនោះ គាត់ច្បាស់ជាបញ្ជាកងទ័ពចន្លោះពី ១៥០០ ទៅ ២០០០ នាក់[169]។ វរសេនាធំរបស់គាត់ពិតជាបានមកដល់វិមាន

---

[165] *សូមមើល* សេចក្តីសម្រេចលើសំណើសុំឱ្យមានវិធានការជាបន្ទាន់ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឯកសារ E189/3 ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ១៥-១៦។ សេចក្តីសម្រេចលើសំណើ អនុលោមតាមវិធាន ៣៥ ដែលសុំឱ្យមានចំណាត់ការជាបន្ទាន់ចំពោះរដ្ឋមន្ត្រីការបរទេស ហោ ណាំហុង ឯកសារE219/3 ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ១៨។

[166] សូមមើលតែសក្ខីកម្មរបស់សាក្សី កាំង ហ្កេកអ៊ាវ, TCW-428, TCW754, TCW-100, TCW126, TCW-253។

[167] បទសម្ភាសន៍ជាមួយ ជា ស៊ីម ទីក្រុងភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៨១ និងបទសម្ភាសន៍ជាមួយ ហេង សំរិន ទីក្រុងភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៨១ ឯកសារ E3/1568 ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ ERN 00651878។

[168] បទសម្ភាសន៍ជាមួយ ជា ស៊ីម ទីក្រុងភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៨១ និងបទសម្ភាសន៍ជាមួយ ហេង សំរិន ទីក្រុងភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៨១ ឯកសារ E3/1568 ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ ERN 00651878-80។

[169] បទសម្ភាសន៍ជាមួយ ជា ស៊ីម ទីក្រុងភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៨១ និងបទសម្ភាសន៍ជាមួយ ហេង សំរិន ទីក្រុងភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៨១ ឯកសារ E3/1568 ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ ERN 00651886 ("កងពលធំរបស់ខ្ញុំ ... ត្រៀមទាហានតែ ៦០០០-៨០០០ នាក់ ប៉ុណ្ណោះ", ERN 00651892 ("មួយកងពលមានបីកងវរសេនាធំ កងវរសេនាធំនីមួយៗមានបីកងវរសេនាតូច។ ទាហានពី ១៥០០-២០០០ នាក់ក្នុងមួយកងវរសេនាធំ ["កងវរសេនាតូច" - ក្រោយមកបានកែតម្រូវ គាត់បាននិយាយ]។ កងពលមួយចំនួនមានទាហាន ៧០០០-៨០០០នាក់ កងពលមួយចំនួនទៀតមានទាហាន ៥០០០-៦០០០ នាក់ ត្រៀមប្រយុទ្ធ", ERN 00651893 ("មួយកងវរសេនាតូច

01004732



ឯករាជ្យនៅទីក្រុងភ្នំពេញប្រហែលជាម៉ោង ៩ ព្រឹកកាលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[170]។ ហេតុដូច្នេះ ទោះបីជាយើងទទួលយកសាក្សី TCW-២២៣ ថាអាចផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញក៏ដោយ ក៏ប៉ុន្តែសាក្សីផ្សេងៗជាច្រើនទៀតបានផ្តល់សក្ខីកម្មបែបនេះរួចហើយនៅក្នុងសំណុំរឿង ០០២/០១ ហើយយើង យល់ឃើញថា សាក្សី TCW-២២៣ មិនមានព័ត៌មានពិសេសណាមួយដែលតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូង ត្រូវស្តាប់សក្ខីកម្មរបស់គាត់ឡើយ។ ហេតុដូច្នេះ កាលពីថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីនានាថា អង្គជំនុំជម្រះចាត់ទុកសាក្សី TCW-២២៣ "មិនសូវពាក់ព័ន្ធទៅនឹងចំណុចអង្គហេតុ [ការជម្លៀសប្រជាជន] ដែលត្រូវធ្វើសវនាការទាំងនេះ និងមិនស្តាប់សក្ខីកម្មរបស់គាត់ឡើយ"[171]។

94. មេធាវីការពារក្តី នួន ជា ក៏បានយោងទៅលើភ័ស្តុតាងដែលថាសាក្សី TCW-២២៣ បានចូលរួមនៅក្នុងកិច្ចប្រជុំមួយនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ ដែល នួន ជា បាននិយាយនៅក្នុងកិច្ចប្រជុំនោះ[172]។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មទាក់ទិននឹងកិច្ចប្រជុំនេះរួចហើយ ហេតុដូចនេះ ភ័ស្តុតាងបន្ថែមលើចំណុចនេះមានលក្ខណៈច្រំដែលច្រើន។ ប្រហែលជាដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា សក្ខីកម្មបែបនេះនឹងមិនមានភាពច្រំដែលទេនោះ ក្រុមមេធាវីការពារក្តី នួន ជា បានផ្អែកលើផ្នែកជាក់លាក់មួយនៅក្នុងកំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ KIERNAN។ យោងតាមការកត់ត្រានៅក្នុងកំណត់ហេតុនេះ សាក្សី TCW-២២៣ បាននិយាយប្រាប់ KIERNAN ថា នៅពេលថ្លែងក្នុងកិច្ចប្រជុំនាថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ និងនៅពេលនិយាយសំដៅលើប្រជាជនរបស់រដ្ឋាភិបាលចាស់ នួន ជា បានប្រើ

---

មានទាហានពី ៤០០-៥០០ នាក់។ [មិនមែន ១៥០០-២០០០ នាក់ ដូច [មិនច្បាស់] បាននិយាយពីមុនទេ ។ មួយកងវរសេនាធំមានទាហានពី ១៥០០ ទៅ ២០០០នាក់"។

170 បទសម្ភាសន៍ជាមួយ ជា ស៊ីម ទីក្រុងភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩១ និងបទសម្ភាសន៍ជាមួយ ហេង សំរិន ទីក្រុងភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩១ ឯកសារ E3/1568 ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ ERN 00651879។ បន្ទាប់ក្រោយមក គាត់បានស្នាក់នៅទីក្រុងភ្នំពេញអស់រយៈពេលបីសប្តាហ៍មុនពេលត្រូវបានបញ្ជូនត្រឡប់ទៅបូព៌ាវិញ។

171 ការបញ្ជាក់ជាបឋម អំពីបុគ្គលដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងអំឡុងសវនាការលើចំណុចអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងសំណុំរឿង ០០២/០១ ឯកសារE236/1 ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២។

172 សំណើសុំកោះហៅសាក្សី TCW-២២៣ ដែលពាក់ព័ន្ធនឹងអត្តចរិតជំនួសឱ្យ នួន ជា ឯកសារ E236/5/1 ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៦។

ប្រាស់ពាក្យ "កម្ចាត់" មិនមែន "កំទេច" ទេ។ KIERNAN បានបកប្រែថា "កម្ចាត់" គឺមានន័យថា "scatter = ខ្ចាត់ខ្ចាយ"[173] (ការបកប្រែនេះហើយដែលក្រុមមេធាវីការពារក្ដី នួន ជា យកមកធ្វើជាមូលដ្ឋាន)[174]។ ក្រុមមេធាវីការពារក្ដី នួន ជា ថាវាផ្ទុយគ្នារវាងពាក្យ "កម្ចាត់" ជាមួយនឹងពាក្យ "កម្ទេច" ដោយពួកគេបានអះអាងថា ពាក្យ"កម្ទេច" គឺមានន័យថាធ្វើឱ្យខ្ទេច មានន័យថា "សម្លាប់"។ ក្រុមមេធាវីការពារក្ដី នួន ជា អះអាងថា ការប្រើប្រាស់ពាក្យ "scatter = ខ្ចាត់ខ្ចាយ" (មិនមែន "សម្លាប់") បានបង្ហាញឱ្យឃើញនូវចេតនារបស់ នួន ជា មកលើអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[175]។

95. យើងជឿជាក់ថា ទោះបីជា នួន ជា បាននិយាយ "កម្ចាត់" ឬ "កម្ទេច" ក៏វាមិនពាក់ព័ន្ធអ្វីទេ។ ជាពិសេស យើងបដិសេធការអះអាងរបស់ក្រុមមេធាវីការពារក្ដី នួន ជា ដែលថា ពាក្យ "កម្ចាត់" ប្រហែលជាអាចដោះបន្ទុក ដោយសារយើងយល់ថា ពាក្យ "កម្ចាត់" គឺមិនមែនមានន័យត្រឹមតែ"scatter = ខ្ចាត់ខ្ចាយ"នោះទេ[176]។ យើងក៏កត់សម្គាល់ឃើញផងដែរថា ក្រុមមេធាវីការពារក្ដី នួន ជា មិនបានតវ៉ាទៅនឹងភស្តុតាងរបស់ Stephen HEDER ដែលថា វានឹងមិនត្រឹមត្រូវឡើយ ប្រសិនបើបកប្រែពាក្យ "កម្ចាត់" ថាមានន័យថា "ធ្វើឱ្យខ្ចាត់ខ្ចាយ" នោះ[177]។ យោងតាម Stephen HEDER ពាក្យ "កម្ចាត់" មានន័យ "ធ្ងន់ជាង ពាក្យ"scatter = ខ្ចាត់ខ្ចាយ"

---

[173] សៀវភៅនិពន្ធដោយ Ben Kiernan ចំណងជើងថា "របបប៉ុលពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជ-សាសន៍ នៅក្នុងប្រទេសកម្ពុជា" ឯកសារ E3/1593 ទំព័រ ៨៩។

[174] សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា កថាខណ្ឌ ៣៨៥។ ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣ (សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ នួន ជា) ទំព័រ ៣។

[175] *សូមមើល* សំណើលើកទី ៦ និងចុងក្រោយ សុំកោះហៅសាក្សី TCW-223 ឯកសារ E236/5/1/1 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌ ១២។

[176] ក្រុមមេធាវីការពារក្ដី នួន ជា សន្និដ្ឋានថា សាស្ត្រាចារ្យ David CHANDLER បានទទួលស្គាល់ថា វាមាន "ភាពខុសគ្នាយ៉ាងពិតប្រាកដ" រវាងពាក្យខ្មែរទាំងពីរពាក្យនេះ (*សូមមើល* សំណើសុំកោះហៅសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី ១ និងទី ២ ឯកសារ E189/3/1/7.1.5 កថាខណ្ឌ ៣៣។ យើងយល់ថា សាស្ត្រាចារ្យ David CHANDLER មិនបានបង្ហាញទស្សនៈណាមួយលើករណីថាតើវាពិតជាត្រឹមត្រូវនៅពេលបកស្រាយពាក្យ "កម្ចាត់" ថាត្រឹមតែមានន័យថា "ខ្ចាត់ខ្ចាយ" នោះទេ (សូមមើល ប្រតិចារឹក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រ ៣៧-៣៨)។

[177] ប្រតិចារឹក ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៧៨ ជួរ ១-២។

ពោលគឺមានន័យថា កម្ចាត់ចោល ឬ លុបបំបាត់ចោល"[178]។ យើងយល់ឃើញថា Stephen HEDER ពិតជាត្រឹមត្រូវដែលនិយាយថា ពាក្យ"កម្ចាត់ មិនមែនមានន័យថា"scatter = ខ្ចាត់ខ្ចាយ"[179]។

96. ហេតុដូច្នេះ បើទោះបីជាយើងទទួលស្គាល់ថា សក្ខីកម្មពីសាក្សី TCW-២២៣ អាចពាក់ព័ន្ធតិចតួចនៅក្នុងរឿងក្តី ០០២/០១ ក៏ដោយ ក៏យើងជឿជាក់ថា វាមិនមានភាពចាំបាច់ ឬ សមស្របត្រូវចាប់បង្ខំឱ្យស្តាប់សក្ខីកម្មពីបុគ្គលនេះឡើយ។ យោងតាមការកត់ត្រានៅក្នុងកំណត់ហេតុសាក្សី TCW-២២៣ បានលើកឡើងថា គាត់គឺជាមនុស្សម្នាក់ក្នុងចំណោម "មនុស្សរាប់ពាន់នាក់" ដែលបានចូលរួមកិច្ចប្រជុំនាថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥[180]។ យើងបានថ្លឹងថ្លែងតម្លៃនៃសក្ខី-កម្មរបស់សាក្សី TCW-២២៣ ជាមួយនឹងស្ថានភាពជាក់ស្តែងដែលថា គាត់បានបដិសេធមិនគោរពតាមដីកាកោះដែលបានចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិរួចទៅហើយ ហើយដែលអង្គជំនុំជម្រះសាលាដំបូងត្រូវបានស្នើឱ្យពិចារណាថា តើគួរប្រើវិធានការចាប់បង្ខំរយៈការដាក់ទណ្ឌកម្មព្រហ្មទណ្ឌដែរ ឬយ៉ាងណា ក្នុងការស្តាប់ចម្លើយសាក្សី នេះ។ ដោយពិចារណាថ្លឹងថ្លែងទៅលើកត្តាទាំងនេះ យើងជឿជាក់ថា ការស្តាប់សក្ខីកម្មរបស់សាក្សី នេះមិនមានភាពចាំបាច់នោះទេ។ ហេតុដូច្នេះហើយ ទើបយើងមិនចេញដីកាកោះហៅសាក្សី នេះ។

97. យើងបានសន្និដ្ឋានថា សាក្សី TCW-២២៣ នឹងគ្មានអភ័យឯកសិទ្ធិលើដីកាកោះហៅទេ។ ទោះបីជាយ៉ាងនេះក៏ដោយ យោងតាមការវាយតម្លៃរបស់យើង វានឹងមិនសមស្របទេ ប្រសិនបើយើងមិនពិចារណាលើការបដិសេធរបស់សាក្សី TCW-២២៣ ដែលមិនបានមកផ្តល់សក្ខីកម្មនៅ

---

[178] ប្រតិចារិក ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៧៨ ជួរ ៣-៥។ យើងកត់សម្គាល់ឃើញថា ក្រុមមេធាវីការពារក្តី នួន ជា ពុំបានសួរដេញដោលការបកស្រាយពាក្យ "កម្ចាត់" ជាមួយនឹងសាក្សីផ្សេងទៀតឡើយ។

[179] ទោះក្នុងករណីនាក៏ដោយ ដីកាដំណោះស្រាយបានចោទប្រកាន់ដូចតទៅ៖ "ក្នុងមហាសន្និបាតមួយនៅទីក្រុងភ្នំពេញនាខែ ឧសភា ឆ្នាំ ១៩៧៥ នួន ជា បានពន្យល់ថា អតីតទាហាន និងមន្ត្រីរដ្ឋការរបស់របប លន់ នល់ មិនឱ្យស្ថិតនៅក្នុងក្របខណ្ឌកម្លាំងរបស់របបថ្មី ទេ"។ ដីកាដំណោះស្រាយ (ក.ស.ច.ស) ឯកសារ D427 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ៩៧៧។

[180] កិច្ចសម្ភាសន៍ជាមួយនឹង ជា ស៊ីម ទីក្រុងភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៨១ និងជាមួយ ហេង សំរិន ទីក្រុងភ្នំពេញ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៨១ ឯកសារ E3/1568 ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ ERN 00713952-00713954។

ចំពោះមុខសហចៅក្រមស៊ើបអង្កេត និងករណីដែលថាអង្គបុរេជំនុំជម្រះបានលើកឡើងយ៉ាងច្បាស់លាស់រួចហើយថា បញ្ហានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងគឺមិនត្រឹមតែពិចារណាថាតើគួរ ឬមិនគួរចេញដីកាកោះនោះទេ តែក៏ត្រូវពិចារណាផងដែរថា តើគួរប្រើប្រាស់វិធានការចាប់បង្ខំដែរ ឬយ៉ាងណា នោះ។ ហេតុដូច្នេះ ទោះបីជាយើងសន្មត់ថា យើងអាចចេញដីកាកោះដែលមានសុពលភាពត្រឹមត្រូវ ដីកានោះត្រូវភ្ជាប់ជាមួយនូវវិធានការអនុវត្ត និងនីតិវិធីប្រមាថតុលាការ។ បញ្ហាអភ័យឯកសិទ្ធិ និងសមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងនឹងកើតមានឡើង។ ជាលទ្ធផលដីកាកោះនឹងនាំឱ្យមានការពន្យារពេលបន្ថែម ហើយនឹងធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងធ្លាក់ចូលក្នុងស្ថានភាពមួយដែលពោរពេញទៅដោយភាពលំបាកលំបិន។ វាមានហានិភ័យធំធេង ដែលធ្វើឱ្យយើងមិនអាចទទួលបានសក្ខីកម្មរបស់សាក្សី TCW-២២៣ នៅក្នុងពេលវេលាមួយសមស្រប។ ទោះបីជាយ៉ាងនេះក៏ដោយ បញ្ហាចោទសំខាន់នៅពេលនេះគឺថាតើយើងត្រៀមខ្លួនចាប់បង្ខំឱ្យស្តាប់សក្ខីកម្មបែបនេះ និងត្រៀមខ្លួនប្រឈមមុខជាមួយនឹងបញ្ហាអភ័យឯកសិទ្ធិនេះរួចហើយ ឬ នៅ។ យើងមិនបានត្រៀមខ្លួនពិចារណាលើបញ្ហាបែបនេះនោះទេ ក្នុងពេលដែលយើងមិនជឿលើសារសំខាន់នៃសក្ខីកម្មបែបនេះចំពោះសំណុំរឿង ០០២/០១ ផងនោះ។

98. ការច្រានចោលសាក្សីណាមួយ គួរថ្លឹងថ្លែងជាមួយនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសិទ្ធិកោះហៅសាក្សីដោះបន្ទុក។ ទោះបីជាយ៉ាងនេះក៏ដោយ ដូចយើងបានព្យាយាមពន្យល់រួចហើយ យើងយល់ឃើញថា នួន ជា មិនទទួលរងព្យសនកម្មអ្វីដោយសារករណីនៃការមិនកោះហៅសាក្សី TCW-២២៣ នោះឡើយ។ យើងយល់ឃើញ មិនមានហេតុផលសមស្របដែលថា សក្ខីកម្មសាក្សី TCW-២២៣ នឹងមានប្រយោជន៍ធំធេងដល់ការការពារក្តី នួន ជា នោះទេ។ តាមពិតទៅ បើយោងតាមកំណត់ហេតុដែលក្រុមមេធាវីការពារក្តីយកមកសំអាងនេះ សក្ខីកម្មពី TCW-២២៣ អាចបង្កការខូចខាតដល់ការការពារក្តីដល់ នួន ជា ទៅវិញទេ។ យើងកត់សម្គាល់ឃើញថា នួន ជា មានបំណងចង់បញ្ជាក់អំពីកំណត់ហេតុសម្ភាសន៍របស់អ្នកដែលត្រូវបានសម្ភាសន៍គឺសាក្សី TCW-២២៣ ដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ[181]។ យើងយល់ឃើញថាកំណត់ហេតុរបស់ Ben KIERNAN បង្ហាញគ្រប់គ្រាន់ និងគួរឱ្យជឿទុកចិត្តថា សាក្សី TCW-

[181] កំណត់ហេតុសម្ភាសន៍របស់ TCW-៩២ ភ្នំពេញ ថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ១៩៩១ និងកំណត់ហេតុសម្ភាសន៍របស់ TCW-២២៣ ភ្នំពេញ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៩១ ឯកសារE3/1568។

២២៣ ពិតជាបាននិយាយពាក្យពេចន៍ និងមតិយោបល់បែបនេះមែនដែលមេធាវីការពារក្តី នួន ជា បានពឹងផ្អែកទៅលើនោះ[182]។ ទោះបីជាកោះហៅសាក្សីនេះឱ្យមកបញ្ជាក់អំពីកំណត់ហេតុនៃកិច្ចសម្ភាសន៍នេះក៏ដោយ ក៏ការកោះហៅនេះមិនបានបង្ហាញឱ្យឃើញថា មិនមានគោលនយោបាយកម្ចាត់អតីតមន្ត្រីរបប លន់ នល់ នោះទេ។ បញ្ហានេះនឹងត្រូវវាយតម្លៃដោយពិចារណាទៅលើភស្តុតាងទាំងអស់។ ផ្អែកតាមកាលៈទេសៈទាំងអស់នេះ យើងយល់ឃើញថា សិទ្ធិរបស់ នួន ជា មិនត្រូវបានប៉ះពាល់ដោយសារតែការបដិសេធរបស់យើងក្នុងការកោះហៅសាក្សី TCW-២២៣ នេះឡើយ។

99. ចំពោះសាក្សីបន្ទាប់ TCW-៤៩៤ មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យកោះហៅដើម្បីផ្តល់សក្ខីកម្មអំពី (i) ការជ្រៀតជ្រែកខាងនយោបាយ (ii) តួនាទីរបស់ប្រទេសវៀតណាម (iii) វចនាសម្ព័ន្ធយោធា[183]។ បុគ្គលនេះត្រូវបានគេលើកឡើងនៅក្នុងបទសម្ភាសន៍ជាមួយ Ben KIERNAN និង Steven HEDER[184]។

100. ទាក់ទិននឹងការស្នើសុំភស្តុតាងរបស់សាក្សីTCW-៤៩៤ អំពីតួនាទីរបស់ប្រទេសវៀតណាម យើងពិចារណាឃើញថា ភស្តុតាងបែបនេះមិនពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ នោះទេ។ ទាក់ទិននឹងការចោទប្រកាន់អំពីការជ្រៀតជ្រែកខាងនយោបាយ អង្គជំនុំជម្រះសាលាដំបូងបានយោងជាច្រើនដងទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែលបានសម្រេចថា មិនមានមូលដ្ឋានណាមួយដើម្បីកោះហៅសាក្សីមកផ្តល់សក្ខីកម្មអំពីការចោទប្រកាន់បែបនេះទេ[185]។

---

[182] *របបប៉ុលពត៖ ពូជសាសន៍ អំណាច អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាក្រោមរបបខ្មែរក្រហម* ឯកសារ E3/1593 ឆ្នាំ១៩៩៦។

[183] សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម ឯកសារ E93/9 ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១។ ឧបសម្ព័ន្ធ៖ សំណើសុំបន្ថែមសាក្សី និងបន្តសវនការបឋម ឯកសារ E93/9.1 ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ ទំព័រ A29-A30។

[184] កិច្ចសម្ភាសន៍រវាង Ben Kiernan ជាមួយនឹង TCW-៤៩៤ ឯកសារ E3/432 ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៨០។ កិច្ចសម្ភាសន៍រវាង Stephen Heder ជាមួយនឹង TCW-៤៩៤ ឯកសារ E3/387 ថ្ងៃទី ០៤ ខែសីហា ឆ្នាំ ១៩៨០។

[185] សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល សំណុំរឿង០០១ ឯកសារF28 ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ៧៩-៨០។

101. សាក្សីផ្សេងទៀត រួមទាំង ឈូក រិន, Philip SHORT និង David CHANDLER បានផ្តល់សក្ខីកម្មអំពីរចនាសម្ព័ន្ធបញ្ជាផ្សេងៗទៀតរួចហើយ។ ហេតុដូច្នេះ សក្ខីកម្មសាក្សី TCW-៤៩៤ ដែលបានស្នើសុំឱ្យស្តាប់នេះគឺមានលក្ខណៈច្រំដែលដដែលៗច្រើន[186] ។ យើងយល់ឃើញថា ភស្តុតាងណាមួយដែលសាក្សី TCW-២២៣ អាចផ្តល់ឱ្យទាក់ទិននឹងជម្លោះរវាងភូមិភាគបូព៌ា និងពួកមជ្ឈិមនៅចុងទសវត្សឆ្នាំ១៩៧០ គឺមិនសូវសំខាន់ទាក់ទិននឹងបញ្ហានានានៅក្នុងសំណុំរឿង ០០២/០១ ទេ។

102. យើងកត់សម្គាល់ឃើញថា កិច្ចសម្ភាសន៍រវាង Stephen HEDER ជាមួយនឹងសាក្សី TCW-៤៩៤ ត្រូវបានទទួលយកមកធ្វើជាភស្តុតាងរួចហើយ ដោយនៅក្នុងបទសម្ភាសន៍នោះ សាក្សី TCW-៤៩៤ បានលើកឡើងថា នៅខែកុម្ភៈ ឆ្នាំ១៩៧៥ មានផែនការសង់ផ្ទះ ដើម្បីទទួលប្រជាជនដែលត្រូវបានជម្លៀសពីភ្នំពេញ ហើយផែនការនេះត្រូវបានគេផ្សព្វផ្សាយ[187]។ ចម្លើយនេះមិនបានពាក់ព័ន្ធដោយផ្ទាល់ជាមួយជនជាប់ចោទទេ ឬសំដៅទៅលើអំពើ និងការប្រព្រឹត្តិរបស់ពួកគេនោះទេ។ ចម្លើយនេះក៏មិនបានលើកឡើងអំពីកាលៈទេសៈជាក់ស្តែងនៃការជម្លៀសប្រជាជននៅខែ មេសា ឆ្នាំ ១៩៧៥ទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងអាចចាត់ទុកឯកសារនេះបែបនេះ ដោយគ្រាន់តែមានការការពារជាចាំបាច់ សម្រាប់ជាភស្តុតាងជាឯកសារ និងភស្តុតាងមិនច្បាស់លាស់ប៉ុណ្ណោះ។ លើសពីនេះទៀត យើងកត់សម្គាល់ឃើញថា មេធាវីការពារក្តី នួន ជា បានលើកឡើងថា សក្ខីកម្មមានលក្ខណៈដោះបន្ទុក។ នៅត្រង់ចំណុចនេះ យើងពិចារណាឃើញថា កំណត់ហេតុស្តាប់ចម្លើយ មានភាពគ្រប់គ្រាន់រួចហើយ។ ហេតុដូច្នេះ យើងសន្និដ្ឋានថា យើងមិនចាំបាច់កោះហៅអ្នកផ្តល់ចម្លើយដើម្បីបញ្ជាក់អំពីកំណត់ហេតុ ស្តាប់ចម្លើយនេះនោះទេ។ ផ្អែកតាមកាលៈទេសៈទាំងអស់ និងវិញ្ញកន្ទូវកត្តានានាដែលបានពិចារណាខាងលើទាក់ទិននឹងសាក្សី TCW-២២៣ យើង ចាត់ទុកថា វាមិនចាំបាច់ដើម្បីកោះហៅសាក្សី TCW-៤៩៤ ទាក់ទិននឹងសំណុំរឿង ០០២/០១ នោះទេ។

---

[186] សូមមើលផងដែរ សក្ខីកម្មរបស់សាក្សី កាំង ហ្គេកអ៊ាវ, TCW-428, TCW-754, TCW-100, TCW-126, TCW-253។

[187] កិច្ចសម្ភាសន៍រវាង Stephen Heder ជាមួយនឹង TCW-៤៩៤ ឯកសារ E3/387 ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩០។

103. តាមសេចក្ដីសង្ខេបនេះ យើងយល់ឃើញថា សក្ខីកម្មពីសាក្សី TCW-២២៣ ឬ សាក្សី TCW-៤៩៤ មិនមានសារសំខាន់សម្រាប់សំណុំរឿង ០០២/០១ នោះទេ។ យើងជឿជាក់ថា សក្ខីពីសាក្សីណាម្នាក់ក្នុងចំណោមសាក្សីទាំងពីរនេះនឹងមិនអាចជួយជ្រោមជ្រែងធំធេងដល់ជនជាប់ចោទឡើយ។ ការលំបាកជាក់ស្ដែងនៃការអនុវត្តដីកាកោះបែបនេះតម្រូវឱ្យយើងមិនកោះហៅបុគ្គលទាំងនេះ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងព្យាយាមចាប់បង្ខំឱ្យស្ដាប់សក្ខីកម្មពីសាក្សី TCW-២២៣ និង/ឬ សាក្សី TCW-៤៩៤ នោះ បញ្ហាចោទដ៏លំបាក និងបញ្ហាមុខជានឹងលេចឡើងពាក់ព័ន្ធនឹងអភ័យឯកសិទ្ធិរបស់ពួកគេរួចផុតពីការចោទប្រកាន់[188]។ យើងមិនបង្ហាញការយល់ឃើញថាតើពួកគេមានអភ័យឯកសិទ្ធិដែរ ឬក៏អត់នោះទេ ចំពោះការចោទប្រកាន់ ហើយយើងក៏មិនបានត្រៀមខ្លួនរួចជាស្រេចក្នុងការស្នើសុំចាប់បង្ខំឱ្យស្ដាប់សក្ខីកម្មរបស់ពួកគេនោះដែរ នៅពេលដែលយើងមិនជឿជាក់ផងនោះថា សក្ខីកម្មពីសាក្សីណាម្នាក់គឺពិតជាមានភាពចាំបាច់នោះ។ យើងយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនគួរពិចារណាបញ្ហាច្បាប់ និងការលំបាកជាក់ស្ដែងដែលមិនមានភាពចាំបាច់នេះឡើយ។ ដោយសារកាលៈទេសៈបែបនេះហើយ ទើបយើងបដិសេធចោលសំណើសុំនានារបស់ក្រុមមេធាវីការពារក្ដី នួន ជា ផ្អែកតាមវិធាន ៨៧(៣)(ក) (ខ) (គ) និង (ង)។

**<u>មតិយោបល់របស់ចៅក្រម Silvia CARTWRIGHT និងចៅក្រម Jean-Marc LAVERGNE</u>**

104. យើងផ្ដល់មតិយោបល់ដាច់ដោយឡែកបែបនេះ ដោយសារតែយើងយល់ផ្សេងពីមតិភាគច្រើនត្រង់ចំណុចថាតើសាក្សី TCW-២២៣ និង TCW-៤៩៤ គួរត្រូវបានកោះហៅមកផ្ដល់សក្ខីកម្មនៅក្នុងរឿងក្ដីនេះដែរ ឬទេ។

105. ក្រុមមេធាវីការពារក្ដី នួន ជា បានដាក់សំណើជាច្រើន ដោយស្នើសុំឱ្យស្ដាប់សក្ខីកម្មរបស់សាក្សី TCW-២២៣ ដោយសំអាងលើមូលហេតុដូចតទៅនេះ៖ (១) ការដឹងរបស់គាត់អំពីការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការ (២) ការដឹងរបស់គាត់ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធបញ្ជារបស់ពួកខ្មែរក្រហម ដោយសារតែគាត់កាន់មុខតំណែងខ្ពស់ក្នុងរបបខ្មែរក្រហម នៅមុនពេលគាត់ផ្ដាច់

---

[188] *សូមមើល* រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៨០ និង ១០៤ ចែងថា ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភា ឬ ព្រឹទ្ធសភានឹងអាចធ្វើទៅកើតលុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬ ព្រឹទ្ធសភា វៀរលែងតែក្នុងករណី *បទល្មើសព្រហ្មទណ្ឌជាក់ស្ដែង*។

ខ្លួន (៣) ជាសាក្សីបញ្ជាក់ពីអត្តចរិតរបស់ នួន ជា និង (៤) ដោយសារគាត់ជាមន្ត្រីយោធាជាន់ខ្ពស់បំផុតម្នាក់របស់ខ្មែរក្រហម ដែលនៅរស់រានមានជីវិតនៅឡើយ និងធ្លាប់បានចូលរួមក្នុងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ និងជាសាក្សីម្នាក់ក្នុងចំណោមសាក្សីពីរនាក់ដែល តាមការអះអាង អាចមានភ័ស្តុតាងផ្ទាល់ស្តីពីចេតនាផ្សេងៗរបស់មជ្ឈិមបក្សពាក់ព័ន្ធថា តើមានគោលនយោបាយសម្លាប់អតីតមន្ត្រីនៃរបប លន់ នល់ ដែរ ឬទេ[189]។

106. ដំបូង យើងកត់សម្គាល់ឃើញថា សំណើសុំឱ្យកោះហៅមន្ត្រីរដ្ឋាភិបាល មិនបានធ្វើឱ្យមន្ត្រីទាំងនោះក្លាយជាជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទនោះឡើយ[190]។ អ្នកទាំងនោះត្រូវបានស្នើសុំឱ្យកោះហៅមកធ្វើជាសាក្សី ហើយក្នុងនាមជាប្រជាពលរដ្ឋផងដែរ ពួកគាត់មានភារកិច្ចជួយចៅក្រម អ.វ.ត.ក ក្នុងការស្វែងរកការពិតក្នុងសំណុំរឿងមួយដែលមានសារៈសំខាន់ជាសារវ័ន្តចំពោះប្រជាជនកម្ពុជា។

107. បុព្វសិទ្ធិ ឬអភ័យឯកសិទ្ធិដែលផ្តល់ជូនដល់សមាជិកសភានៅកម្ពុជា អាចត្រូវបានយកមកប្រើប្រាស់ដើម្បីគ្រាន់តែរារាំងការអនុវត្តដីការបស់តុលាការដែលកោះហៅមកធ្វើសក្ខីកម្មប៉ុណ្ណោះ។ លទ្ធភាពដែលថា នៅពេលមានដីកាកោះពីតុលាការ បុគ្គលទាំងនេះអាចទាមទារប្រើអភ័យឯកសិទ្ធិរបស់ខ្លួន ដើម្បីឱ្យខ្លួនរួចផុតពីការត្រូវចូលខ្លួនមកធ្វើសក្ខីកម្ម មិនអាចលុបកាតព្វកិច្ចរបស់អង្គជំនុំជម្រះក្នុងការស្វែងរកការស្តាប់សក្ខីកម្មរបស់ពួកគាត់បានឡើយ។ អង្គជំនុំជម្រះមានកាតព្វកិច្ចផ្នែកតុលាការក្នុងការស្វែងរកការស្តាប់រាល់សក្ខីកម្មទាំងឡាយណាដែលពាក់ព័ន្ធ និងមានតម្លៃជា

---

[189] សំណើសុំបើកការស៊ើបអង្កេត អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, E82, ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌទី ៣១។ សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម, E93/9, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ ឧបសម្ព័ន៖ សំណើសុំបន្ថែមសាក្សី និង បន្តសវនាការបឋម, E93/9.1, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ ទំព័រទី ក១៣-ក១៥។ សំណើសុំកោះហៅសាក្សី TCW-២២៣ ក្នុងឋានៈជាសាក្សីអត្តចរិត ជំនួស នួន ជា, E236/5/1, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣។ សំណើទី ៦ និងសំណើចុងក្រោយ ស្នើសុំកោះហៅសាក្សី TCW-២២៣, E236/5/1/1, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៣ កថាខណ្ឌទី ១១-១៣។

[190] *សូមមើល* រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (២០១០) មាត្រា ៨០ មាត្រា ១០៤ ថ្មី និង ច្បាប់ស្តីពីលក្ខន្តិកៈរបស់សមាជិកសភា (ក្រមលេខ នស/របក/១០០៦/០២៥) ចូលជាធរមាននៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៦ សភាជាតិ ជំពូក ២, មាត្រា ៤-១៦ និង ច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា (ក្រមលេខ NS/0108/001No) ចូលជាធរមាននៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ ជំពូក ២ មាត្រា ៤-១៦។

ភ័ស្តុតាងពីបុគ្គលគ្រប់រូប មិនចំពោះថាបុគ្គលនោះមានមុខតំណែងផ្លូវការណាមួយនោះឡើយ។ លើសពីនេះទៅទៀត ហើយមុនពេលដែលអភ័យឯកសិទ្ធិនោះអាចរារាំងមិនឱ្យតុលាការស្តាប់ការបង្ហាញភ័ស្តុតាង អភ័យឯកសិទ្ធិត្រូវតែយកមកប្រើប្រាស់ដោយបុគ្គលរូបនោះ ជាជាងថា អង្គជំនុំជម្រះជាអ្នកសន្មតជាមុនអំពីការប្រើប្រាស់អភ័យឯកសិទ្ធិនេះ ។ ទោះបីជាក្នុងអំឡុងពេលកិច្ចស៊ើបសួរដែលបានធ្វើឡើងតាំងពីបួនឆ្នាំមុនក៏ដោយ សាក្សី TCW-២២៣ និងTCW-៤៩៤ មិនបានអនុវត្តតាមការកោះហៅឱ្យមកផ្តល់សក្ខីកម្ម អង្គជំនុំជម្រះពុំមានព័ត៌មានដើម្បីកំណត់ថាបុគ្គលណាមួយក្នុងចំណោមអ្នកដែលអាចក្លាយជាសាក្សីទាំងនេះ បានបញ្ជាក់ដោយផ្ទាល់អំពីបំណងមិនចង់មកផ្តល់សក្ខីកម្មនៅក្នុងតុលាការនោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះក៏មិនមានចេតនាលើកឡើងអំពីអភ័យឯកសិទ្ធិនោះទេ។ ផ្ទុយទៅវិញ សាក្សីសក្តានុពលទាំងនេះមិនទាន់ទាំងបានទទួលការជូនដំណឹងអំពីសំណើសុំពាក់ព័ន្ធនឹងសក្ខីកម្មរបស់ពួកគាត់ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅឡើយទេ។ លើកលែងតែសាក្សីសក្តានុពលដែលបដិសេធមិនព្រមមកផ្តល់សក្ខីកម្ម ទើបយើងពិចារណាលើការប្រើប្រាស់វិធានការចាប់បង្ខំ។ វិធានការបែបនេះកម្រត្រូវបានគេលើកឡើងណាស់ ហើយក៏ត្រូវបានគេអនុវត្តតិចតួចប៉ុណ្ណោះ។ ចំណុចដែលថាបុគ្គលទាំងនេះអាចអនុវត្តអភ័យឯកសិទ្ធិនៅពេលខាងមុខ ដែលអាចឱ្យពួកគាត់រួចពីការធ្វើសក្ខីកម្មមិនពាក់ព័ន្ធ និងមិនច្បាស់លាស់ ទៅនឹងចំណុចដែលថា តើតុលាការគួរ ឬមិនគួរកោះហៅពួកគាត់នោះទេ។

108. ពាក់ព័ន្ធនឹងគោលការណ៍ទាំងនេះ យើងពិចារណាឃើញថា សាក្សី TCW-២២៣ និងសាក្សី TCW-៤៩៤ គប្បីត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្ម។ សាក្សីទាំងពីររូបហាក់ដូចជាដឹងអំពីព័ត៌មានដែលសាក្សីដែលត្រូវបានស្នើសុំផ្សេងទៀតអាចមិនបានដឹងព័ត៌មាននេះ នៅក្នុងសំណុំរឿង ០០២/០១។ សាក្សី TCW-២២៣ ទំនងជាធ្លាប់បានបំពេញមុខងារសំខាន់មួយនៅក្នុងអង្គភាពប្រដាប់អាវុធ ដែលបានដឹកនាំការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ហើយទំនងជាអាចផ្តល់សក្ខីកម្មពិសេស និងពាក់ព័ន្ធទៅនឹងគោលនយោបាយផ្សេងៗក្នុងសម័យនៃរបបកម្ពុជាប្រជាធិបតេយ្យ និងការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងរចនាសម្ព័ន្ធបញ្ជា[191]។ យើង

---

[191] *សូមមើលឧទាហរណ៍* កិច្ចសម្ភាសន៍របស់ ជា ស៊ីម ភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៨៣ និង ហេង សំរិន ភ្នំពេញ ថ្ងៃទី ០២ ធ្នូ ឆ្នាំ ១៩៩១, E3/1568, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ ទំព័រទី ៣១ ("ក្នុងសម័យដែលយើងវាយពួកចក្រពត្តិនិយម និង បរិវាររបស់ពួកវា យើងបានជ័យជម្នះ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ បន្ទាប់ពីការតស៊ូចប់ទៅដោយជ័យជម្នះ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ អង្គភាពខ្លះរបស់ភូមិភាគ ត្រូវបានបញ្ចូលគ្នាធ្វើជាកងពល

យល់ស្របជាមួយនឹងសហការីចៅក្រមជាតិដែលលើកឡើងថា សក្ខីកម្មរបស់សាក្សី TCW-៤៩៤ ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការជ្រៀតជ្រែកខាងនយោបាយ និងតួនាទីរបស់ប្រទេសវៀតណាម គឺមិនមានការពាក់ព័ន្ធនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ យើងចាត់ទុកថា សក្ខីកម្មរបស់គាត់ដែលត្រូវបានស្នើសុំឱ្យស្តាប់ ដែលក្រុមមេធាវីការពារក្តី នួន ជា អះអាងថា ជាមេភូមិភាគដែលបានវាយបកទៅលើកងទ័ពមជ្ឈិមនៅចុងទសវត្សរ៍ឆ្នាំ ១៩៧០ អាចផ្តល់ជាភ័ស្តុតាងដែលមានភាពពាក់ព័ន្ធដោយផ្ទាល់ និងមានតម្លៃជាភ័ស្តុតាងទាក់ទិននឹងសម័យកាលនោះ ក៏ដូចជាលទ្ធភាពផ្តល់ភ័ស្តុតាងអំពីសេចក្តីណែនាំចេញនៅខែ កុម្ភៈ ឆ្នាំ ១៩៧៥ ពាក់ព័ន្ធនឹងផែនការផ្តល់កន្លែងស្នាក់នៅដល់ជនទាំងឡាយដែលត្រូវបានជម្លៀសចេញពីភ្នំពេញ។ ជាសរុបមក ការស្នើសុំស្តាប់សក្ខីកម្មសាក្សី TCW-២២៣ និងTCW-៤៩៤ គឺពិតជាជាប់ពាក់ព័ន្ធជាចម្បង និងអាចជួយអង្គជំនុំជម្រះបញ្ជាក់ការពិត។ យើងពិចារណាឃើញថា វាមិនសមស្របដែលត្រូវគិតគូឆ្ងាយពីនេះទៀតថែមទៀតនោះទេ ហើយក៏មិនគួរពង្រីកការវិភាគព័ត៌មានលម្អិតរបស់ពួកគាត់ ដែលមាននៅក្នុងបទសម្ភាសន៍កាលពីពេលមុននោះដែរ។ ជាការពិត អង្គជំនុំជម្រះមិនបានធ្វើការវិភាគលម្អិតបែបនេះនៅក្នុងការពិចារណាអំពីភាពចាំបាច់ដើម្បីកោះហៅសាក្សីផ្សេងទៀតដែលស្នើសុំនោះទេ។

109. អង្គជំនុំជម្រះសាលាដំបូងត្រូវតែឱ្យគេមើលឃើញថាបានប្រព្រឹត្តស្មើភាពគ្នា ដោយគ្មានការភ័យខ្លាច និងគ្មានបុព្វសិទ្ធិចំពោះបុគ្គលទាំងអស់ដែលសក្ខីកម្មរបស់ពួកគាត់ត្រូវបានចាត់ទុកថាសំខាន់ដើម្បីបញ្ជាក់ការពិត ឬជួយស្វែងរកយុត្តិធម៌។ សាក្សី និងអ្នកជំនាញជាច្រើន បានអនុវត្តដីកាកោះដោយគ្មានការស្នាក់ស្ទើរ អ្នកផ្សេងជាច្រើនទៀតបានធ្វើដំណើរពីទីឆ្ងាយដើម្បីមកតុលាការ ហើយដែលអ្នកទាំងនោះមានតួនាទីផ្គត់ផ្គង់ខ្លួនឯង និងគ្រួសាររបស់ពួកគេ។ សាក្សី TCW-២២៣ និង TCW-៤៩៤ មិនទាន់ត្រូវបានកោះហៅនៅឡើយ ហើយក៏មិនទាន់បានបញ្ជាក់ថា ការទទួលខុសត្រូវរបស់ពួកគេមានតម្លៃធំធេងបំផុតដែលមិនអាចឱ្យពួកគេគោរពតាមដីកាកោះរបស់អង្គជំនុំជម្រះបាន។ ពួកគេអាចមានចេតនាចូលរួមជួយដល់ផលប្រយោជន៍នៃយុត្តិធម៌ដែលត្រូវបានទន្ទឹងរង់ចាំជាយូរមកហើយ។ ការជំនុំជម្រះនៅ អ.វ.ត.ក មានគោលបំណងផ្សព្វផ្សាយការផ្សះផ្សាជាតិលើកតួនាទីក្នុងការបម្រើដល់យុត្តិធម៌ដែលមន្ត្រីជាតិកម្ពុជា ត្រូវបានសន្មតថាអនុវត្តមិនខុសគ្នាផង

---

មជ្ឈិម។ មានកងពលចំនួនពីរ។ កងពលរបស់ខ្ញុំ គឺជាកងពលទីមួយ ដែលវាយក្រុងភ្នំពេញ និង ក្រោយមក កងពលទីពីរបានប្តូរទៅជាកងពលទី ២៩០ វិញ [...]")។

ដែរ។ ផ្អែកតាមសំអាងហេតុទាំងនេះ យើងយល់ឃើញថា បុគ្គលទាំងពីររូបនេះគួរត្រូវបានកោះហៅដើម្បីស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១[192]។

110. លើសពីនេះទៀត យើងមិនយល់ស្របទេថា កិច្ចដំណើរការជំនុំជម្រះដោយឆាប់រហ័សគួរត្រូវបានយកមកប្រើប្រាស់ ដើម្បីធ្វើយុត្តិកម្មក្នុងការមិនកោះហៅសាក្សីដែលមានសារសំខាន់ចំពោះរឿងក្តីនេះ។ ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចនៅក្បែរចុងបញ្ចប់នៃការស៊ើបអង្កេត ដែលការកោះហៅបុគ្គលទាំងនេះអាចនាំឱ្យពន្យារពេលនៃការបញ្ចប់កិច្ចស៊ើបសួរ ក៏អង្គជំនុំជម្រះសាលាដំបូងអាចចេញដីកាកោះតាំងពីដំបូងនៃដំណាក់កាលការជំនុំជម្រះក្តី ប្រសិនបើអង្គជំនុំជម្រះមានសម្លេងភាគច្រើនដាច់ខាតលើចំណុចនេះ។ បើតាមទស្សនៈរបស់យើង អង្គជំនុំជម្រះគួរចេញដីកាកោះ និងកំណត់អំពីចេតនានៃសាក្សីទាំងនេះក្នុងការផ្តល់សក្ខីកម្ម។ បញ្ហានៃអភ័យឯកសិទ្ធិសភាអាចនឹងត្រូវបានដោះស្រាយ ប្រសិនបើមានការលើកឡើង។ ការពន្យារពេលមិនត្រឹមត្រូវ គឺមិនមែនជាការសន្និដ្ឋានសមស្របនោះទេ។ យើងក៏មិនអាចទទួលយកទឡ្ហីករណ៍ដែលថា ការស្នើសុំឱ្យកោះហៅសាក្សីសក្តានុពលទាំងនេះ អាចត្រូវបានបកស្រាយថាជាយុទ្ធសាស្ត្រនៃការជំនុំជម្រះក្តីដែរ។ យើងមិនយល់ស្របជាមួយចៅក្រមជាតិលើចំណុចនេះទេ ហើយយើងត្រូវកោះហៅសាក្សី TCW-២២៣ និង TCW-៤៩៤ ដើម្បីឱ្យមកផ្តល់សក្ខីកម្ម។

111. យើងទទួលស្គាល់ថា សាក្សីមួយចំនួនមិនអាចត្រូវបានកោះហៅ ដោយសារតែការខ្វែងគំនិតគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ ជាចុងក្រោយ អង្គជំនុំជម្រះបានកោះហៅសាក្សីចំនួន ២០ នាក់ ដែលត្រូវបានស្នើសុំឱ្យកោះហៅដោយមេធាវីការពារក្តី នួន ជា និង ២៣ នាក់ ដែលត្រូវបានស្នើសុំឱ្យកោះហៅដោយមេធាវីការពារក្តី ខៀវ សំផន និងបានពិចារណាលើភស្តុតាងជាឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ ដែលត្រូវបានយកមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ឯកសារតែមួយចំនួនតូចប៉ុណ្ណោះត្រូវបានបដិសេធចោល ដោយសារតែការដាក់មិនបានទាន់ពេលវេលា។ យើងយល់ឃើញយ៉ាងច្បាស់ថា ប្រសិនបើមានបណ្តឹងឧទ្ធរណ៍ បញ្ហានេះអាចនឹងត្រូវបានដោះស្រាយ ដោយសារតែអង្គជំនុំជម្រះតុលាការកំពូល មានអំណាចកោះហៅសាក្សី និងទទួលខុសត្រូវក្នុងការកំណត់

[192] សំណើសុំបន្ថែមសាក្សី និង បន្តសវនាការបឋម, E93/9, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ ឧបសម្ព័ន្ធ៖ សំណើសុំបន្ថែមសាក្សី និង បន្តសវនាការបឋម, E93/9.1, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ ទំព័រទី ក២៩-ក៣០។

ចុងក្រោយ អំពីផលប៉ះពាល់ណាមួយដែលកើតចេញពីការខកខានមិនបានកោះហៅសាក្សី[193]។ ដោយពិចារណាទៅលើលទ្ធផលនេះ យើងមិនបញ្ចេញមតិយោបល់អំពីបញ្ហានៃភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីក្នុងការជំនុំជម្រះ ដែលសហសេវិកជាតិរបស់យើងលើកឡើងនោះទេ។

### ៣.២.៩ សាក្សីដែលបានស្នើសុំឱ្យកោះហៅពាក់ព័ន្ធនឹងអត្តចរិតរបស់ជនជាប់ចោទ

112. ទីបំផុត អង្គជំនុំជម្រះសាលាដំបូងបានកំណត់ចំនួនថ្ងៃសម្រាប់ធ្វើសវនាការ ដើម្បីអាចឱ្យជនជាប់ចោទបង្ហាញភ័ស្តុតាងពាក់ព័ន្ធនឹងអត្តចរិតរបស់ពួកគាត់[194]។ ដូចគ្នាទៅនឹងករណីដែលពាក់ព័ន្ធទៅនឹងសក្ខីកម្មស្តីពីព្យសនកម្មដែលជនរងគ្រោះបានទទួលរងដែរ និងក្នុងខណៈដែលអង្គជំនុំជម្រះកំពុងកំណត់ចំនួនម៉ោងជាក់លាក់ សម្រាប់ការបង្ហាញភ័ស្តុតាងដែលភាគីបានស្នើសុំ អង្គជំនុំជម្រះមិនបានដាក់កម្រិតទៅលើឆន្ទានុសិទ្ធិរបស់ភាគីដែលពាក់ព័ន្ធណាមួយ ក្នុងការសម្រេចចង់ស្នើឱ្យពិនិត្យភ័ស្តុតាងដែលពាក់ព័ន្ធបំផុតក្នុងដំណាក់កាលនៃការជំនុំជម្រះក្តីនេះឡើយ[195]។

113. ក្រុមមេធាវីការពារក្តី ខៀវ សំផន ស្នើសុំកោះហៅបុគ្គលមួយចំនួនដូចខាងក្រោម ពាក់ព័ន្ធទៅនឹងអត្តចរិតរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់សាក្សីទាំងអស់នេះរួចហើយនៅចំពោះមុខអង្គជំនុំជម្រះ។

---

[193] *សូមមើល* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ មាត្រា១៤(៣)(ង)។ *សូមមើលផងដែរ* វិធាន ១០៤(១)នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Bagosora *និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះតុលាការកំពូល ICTR (ICTR-98-41-A) សាលក្រម ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ កថាខណ្ឌ ៥៣៧, ៥៤៦ (ទោះបីជាអង្គជំនុំជម្រះសាលាដំបូង រំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការខកខានមិនបានអនុវត្តដីកាកោះដែលបានចេញឱ្យកោះហៅរដ្ឋមន្ត្រីក្រសួងការពារជាតិរវ៉ាន់ដាឈ្មោះ Gatsinzi ដែលជនជាប់ចោទបានស្នើសុំនោះ ដូចនេះ ការខូចប្រយោជន៍ដល់ជនជាប់ចោទត្រូវបានជួសជុលដោយសារតែចុងក្រោយ សាក្សីរូបនេះ ត្រូវបានស្តាប់សក្ខីកម្ម នៅសវនាការតុលាការកំពូល។

[194] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "ព័ត៌មានបន្ថែមស្តីពីការកំណត់កាលបរិច្ឆេទសវនាការ", E236/5, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[195] ប៉ុន្តែ *សូមមើល* ដីកាបង្គាប់ឱ្យស្តាប់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ សក្ខីកម្មសាក្សីអត្តចរិតរបស់ ខៀវ សំផន សាក្សី TCW-២៧៧ និងសាក្សី TCW-៨៤, E236/5/4, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៣ (តម្រូវឱ្យស្តាប់សក្ខីកម្មរបស់សាក្សី TCW-២៧៧ និង TCW-៨៤ តាមរយៈប្រព័ន្ធសោតទស្សន៍ ដើម្បីជាប្រយោជន៍ដល់ការសន្សំសំចៃរបស់តុលាការ)។

- សាក្សី TCW-២២៧ Philippe JULLIAN-GAUFRES;
- សាក្សី TCW-៨៤ ចៅ សុខុន
- សាក្សី TCW-៦៧៣ សូ សុជាតិ
- សាក្សី TCW-៧៤២ ទន់ សឿន
- សាក្សី TCW-៦៦៥ សុខ រឿ

114. ក្រុមមេធាវីការពារក្តី នួន ជា ស្នើសុំស្តាប់សក្ខីកម្មតែសាក្សីមួយរូបប៉ុណ្ណោះ គឺសាក្សី TCW-២២៣[196] ពាក់ព័ន្ធនឹងអត្តចរិតរបស់ជនជាប់ចោទ។ ដោយសារតែអង្គជំនុំជម្រះពុំមានលទ្ធភាពកោះហៅសាក្សី TCW-២២៣ ដូចបានបញ្ជាក់ជូនលម្អិតខាងលើ អង្គជំនុំជម្រះមិនអាចស្តាប់សក្ខីកម្មសាក្សី TCW-២២៣ នៅចំពោះមុខអង្គជំនុំជម្រះទេ។ ហេតុដូច្នេះ សាក្សីរូបនេះមិនអាចផ្តល់សក្ខីកម្មឱ្យជនជាប់ចោទពាក់ព័ន្ធនឹងការជំនុំជម្រះក្តីនៅវគ្គនេះបានឡើយ។

115. អង្គជំនុំជម្រះសាលាដំបូង មិនអាចរកបានការឯកភាពគ្នាជាឯកច្ឆ័ន្ទទាក់ទងទៅនឹងសាក្សី TCW-២២៣ ដែលត្រូវបានស្នើសុំឱ្យកោះហៅឱ្យមកបញ្ជាក់អំពីអត្តចរិតរបស់ នួន ជា ទេ។ ហេតុដូច្នេះ យើងមានមតិយោបល់ដាច់ដោយឡែកពីគ្នាចំនួនពីរដូចតទៅនេះ។

<u>**មតិយោបល់របស់ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន និងចៅក្រម យូរ ឧត្តរា**</u>

116. យើងលើកឡើងសាជាថ្មីអំពីមតិយោបល់របស់យើងដូចបានលើកឡើងខាងលើ ទាក់ទិននឹងសំណើសុំឱ្យកោះហៅសាក្សី TCW-២២៣។ ទោះបីជាយ៉ាងណាក៏ដោយ ទាក់ទិននឹងសំណើដែលសាក្សី TCW-២២៣ ត្រូវបានកោះហៅក្នុងនាមជាសាក្សីអត្តចរិត យើងកត់សម្គាល់បន្ថែមថាភស្តុតាងដែលបានស្នើសុំជាច្រើន គឺទាក់ទងនឹងអាកប្បកិរិយាល្អរបស់ជនជាប់ចោទ ដែលទាក់ទងនឹងហេតុការណ៍នានា មុនពេលដែលអំពើរបស់ជនជាប់ចោទត្រូវបានចោទប្រកាន់[197]។ ទោះបីជា

---

[196] សំណើសុំកោះហៅសាក្សី TCW-២២៣ ធ្វើជាសាក្សីអត្តចរិត ជំនួសមុខឱ្យ នួន ជា, E236/5/1, ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៣។

[197] សំណើសុំកោះហៅសាក្សី TCW-២២៣ ដែលពាក់ព័ន្ធនឹងអត្តចរិត ជំនួសមុខឱ្យ នួន ជា, E236/5/1, ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ៣ និង៤។

យ៉ាងណាក៏ដោយ ភ័ស្តុតាងនៃអត្តចរិតល្អរបស់ជនជាប់ចោទមុនព្រឹត្តិការណ៍ដែលត្រូវបានចោទប្រកាន់ គឺមិនពាក់ព័ន្ធទាល់តែសោះ។ នៅក្នុងរឿងក្តី *Kuprsekić* អង្គជំនុំជម្រះបានសម្រេចថា៖

> "i) និយាយជាទូទៅ ភ័ស្តុតាងនៃអត្តចរិតរបស់ជនជាប់ចោទមុនពេលព្រឹត្តិការណ៍ដែលគាត់ត្រូវបានចោទប្រកាន់នៅចំពោះមុខតុលាការអន្តរជាតិ គឺមិនមែនជាបញ្ហាពាក់ព័ន្ធនោះទេ ដោយសារតែ៖
>
> ក) ផ្អែកតាមប្រភេទនៃបទឧក្រិដ្ឋ ដែលត្រូវបានប្រព្រឹត្តនៅក្នុងបរិបទនៃអំពើហិង្សាមានលក្ខណៈជាទូទៅ និងក្នុងអំឡុងភាពអាសន្នជាតិ និងអន្តរជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចត្រូវបានប្រព្រឹត្តដោយជនទាំងឡាយណាដែលមិនដែលត្រូវបានផ្តន្ទាទោសពីមុនមក ឬមិនមានប្រវត្តិបង្កអំពើហិង្សាពីមុន ហើយជាបច្ច័យភ័ស្តុតាងនៃអំពើល្អ ឬអំពើអាក្រក់របស់ជនជាប់ចោទ មុនពេលមានជម្លោះប្រដាប់អាវុធចាប់ផ្តើម គឺកម្រមានតម្លៃជាភ័ស្តុតាងនៅចំពោះមុខតុលាការអន្តរជាតិណាស់ ហើយនិង
>
> ខ) ផ្អែកតាមគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ ភ័ស្តុតាងអត្តចរិតរបស់ជនជាប់-ចោទជាទូទៅ មិនអាចទទួលយកដើម្បីបង្ហាញអំពីឧបនិស្ស័យរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តិដូចគ្នានឹងភ័ស្តុតាងអត្តចរិតនោះទេ"[198]។

117. មេធាវីការពារក្តី នួន ជា បានលើកឡើងថា ទំនាក់ទំនងការងាររបស់សាក្សី TCW-២២៣ ជាមួយនឹង នួន ជា បានបន្តជាប់ "ដូចមានក្នុងកំណត់ត្រានៃកិច្ចសម្ភាសន៍របស់លោក Ben Kiernan ដែលសាក្សី TCW-២២៣ បានចូលរួមប្រជុំកាលពីថ្ងៃទី ២០ ខែឧសភា ឆ្នាំ ១៩៧៥

---

[198] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Kupreskić និងអ្នកផ្សេងទៀត* សេចក្តីសម្រេចលើភ័ស្តុតាងអត្តចរិតល្អរបស់ជនជាប់-ចោទ និងមេធាវីការពារក្តី Tu Quoque ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ១៩៩៩។ សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Bagilishema* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (ICTR-95-1A-A), សាលដីកា កថាខណ្ឌ ១០៥។ រឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Stakić,* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (IT-97-24-A) សាលដីកា កថាខណ្ឌ ៤០៦ និងរឿងក្តី រដ្ឋអាជ្ញា ទល់នឹង *Blagojević* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-02-60) សាលក្រម កថាខណ្ឌ ៨៥៣។

ជាមួយ នួន ជា និងអ្នកដទៃទៀត"[199]។ យើងពិនិត្យឃើញថា ការលើកឡើងនេះមិនបានឆ្លុះបញ្ចាំងត្រឹមត្រូវលើខ្លឹមសារនៃកិច្ចសម្ភាសន៍របស់លោក Ben Kiernan ទេ[200]។ យើងមានការចាប់អារម្មណ៍ថា មេធាវីការពារក្តី នួន ជា បានប្រែប្រួលសំណើឱ្យកោះហៅសាក្សី TCW-២២៣ រហូត ជាពិសេស សំណើសុំឱ្យកោះហៅក្នុងខែ កុម្ភៈ ឆ្នាំ ២០១៣ ដែលថា សាក្សី TCW-២២៣ សុំឱ្យកោះហៅឱ្យធ្វើជាសាក្សីអត្តចរិតតែម្នាក់គត់នេះ គឺជាសំណើជាយុទ្ធសាស្ត្រនៃការជំនុំជម្រះ។ យើងមានការបារម្ភថា មេធាវីការពារក្តី នួន ជា លើកសំណើនេះឡើង គឺមានគោលបំណងធ្វើឱ្យមានភាពច្របូកច្របល់ នោះគឺជាការប៉ុនប៉ងឱ្យមានការអនុវត្តវិធានាការចាប់បង្ខំចំពោះសមាជិកសភាកម្ពុជា ជាជាងជាសំណើដែលសមហេតុផល និងដោយសុចរិតដែលថា សក្ខីកម្មបានមកពីសាក្សី TCW-២២៣ នឹងបានជួយ នួន ជា នោះ។

118. យើងពិតជាពិចារណាអំពីលទ្ធភាពដែលថា បញ្ហានៃភាពពាក់ព័ន្ធ អាចត្រូវបានដោះស្រាយដោយឱ្យទម្ងន់ជាភស្តុតាងតិចតួចចំពោះសក្ខីកម្មបែបនេះ។ ប៉ុន្តែ តាមការយល់ឃើញរបស់យើងដែលបានលើកឡើងថា ការកោះហៅសាក្សីនេះទំនងជាអូសបន្លាយកិច្ចដំណើរការនីតិវិធី ហើយការចាប់អារម្មណ៍របស់យើងគឺថា សំណើនេះរបស់មេធាវីការពារក្តី នួន ជា ចំពោះភស្តុតាងអត្តចរិតនេះ គឺជាយុទ្ធសាស្ត្រ ហេតុដូច្នេះ យើងយល់ឃើញថា សំណើសុំនេះត្រូវបដិសេធចោល។ អង្គជំនុំជម្រះមិនគួរបំបែកបទចោទប្រកាន់ដើម្បីធានាការជំនុំជម្រះឱ្យឆាប់រហ័ស ហើយនៅក្នុងពេលជាមួយគ្នានេះ អនុញ្ញាតឱ្យភាគីដាក់ជូននូវភស្តុតាងដែលមិនពាក់ព័ន្ធ នៅដំណាក់កាលយឺតយ៉ាវ ហើយដែលមានទម្ងន់តិចតួច ឬ គ្មានទម្ងន់ជាភស្តុតាងទាល់តែសោះនោះ។ ហេតុដូច្នេះ យើងបដិសេធសំណើនេះ ផ្អែកតាមវិធាន ៨៧(៣)(ក) (ខ) (គ) និង (ង)។

---

[199] សំណើសុំកោះហៅសាក្សី TCW-223 ដែលពាក់ព័ន្ធនឹងអត្តចរិតរបស់ នួន ជា ឯកសារ E236/5/1 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ៥។

[200] កិច្ចសម្ភាសន៍ជាមួយនឹង ជា ស៊ីម ទីក្រុងភ្នំពេញ ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ១៩៨១ និងជាមួយ ហេង សំរិន ទីក្រុងភ្នំពេញ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ១៩៨១ ឯកសារ E3/1568 ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១ ERN 00713952-00713954។ សាក្សី TCW-223 ពិពណ៌នាកិច្ចប្រជុំដូចតទៅនេះ៖ "ប៉ុល ពត និង នួន ជា គឺជាអ្នកដែលបាននិយាយអំពីផែនការនោះ។ មានមនុស្សជាច្រើនដែលបានចូលរួមស្តាប់តំណាងមកពីទូទាំងប្រទេស។ មនុស្សរាប់ពាន់នាក់ពីគ្រប់ស្រុក និងតំបន់ លេខាស្រុក និងលេខាតំបន់មកពីទូទាំងប្រទេស។ និងតំណាងកងទ័ព មកពីគ្រប់អង្គភាព និងភូមិភាគ។ ដូច្នេះ មានមនុស្សរាប់ពាន់នាក់..."

## <u>មតិយោបល់របស់ចៅក្រម Silvia CARTWRIGHT និងចៅក្រម Jean-Marc LAVERGNE</u>

119. យើង ចៅក្រម Silvia CARTWRIGHT និងចៅក្រម Jean-Marc LAVERGNE យល់ឃើញថា ការដែលសាក្សី TCW-២២៣ ជាសាក្សីតែមួយគត់ដែលក្រុមមេធាវីការពារក្ដី នួន ជា បានស្នើសុំ គឺជាហេតុផលបន្ថែមមួយទៀតដែលអង្គជំនុំជម្រះគប្បីកោះហៅគាត់ក្នុងសំណុំរឿង ០០២/០១ នេះ។ ដោយសារអង្គជំនុំជម្រះមិនបានប្រើឆន្ទានុសិទ្ធិហាមឃាត់ជនជាប់ចោទដទៃទៀតក្នុងការកោះហៅបុគ្គលដែលខ្លួនយល់ថាពាក់ព័ន្ធទៅនឹងបញ្ហាអត្តចរិតនេះ ហេតុដូច្នេះទើបយើងគប្បីកោះហៅសាក្សី TCW-២២៣ រូបនេះ។

120. យើងយល់ឃើញទៀតថា ភ័ស្តុតាងអំពីអត្តចរិតរបស់សាក្សី TCW-២២៣ ទំនងជាមានភាពពាក់ព័ន្ធ និងមានតម្លៃជាភ័ស្តុតាង។ យើងយល់ស្របជាមួយនឹងយុត្តិសាស្ត្រអន្តរជាតិ ដែលកម្រកំហិតលទ្ធភាពរបស់ភាគីក្នុងការផ្ដល់ភ័ស្តុតាងអំពីអត្តចរិតនេះ។ ទោះបីជាអង្គជំនុំជម្រះទំនងជាឱ្យតម្លៃតិចតួចទៅលើទម្ងន់ភ័ស្តុតាងដែលបានមកពីបុគ្គលទាំងឡាយដែលពុំសូវស្គាល់ច្បាស់អំពីអត្តចរិតរបស់ជនជាប់ចោទយ៉ាងណាក្ដី ក៏តុលាការមិនអចិន្ត្រៃយ៍ទាំងនោះបានអនុញ្ញាតឱ្យស្ដាប់សក្ខីកម្មអំពីអត្តចរិតទាំងនោះដែរ លើកលែងតែក្នុងករណីដែលចំនួនសាក្សីអត្តចរិតដែលបានស្នើសុំទាំងនោះ មានចំនួនច្រើនពេកប៉ុណ្ណោះ[201]។

---

[201] *ព្រះរាជអាជ្ញា ទល់នឹង* *Kupreškić et al.*, សេចក្ដីសម្រេចលើភ័ស្តុតាងនៃអត្តចរិតល្អរបស់ជនជាប់ចោទ និងមេធាវីការពារក្ដីរបស់ *Tu Quoque*, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (IT-95-16-T), ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៩; *ព្រះរាជអាជ្ញា ទល់នឹង* *Ndindiliyimana et al.*, សេចក្ដីសម្រេចលើសំណើលើកទីពីររបស់ Sagahutu ស្នើសុំផ្ទៀងផ្ទាត់បញ្ជីសាក្សីរបស់គាត់, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (ICTR-00-56-T), ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៨ កថាខណ្ឌទី ១១។

## ៣.៣ មូលដ្ឋានសម្រាប់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ក្នុងការមិនស្តាប់សក្ខីកម្មបុគ្គល ផ្សេងៗទៀតដែលនៅសេសសល់ និងដែលត្រូវបានស្នើសុំស្តាប់សក្ខីកម្មក្នុងដំណាក់កាលនៃសំណុំរឿង ០០២/០១

### ៣.៣.១ សាក្សីដែលត្រូវបានស្នើសុំ ដើម្បីគាំទ្រការចោទប្រកាន់ទូទៅពាក់ព័ន្ធនឹងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឯករាជ្យភាពរបស់តុលាការ អំពើពុករលួយ ឬ ប្រក្រតីភាពនៃការស៊ើបសួរតាមផ្លូវតុលាការនៃសំណុំរឿង ០០២

121. ជាការឆ្លើយតបទៅនឹងការស្នើសុំរបស់អង្គជំនុំជម្រះសាលាដំបូង ឲ្យកំណត់អត្តសញ្ញាណបុគ្គលទាំងឡាយ ដែលខ្លួនចាត់ទុកថាមានសារៈសំខាន់ក្នុងការកោះហៅឲ្យមកផ្តល់សក្ខីកម្មដើម្បីដោះបន្ទុកទៅនឹងការចោទប្រកាន់លើជនជាប់ចោទ ក្រុមមេធាវីការពារក្តី នួន ជា បែជាស្នើសុំឲ្យស្តាប់សក្ខីកម្មបុគ្គលជាច្រើនរូប ដើម្បីគាំទ្រដល់ការចោទប្រកាន់ជាទូទៅពាក់ព័ន្ធទៅនឹងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ឯករាជ្យភាពរបស់ប្រព័ន្ធតុលាការកម្ពុជា ការចោទប្រកាន់ថាមានអំពើពុករលួយ ឬប្រក្រតីភាពនៃដំណើរការ និងកិច្ចស៊ើបសួរតាមផ្លូវតុលាការក្នុងសំណុំរឿង ០០២ ទៅវិញ[202]។ ក្នុងចំណោមបុគ្គលដែលបានស្នើសុំទាំងអស់នេះ ពុំមានបុគ្គលណាមួយអាចយកទៅដោះបន្ទុកប្រឆាំងនឹងការការចោទប្រកាន់ណាមួយមកលើជនជាប់ចោទ ឬពុំមានបុគ្គលណាមួយដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលជាចំណុចវិវាទនៅក្នុងសំណុំរឿង ០០២/០១ នេះឡើយ។

122. ក្រុមមេធាវីការពារក្តី នួន ជា បានស្នើសុំឲ្យកោះហៅមន្ត្រីបច្ចុប្បន្ន និងអតីតមន្ត្រីមួយចំនួនដែលធ្វើការនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីពិនិត្យមើល "ដំណើការ និងសមត្ថកិច្ច" នៃការស៊ើបសួរក្នុងសំណុំរឿង ០០២[203]។ វិការៈនៃនីតិវិធីដែលត្រូវបានចោទប្រកាន់នានា ក្នុង

---

[202] បុគ្គលទាំងឡាយដែលភាគីបានស្នើសុំឲ្យស្តាប់សក្ខីកម្មនៅក្នុងពេលជំនុំជម្រះក្តី ដែលក្នុងពេល ឬ បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការភ្លាម ត្រូវបានជូនដំណឹងដោយមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង, E236, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ កថាខណ្ឌទី ៥ (បានកំណត់បុគ្គលចំនួន ៤៦ នាក់ ថាពាក់ព័ន្ធទៅនឹងការចោទប្រកាន់ទូទៅ)។

[203] ឧបសម្ព័ន្ធ ឃ៖ សេចក្តីសង្ខេបអំពីសាក្សីពាក់ព័ន្ធនឹងចំណុចក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្រុមមេធាវីការពារក្តី នួន ជា, E9/10.1, ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១។ ឧបសម្ព័ន្ធ ៣៖ សម្ភារៈសម្រាប់ត្រៀមរៀបចំកិច្ចដំណើរការនីតិវិធីបញ្ជីបឋម៖ សេចក្តីសង្ខេបអំពីសាក្សី ក្រុមមេធាវីការពារក្តី នួន ជា, E93/4.3, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១ និង

អំឡុងពេលនៃដំណាក់កាលស៊ើបសួរត្រូវតែយកមកតទល់គ្នានៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ក្នុងដំណាក់កាលមុនអង្គសេចក្តី ប្រសិនបើចាំបាច់ គឺត្រូវធ្វើតាមរយៈបណ្តឹងឧទ្ធរណ៍ទៅកាន់អង្គបុរេជំនុំជម្រះ។ ភាគីក្នុងសំណុំរឿង ០០២ សុទ្ធតែបានអនុវត្តសិទ្ធិចូលរួមយ៉ាងពេញលេញ នៅក្នុងអំឡុងពេលនៃការស៊ើបសួរតាមផ្លូវតុលាការ ដែលបានប្រើប្រាស់រយៈពេលយ៉ាងវែងនៅក្នុងសំណុំរឿង ០០២ នេះ។ បើទោះបីជានៅក្នុងក្របខណ្ឌច្បាប់របស់ អ.វ.ត.ក មិនបានអនុញ្ញាតឱ្យលើកអំពីវិការៈនៃកិច្ចស៊ើបសួរបែបនេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានយ៉ាងណាក្តី ក៏អង្គជំនុំជម្រះបានអនុញ្ញាតឱ្យភាគី នៅពេលជំនុំជម្រះ លើកឡើងអំពីភាពមិនប្រក្រតីនៃការធ្វើសម្ភាសន៍ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែលបញ្ហានេះអាចប៉ះពាល់ជាក់ស្តែងដល់ការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌[204]។ ហេតុដូច្នេះ អង្គជំនុំជម្រះពិចារណាឃើញថា ដើម្បីជាប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះមិនចាំបាច់ស្តាប់សក្ខីកម្មរបស់បុគ្គលទាំងឡាយដែលក្រុមមេធាវីការពារក្តី នួន ជា បានស្នើសុំទាំងនេះទេ ពាក់ព័ន្ធទៅនឹងកិច្ចស៊ើបសួរតាមផ្លូវតុលាការក្នុងសំណុំរឿង ០០២ នេះ[205]។

123. ក្រុមមេធាវីការពារក្តី នួន ជា បានស្នើសុំកោះហៅបុគ្គលចំនួនបីរូបផងដែរ ពាក់ព័ន្ធនឹងការចរចាដែលឈានទៅរកការបង្កើត អ.វ.ត.ក នេះឡើង[206]។ ការចោទប្រកាន់បែបនេះ គឺស្ថិតនៅក្រៅវង្វង់នៃវិសាលភាពត្រួតពិនិត្យរបស់អង្គជំនុំជម្រះសាលាដំបូងផងដែរ។ ក្រុមមេធាវីការពារក្តីថែមទាំងបានស្នើសុំស្តាប់សក្ខីកម្មរបស់បុគ្គលិកនៃការិយាល័យសហព្រះរាជអាជ្ញា ដើម្បីស្វែងយល់

---

សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម, E93/9, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ ។ ឧបសម្ព័ន្ធ៖ សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម, E93/9.1, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១។

[204] *សូមមើល* វិធាន ៤៨ និង ៧៦ នៃវិធានផ្ទៃក្នុង និងសេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតីដែលត្រូវបានចោទប្រកាន់ថាបានកើតឡើងក្នុងពេលស៊ើបអង្កេតតាមផ្លូវតុលាការ (E221, E223, E224, E224/2, E234, E234/2, E241 និង E241/1), E251, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២។

[205] មានជាអាទិ៍ សាក្សី TCW-៦១, សាក្សី TCW-៧៣១, សាក្សីTCW-៧៣៦, សាក្សីTCW-៧៩២, សាក្សីTCW-២០៦, សាក្សីTCW-៣០១, សាក្សីTCW-៥៥៨, សាក្សី TCW-៥១១, Laurent Kasper-Ansermet, សាក្សីTCW-២៥, សាក្សី TCW-២៧៤, សាក្សីTCW-៥៧៥, អ្នកជំនាញ TCE-១, អ្នកជំនាញ TCE-១៩, អ្នកជំនាញ TCE-៣៩, សាក្សីTCW-៣១ និង សាក្សីTCW-៣៨៣; *សូមមើលផងដែរ, Deuxième demande visant à faire verser aux débats des extraits du livre de M. Marcel LEMONDE*, E280/2, ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣។

[206] មានជាអាទិ៍ សាក្សី TCW-២១២, សាក្សីTCW-៧ និង សាក្សី TCW-៦៥៨

អំពីមូលដ្ឋានក្នុងការជ្រើសរើសចំនួនជនសង្ស័យដើម្បីស៊ើបសួរ[207]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់យ៉ាងច្បាស់ថា ការសម្រេចអំពីបុគ្គលរូបណាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងនរណាត្រូវស៊ើបសួរដោយសហចៅក្រមស៊ើបអង្កេតគឺជាបញ្ហាគោលនយោបាយដែលត្រូវសម្រេចជាចម្បងដោយសហព្រះរាជអាជ្ញា។ ដូច្នេះ គ្មានមូលដ្ឋានណាមួយដើម្បីយកមកធ្វើជាសំអាងនៅក្នុងការកោះហៅសាក្សីទាំងនេះ ដើម្បីឱ្យមកធ្វើសក្ខីកម្មនៅក្នុងពេលជំនុំជម្រះក្តី ក្នុងសំណុំរឿង ០០២/០១ នេះ នោះឡើយ[208]។

124. ទីបញ្ចប់ ក្រុមមេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យស្តាប់សក្ខីកម្មអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា ២ នាក់ ចំពោះការចោទប្រកាន់ថា ពួកគាត់មានតួនាទីក្នុងការទប់ស្កាត់មិនឱ្យមន្ត្រីកម្ពុជាចំនួន ៦ នាក់ មកធ្វើការឆ្លើយតបទៅនឹងដីកាកោះរបស់សហចៅក្រមស៊ើបអង្កេត[209]។ សំណើនេះពុំបានចោទប្រកាន់ថាការប្រព្រឹត្តិបែបនេះនាំឱ្យមានការជ្រៀតជ្រែកដល់រដ្ឋបាលតុលាការ ដែលអាចផ្តន្ទាទោសបានស្របតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងនោះឡើយ ហើយភស្តុតាងដែលត្រូវបានស្នើសុំនោះ មិនមានភាពពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ នោះទេ។ បញ្ហាទាំងអស់នេះ រួមទាំងបញ្ហាជាច្រើនផ្សេងទៀតផងដែលពាក់ព័ន្ធនឹងការស្នើសុំភស្តុតាងបន្ថែមនេះ ពីមុនមកធ្លាប់ត្រូវបានលើកឡើង និងសម្រេចរួចហើយនៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងដំណាក់កាលជំនុំជម្រះក្តី និងមានករណីជាច្រើនទៀត ដែលបញ្ហានេះ ត្រូវបានប្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលផងដែរ[210]។ យោងតាមមូលហេតុទាំងអស់នេះ អង្គជំនុំជម្រះយល់ឃើញថា សក្ខីកម្មពី

---

[207] មានជាអាទិ៍ សាក្សី TCW-៨៦ និង សាក្សី TCW-៥១៣

[208] *កាំង ហ្គេកអ៊ាវ ហៅ ឌុច*, សាលដីកាបណ្តឹងសាទុក្ខ, សំណុំរឿងលេខ 001/18-07-2007/ECCC/SC, F28, ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌទី ៧៩-៨០។

[209] មានជាអាទិ៍ សាក្សី TCW-៣១៧ និង សាក្សី TCW-៥២៤

[210] *សូមមើលឧទាហរណ៍* សេចក្តីសម្រេចលើពាក្យសុំប្តឹងជំទាស់ចៅក្រម Silvia CARTWRIGHT, E171/2, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១២ និង សេចក្តីសម្រេចលើបណ្តឹងជំទាស់លើចៅក្រម Silvia CARTWRIGHT, E137/5, ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១។ សេចក្តីសម្រេចលើពាក្យរបស់ អៀង ធីរិទ្ធ និង អៀង សារី សុំប្តឹងជំទាស់ចៅក្រម យូរ ឧត្តរា ចេញពីអង្គចៅក្រមពិសេស និង សំណើសុំឱ្យមានសវនាការសាធារណៈ, E63/5, ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១១។ សេចក្តីសម្រេចលើពាក្យសុំចំណាត់ការបន្ទាន់ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, E189/3, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២។ សេចក្តីសម្រេចលើពាក្យរបស់ អៀង សារី សុំប្តឹងជំទាស់ចៅក្រម និល ណុន និងសំណើពាក់ព័ន្ធ, E5/3, ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់

បុគ្គលណាមួយក្នុងចំណោមបុគ្គលខាងក្រោមនេះ ពុំមានភាពពាក់ព័ន្ធ ឬមិនចាំបាច់ស្តាប់ក្នុងសំណុំរឿង ០០២/០១ នេះទេ ដ្បិតក្រុមមេធាវីការពារក្តី នួន ជា ពុំបានបំពេញទៅតាមលក្ខខណ្ឌអប្បបរមា ស្តីអំពីភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់អ្នកទាំងនោះ (វិធាន៨៧(៣) (ក) នៃវិធានផ្ទៃក្នុង)៖

- សាក្សី TCW-១០៨ អ៊ុត ឈន
- សាក្សី TCW-៥៦៨ Knut ROSANDHAUG
- សាក្សី TCW-៥៧ Patricia O'BRIEN
- សាក្សី TCW-៥៨ Joel BRINKLEY
- សាក្សី TCW-៦១ Bernard BRUN
- សាក្សី TCW-៧៣១ David TOLBERT
- សាក្សី TCW-៧០៤ Peter TAKSOE-JENSEN
- សាក្សី TCW-៧៣៦ Ignacio TREDICI
- សាក្សី TCW-៧៩២ YOU Bunleng
- សាក្សី TCW-២០៦ Yash GHAI
- សាក្សី TCW-៣០ Cat BARTON
- អ្នកជំនាញ TCE-៤២ Elizabeth F. LOFTUS
- អ្នកជំនាញ TCE-៧៨ YSA Osman
- អ្នកជំនាញ TCE-៧៧ Jeffrey N. YOUNGGREN
- សាក្សី TCW-៥៥៨ Jean REYNAUD
- សាក្សី TCW-២១២ Thomas HAMMARBERG
- សាក្សី TCW-៧ Brad ADAMS
- សាក្សី TCW-៥៤១ ប្រាក់ គឹមសាន
- សាក្សី TCW-៥៣៣ Amanda PIKE

---

អង្គជំនុំជម្រះសាលាដំបូងចំពោះពាក្យសុំចំណាត់ការភ្លាមៗ យោងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, E176/2/1/4, ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២។ សេចក្តីសម្រេចលើ "បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីពាក្យសុំចំណាត់ការភ្លាមៗ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង" របស់ នួន ជា, E189/3/1/8, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣។

- សាក្សី TCW-៥៣០ Margot PICKEN
- សាក្សី TCW-៨៦ ជា លាង
- សាក្សីថ្មី Laurent KASPER-ANSERMET
- សាក្សី TCW-២៥ Anna AUSTIN
- សាក្សី TCW-២៧៤ Helen JARVIS
- សាក្សី TCW-៣១ Wayne BASTIN
- សាក្សី TCW-៣៨៣ Marcel LEMONDE
- សាក្សី TCW-៥១៣ Robert PETIT
- សាក្សី TCW-៥៧៥ Heather RYAN
- សាក្សី TCW-៦៣០ ស៊ាន វិសុទ្ធ
- អ្នកជំនាញ TCE-១ Carl ASK
- អ្នកជំនាញ TCE-១៩ Keith A. FINDLAY
- អ្នកជំនាញ TCE-៣៩ Petrus Johannes van KOPPEN
- សាក្សី TCW-៥១១ Christophe PESCHOUX
- សាក្សី TCW-១៣២ Hans CORELL
- សាក្សី TCW-២៤៨ ហ៊ុន សែន
- សាក្សី TCW-២៩២ គាត ឈន់
- សាក្សី TCW-២៤៣ ហោ ណាំហុង
- សាក្សី TCW-៣១៧ ខៀវ កញ្ញារិទ្ធិ
- សាក្សី TCW-៦៥៨ សុខ អាន
- សាក្សី TCW-៣៥៣ គង់ សំអុល
- សាក្សី TCW-៥២៤ ផៃ ស៊ីផាន
- សាក្សី TCW-៦៤៩ ស៊ឹម កា
- សាក្សី TCW-៤៩៤ អ៊ុក ប៊ុនឈឿន។

125. បើទោះបីជា អង្គជំនុំជម្រះសម្រេចមិនស្តាប់សក្ខីកម្មអ្នកជំនាញ TCE-៧៨ និងសាក្សី TCW-៦៤៩ ដើម្បីគាំទ្រការចោទប្រកាន់ទូទៅទាំងអស់នេះក្តី ក៏អង្គជំនុំជម្រះទទួលស្គាល់ជំនាញឯកទេសរបស់សាក្សីទីមួយពាក់ព័ន្ធនឹងចំនួនជនជាតិខ្មែរ-អ៊ីស្លាម និងជំនាញឯកទេសសាក្សីទីពីរពាក់ព័ន្ធនឹងអត្ថិភាពនៃជម្លោះប្រដាប់អាវុធផងដែរ។ សាក្សី TCW-៦៤៩ ទំនងជាបានដឹងពាក់ព័ន្ធនឹងការចូលលុកលុយរបស់ពួកខ្មែរក្រហមទៅក្នុងទឹកដីវៀតណាម នៅខែ មករា ឆ្នាំ ១៩៧៧ ដែរ[211]។ ទោះបីជា ភ័ស្តុតាងនេះ មិនពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០១ យ៉ាងណាក្តី ក៏គេអាចរង់ចាំស្តាប់នៅក្នុងការជំនុំជម្រះក្តីទៅថ្ងៃអនាគតក្នុងសំណុំរឿង ០០២។

126. បើទោះបីជាអង្គជំនុំជម្រះយល់ស្របគ្នាថា មិនចាំបាច់ស្តាប់សក្ខីកម្មរបស់សាក្សី TCW-៤៩៤ ពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងអស់យ៉ាងណាក្តី ក៏អង្គជំនុំជម្រះមិនអាចយល់ស្របគ្នាបានលើចំណុចថាតើគួរ ឬមិនគួរស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំ និង/ឬ តួនាទីរបស់ជនជាប់ចោទ និងគោលនយោបាយ និងរចនាសម្ព័ន្ធនៃកម្ពុជាប្រជាធិបតេយ្យ (ផ្នែកទី ៣.២.៨)។

---

[211] *សូមមើលឧទាហរណ៍* ប្រតិចារិកនៃកំណត់ហេតុនៃកិច្ចសម្ភាសន៍ជាមួយ ស៊ីម កា និង ជា ស៊ីម នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩០, D210/6, ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៩ ទំព័រទី ១២ (កិច្ចសម្ភាសន៍ឆ្នាំ ១៩៩០ របស់ ស៊ីម កា ដោយ Steven HEDER, ដែលក្នុងនោះ ស៊ីម កា ពិភាក្សាអំពីការវាយប្រហារដោយពួកខ្មែរក្រហមចូលទៅក្នុងទឹកដីវៀតណាម នៅខែ មករា ឆ្នាំ ១៩៧៧៖ "ជាទូទៅ បញ្ជារួមធ្វើចេញពី ៨៧០ ដែលចេញបញ្ជាទៅភូមិភាគផ្សេងៗ។ បន្ទាប់មក ភូមិភាគបង្កើតគណបញ្ជាការមួយទៀត ដែលមានសមាសភាពទាំងតំបន់ និង ភូមិភាគចូលរួម។ រួចហើយគណកម្មាធិការនេះឯកភាពគ្នាជាមួយមជ្ឈិម ដើម្បីវាយប្រហារចូលទៅក្នុងទឹកដីវៀតណាម")។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ៣៖ សម្ភារៈម្រាប់ត្រៀមរៀបចំកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីបឋម៖ សេចក្តីសង្ខេបអំពីសាក្សីរបស់ក្រុមមេធាវីការពារក្តីរបស់ នួន ជា, E93/4.3, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រទី ៤៩-៥០ (ញត្តិរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្នើសុំស្តាប់សក្ខីកម្មរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយសារគាត់"អាចផ្តល់ព័ត៌មានលម្អិតអំពីស្ថានការណ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងរចនាសម្ព័ន្ធបញ្ជាមួយបែបទៀតក្នុងរបបខ្មែរក្រហម និងតួនាទីរបស់ប្រទេសវៀតណាម។ ជាងនេះទៅទៀត គាត់អាចផ្តល់ព័ត៌មានពិស្តារអំពីការជ្រៀតជ្រែកខាងនយោបាយ និងការចោទប្រកាន់អំពីអំពើពុករលួយនៅ អ.វ.ត.ក")។ អង្គជំនុំជម្រះ បានបដិសេធសំណើនេះ ដោយផ្អែកលើមូលដ្ឋានដដែល។

01004754



### ៣.៣.២ បុគ្គលទាំងឡាយដែលត្រូវបានចាត់ទុកថាពាក់ព័ន្ធច្រើនទៅនឹងការជំនុំជម្រះក្ដីនៅថ្ងៃអនាគត ក្នុងសំណុំរឿង ០០២ ឬពាក់ព័ន្ធជាពិសេសទៅនឹងជនជាប់ចោទទាំងអស់ដែលត្រូវបានបំបែកចេញពីកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១

127. តាមសេចក្ដីសម្រេចស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ និងលើកទីពីរ សំណើសុំរបស់សហព្រះរាជអាជ្ញាដើម្បីដាក់បញ្ចូលមន្ទីរស-២១ និងការសម្លាប់មនុស្សនៅស្រុក ១២ នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានបដិសេធ និងវិសាលភាពនៃការជំនុំជម្រះក្ដីលើកទីមួយក្នុងសំណុំរឿង ០០២ ត្រូវបានកំណត់យកត្រឹមតែការជម្លៀសប្រជាជន និងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ។ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងមិនបានកែប្រែវិសាលភាពសំណុំរឿង ០០២/០១ នោះទេ[212]។ ហេតុដូច្នេះដោយសារតែគ្មានសេចក្ដីណែនាំផ្ទុយណាមួយពីអង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូងសម្រេចពន្យារការស្ដាប់សក្ខីកម្មបុគ្គលខាងក្រោមដែលត្រូវបានស្នើឡើងដោយភាគីក្នុងសំណុំ-រឿង០០២/០១ ទៅការជំនុំជម្រះក្ដីនៅថ្ងៃខាងមុខ[213]៖

---

[212] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ឯកសារE284/4/8 ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣។ *សូមមើលផងដែរ*សេចក្ដីសង្ខេបសម្អាងហេតុនៃសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ ក្នុងសំណុំរឿង ០០២ របស់អង្គជំនុំជម្រះសាលាដំបូង, E284/4/7, ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣។

[213] សេចក្ដីសម្រេចស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ បន្ទាប់ពីសេចក្ដីសម្រេចរបស់អង្គជំនុំ-ជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, E284, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣។

*ពាក់ព័ន្ធនឹងស្រុក ១២*[214]៖

- សាក្សី TCW-៦៥១ ស៊ឹម ទន់
- សាក្សី TCW-១៦២ ឌី យ៉េត
- សាក្សី TCW-១៦០ ឌុយ ដុក
- សាក្សី TCW-៤២២ ម៉ូត ម៉ាញ
- សាក្សី TCW-២៩៨ កែប មឿន

*ពាក់ព័ន្ធនឹងមន្ទីរស-២១*[215]៖

- សាក្សី TCW-៥៤០ ប្រាក់ ខន
- សាក្សី TCW-៦៩៨ សួស ធី
- ដើមបណ្តឹងរដ្ឋប្បវេណី TCCP-២១ ជុំ ម៉ី
- សាក្សី TCW-២៣២ ហ៊ឹម ហ៊ុយ
- សាក្សី TCW-៣១៦ ខៀវ ចេស
- សាក្សី TCW-៣៤៨ គក ស្រស់
- សាក្សី TCW-៣៦៧ ឡាច មាន
- សាក្សី TCW-៣៧៩ ឡាយ ចាន់
- សាក្សី TCW-៤០៥ លី ហ៊ា

[214] ឧបសម្ព័ន្ធ II, ផ្នែក x។ *សូមមើលផងដែរ* បុគ្គលទាំងឡាយដែលភាគីបានស្នើសុំឱ្យស្តាប់សក្ខីកម្មនៅក្នុងពេលជំនុំជម្រះក្តី ដែលក្នុងពេល ឬ បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការភ្លាម ត្រូវបានជូនដំណឹងដល់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង, E236, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ផ្នែកទី ៦-៧។ ឧបសម្ព័ន្ធ ក៖ សំណើសុំរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងកាលបរិច្ឆេទសវនាការដែលបានស្នើសុំ សម្រាប់ដំណាក់កាលចុងក្រោយនៃសំណុំរឿង ០០២, E273.1, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣។

[215] ឧបសម្ព័ន្ធ II, ផ្នែក ix។ *សូមមើលផងដែរ* បុគ្គលទាំងឡាយដែលភាគីបានស្នើសុំឱ្យស្តាប់សក្ខីកម្មនៅក្នុងពេលជំនុំជម្រះក្តី ដែលក្នុងពេល ឬ បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការភ្លាម ត្រូវបានជូនដំណឹងដល់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង, E236, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ផ្នែកទី ៦-៧។ ឧបសម្ព័ន្ធ ក៖ សំណើសុំរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងកាលបរិច្ឆេទសវនាការដែលបានស្នើសុំសម្រាប់ដំណាក់កាលចុងក្រោយនៃសំណុំរឿង ០០២, E273.1, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣។

- សាក្សី TCW-៤៧៩ នង ចាន់ផល
- សាក្សី TCW-៥១២ ប៉ែស ម៉ាត់
- សាក្សី TCW-៥២៣ ភោគ ខន
- សាក្សី TCW-៥៣ ប៊ិត ថុន
- សាក្សី TCW-៥៩៨ អោម ម៉េត
- សាក្សី TCW-៦៣២ សេក ជន
- សាក្សី TCW-៨៨ ជាម សួ
- ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-២២ ជុំ នៅ
- ដើមបណ្ដឹងរដ្ឋប្បវេណី TCCP-៩៣ ណាំ ម៉ុន
- សាក្សី TCW-៤១០ ម៉ម ណៃ
- សាក្សី TCW-៤៤១ ម៉ុម ឆ្វុត
- សាក្សី TCW-៤៧០ ញ៉ែម អេន
- សាក្សី TCW-៤៧៤ នឹម គឹមស្រ៊ាង
- សាក្សី TCW-៤៩ ប៊ូ ម៉េង
- សាក្សី TCW-១១៥ ជាម នឿន
- សាក្សី TCW-១២៥ ជុំ ផល
- សាក្សី TCW-១៤០ ដែង ឈឿវ
- សាក្សី TCW-២៩០ កា ស៊ុនបូណាត
- សាក្សី TCW-៤៩៩ ប៉ាន សុខុន
- សាក្សី TCW-៦៥៥ Francoise SIRONI-GUILBARD
- សាក្សី TCW-១១៨ ជិន ម៉េត។

128. ក្រោយពីបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ និងការរំលត់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី កាលពីថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ និងថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានសម្រេចពាក់ព័ន្ធនឹងបុគ្គលជាច្រើនរូប ដែលត្រូវបានស្នើសុំក្នុងសំណុំរឿង ០០២/០១ និងត្រូវបានអះអាងថាមានភាពពាក់ព័ន្ធគ្នាជាចម្បងតែទៅនឹង

ជនជាប់ចោទទាំងអស់នោះតែប៉ុណ្ណោះ ដូច្នេះ មិនមានតម្រូវការស្តាប់សក្ខីកម្មពួកគាត់នៅក្នុងការជំនុំជម្រះក្តីនេះទៀតហើយ។ បន្ថែមលើសាក្សីដូចបានរៀបរាប់ខាងលើ ដែលរួមមានសាក្សី TCW-៧២៤, TCW-៧៩៤, TCW-៧៩៦, TCW-៦៧៩, TCW-២៤៣ និង TCW-២៩២, អង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណបុគ្គលជាច្រើនរូបបន្ថែមទៀត ថាមិនចាំបាច់ត្រូវស្តាប់សក្ខីកម្មដ្បិតសក្ខីកម្មរបស់ពួកគាត់ ទំនងជាមានភាពពាក់ព័ន្ធជាចម្បងតែទៅនឹងតួនាទីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ឬ អៀង សារី ឬ ពាក់ព័ន្ធតិចតួចទៅនឹងសំណុំរឿង ០០២/០១[216]៖

- សាក្សី TCW-៧២៥ ធុច ស៊ីថន
- សាក្សី TCW-៦០០ សៅ ណៃ
- សាក្សី TCW-៧៧៨ យ៉ាង រិន
- សាក្សី TCW-៩០ ជា ផាន
- សាក្សី TCW-១៨ អាង នាង
- សាក្សី TCW-៣២៥ ខូ វណ្ណី

129. ទោះបីជាសហព្រះរាជអាជ្ញា បានស្នើសុំឱ្យស្តាប់សក្ខីកម្មសាក្សីខាងក្រោមនេះ ជាពិសេសក្នុងដំណាក់កាលក្រោយៗមកទៀតនៃការជំនុំជម្រះ នៅមុនសវនាការបញ្ចប់ការពិភាក្សាដេញដោលភស្តុតាងក្នុងសំណុំរឿង ០០២/០១ យ៉ាងណាក្តី អង្គជំនុំជម្រះពិចារណាឃើញថា បុគ្គលទាំងនេះមានភាពពាក់ព័ន្ធទៅនឹងផ្នែកផ្សេងទៀតនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ច្រើនជាង ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចពន្យារពេលស្តាប់សក្ខីកម្មរបស់បុគ្គលខាងក្រោមនេះសិន ដោយរង់ចាំស្តាប់នៅក្នុងសវនាការជំនុំជម្រះក្តីនាពេលអនាគតនៃសំណុំរឿង ០០២[217]៖

---

[216] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ឯកសារលេខ E138/1/10/1/5/7 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២។ សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី ឯកសារ E270/1 ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣។

[217] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា ឆ្លើយតបទៅនឹងសំណើរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ សុំឱ្យផ្តល់ព័ត៌មានមុនកិច្ចប្រជុំរៀបចំសវនាការ, E288/3, ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌទី ៥ (ស្នើសុំស្តាប់សក្ខីកម្មសាក្សី TCW-781 ពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន)។ ឧបសម្ព័ន្ធ ក៖ សំណើសុំរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងកាលបរិច្ឆេទសវនាការដែលបានស្នើសុំ សម្រាប់ដំណាក់កាលចុងក្រោយនៃសំណុំរឿង ០០២, E273.1,

- សាក្សី TCW-៧៩ ចាន់ ម៉ាន
- សាក្សី TCW-៦៩៦ សួន រី
- សាក្សី TCW-៧៨១ យ៉េន គុច

### ៣.៣.៣ បុគ្គលដែលមានក្នុងបញ្ជីដំបូងៗក្នុងសំណុំរឿង ០០២/០១ ប៉ុន្តែមិនត្រូវបានអង្គជំនុំជម្រះកំណត់ថាពាក់ព័ន្ធក្នុងការស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ឬគ្មានភាគីណាស្នើសុំ

130. បន្ទាប់ពីអង្គជំនុំជម្រះបានស្នើឲ្យភាគីកំណត់អត្តសញ្ញាណ (ចេញពីបញ្ជីធំនៃសំណុំរឿង ០០២ របស់ពួកគាត់ពាក់ព័ន្ធនឹងវិធាន៨០នៃវិធានផ្ទៃក្នុង) បុគ្គលទាំងឡាយណាដែលអាចមានការពាក់ព័ន្ធទៅនឹងផ្នែកដំបូងៗនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០១ ភាគីបានដាក់បញ្ជីដែលបានកែសម្រួលរបស់ខ្លួននៅពាក់កណ្តាលឆ្នាំ ២០១១។ បុគ្គលទាំងអស់ដែលមានរាយនាមក្នុងបញ្ជីទាំងនោះ ត្រូវបានអង្គជំនុំជម្រះពិនិត្យ ដើម្បីរកមើលភាពអាចពាក់ព័ន្ធ និងតម្លៃភ័ស្តុតាង បន្ទាប់មកអង្គជំនុំជម្រះ បានចេញបញ្ជីមួយរបស់ខ្លួន នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ដោយមានរាយនាមបុគ្គលទាំងឡាយដែលអង្គជំនុំជម្រះចាត់ទុកថាមានភាពពាក់ព័ន្ធ និងគប្បីស្តាប់សក្ខីកម្មនៅក្នុងដំណាក់កាលដំបូងៗនៃវគ្គសវនាការនេះ។ បុគ្គលជាច្រើនដែលមានឈ្មោះនៅក្នុងបញ្ជីពាក់កណ្តាលឆ្នាំ ២០១១ នេះ មិនត្រូវបានកំណត់អត្តសញ្ញាណដោយអង្គជំនុំជម្រះថាមានភាពពាក់ព័ន្ធខ្លាំង និងមិនគប្បីស្តាប់សក្ខីកម្មក្នុងសំណុំរឿង០០២/០១ នេះទេ។ ម្យ៉ាងទៀត ក្រោយមក គ្មានភាគីណាមួយបានស្នើសុំឲ្យស្តាប់សក្ខីកម្មបុគ្គលទាំងនេះពាក់ព័ន្ធនឹងផ្នែកណាមួយនៃការជំនុំជម្រះក្តីវគ្គនេះ ឬ វគ្គក្រោយៗទៀតណាមួយនោះទេ (ឧបសម្ព័ន្ធ II ផ្នែក xiii(ក))។ ដូច្នេះ បុគ្គលទាំងអស់ដែលមានក្នុងឧបសម្ព័ន្ធ II ផ្នែក xiii មិនត្រូវបានស្តាប់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះទេ ដោយសារភាពមិនពាក់ព័ន្ធ និងច្រំដែល(វិធាន៨៧(៣)(ក)នៃវិធានផ្ទៃក្នុង)។ បុគ្គលឯទៀតនៅក្នុងផ្នែកនេះ ត្រូវបានកំណត់អត្តសញ្ញាណពាក់ព័ន្ធតែទៅនឹងការចោទប្រកាន់ទៅលើដំណើរការ និងការប្រព្រឹត្តិទៅនៃការស៊ើបសួរ ឬ ការចោទប្រកាន់ទូទៅអំពីភាពយុត្តិធម៌នៃការជំនុំជម្រះតែប៉ុណ្ណោះ (ឧបសម្ព័ន្ធ II ផ្នែក

---

ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣ (ស្នើសុំស្តាប់សក្ខីកម្មសាក្សី TCW-៦៩៦ និងសាក្សី TCW-៧៩ ក្នុងពេលជំនុំជម្រះក្តី)។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ម៉ន, D166/116, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៩។ ជីវប្រវត្តិរបស់ ខាត់ ខាន់ ហៅ សួន រី, E3/172, ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ិន គុជ, E3/437, ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២។

xiii(ខ) និង ត្រូវបានបដិសេធ ដោយសារមូលហេតុដូចគ្នាទៅនឹងអ្នកទាំងអស់ដូចដែលបានពិពណ៌នាខាងលើ (ផ្នែក ៣.៣.១)។

131. ចំណែកបុគ្គលផ្សេងទៀតក្នុងឧបសម្ព័ន្ធនេះ មិនត្រូវបានកំណត់អត្តសញ្ញាណឱ្យគ្រប់គ្រាន់ ដែលផ្ទុយទៅនឹងដីកា E9 របស់អង្គជំនុំជម្រះសាលាដំបូង (ឧបសម្ព័ន្ធ II ផ្នែក xiii(គ))[218]។ ក្នុងដំណាក់កាលមុនអង្គសេចក្តី ភាគីត្រូវបានបង្គាប់ឱ្យកំណត់អត្តសញ្ញាណឱ្យបានគ្រប់គ្រាន់ចំពោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនីមួយៗដែលខ្លួនបានស្នើសុំ ដើម្បីអនុញ្ញាតឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញស្វែងរកអ្នកទាំងនោះឱ្យឃើញក្នុងរយៈពេលសមស្របមួយ ដើម្បីជូនដំណឹងដល់ភាគីដទៃអំពីបុគ្គលណាខ្លះដែលត្រូវបានស្នើសុំកោះហៅ និងដើម្បីអាចឱ្យអង្គជំនុំជម្រះ សម្រេចលើភាពពាក់ព័ន្ធរបស់អ្នកទាំងអស់នោះបាន[219]។ អង្គជំនុំជម្រះបដិសេធភ័ស្តុតាងនេះ ដោយសំអាងលើមូលដ្ឋាននៃភាពអាចពាក់ព័ន្ធតិចតួច ភាពច្រំដែល និង/ឬ ភាពទំនងជាមិនអាចរកបានក្នុងរយៈពេលសមស្របមួយ (វិធាន ៨៧(៣)(ក) និង (ខ) នៃវិធានផ្ទៃក្នុង)[220]។

---

[218] *សូមមើលផងដែរ* ឧបសម្ព័ន្ធ II, ផ្នែក i (បញ្ជាក់ថាសាក្សី TCW-៤៩១ ដែលត្រូវបានដាក់បញ្ចូលក្នុងឯកសារ E236 (បុគ្គលទាំងឡាយដែលភាគីបានស្នើសុំឱ្យស្តាប់សក្ខីកម្មនៅក្នុងពេលជំនុំជម្រះក្តី ដែលក្នុងពេល ឬ បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការភ្លាម ត្រូវបានជូនដំណឹងមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង, E236, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ផ្នែកទី ៧) ត្រូវបានកំណត់ថាខ្វះព័ត៌មានជាក់លាក់)។

[219] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, E9, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ កថាខណ្ឌទី ២ និងទី ៦។ ព័ត៌មានលម្អិតដែលតម្រូវឱ្យមាន រួមមានឈ្មោះពេញ ភេទ ថ្ងៃខែឆ្នាំកំណើត និងទីកន្លែងកំណើត អាសយដ្ឋានបច្ចុប្បន្ន និង/ឬ ព័ត៌មានលម្អិតសម្រាប់ទាក់ទងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញ ដែលត្រូវបានស្នើ។ ជាមួយគ្នាផងដែរ អង្គជំនុំជម្រះតម្រូវឱ្យភាគផ្តល់នូវ "i) សេចក្តីសង្ខេបអង្គហេតុពាក់ព័ន្ធនឹងសាក្សីដែលបានស្នើនីមួយៗ ដែលនឹងត្រូវមកធ្វើសក្ខីកម្ម ឬ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗដែលត្រូវស្តាប់សក្ខីកម្ម ត្រូវសង្ខេបអង្គហេតុ ឬ ផលប៉ះពាល់នៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់។ [...] សេចក្តីសង្ខេបនោះ គប្បីមានព័ត៌មានលម្អិតល្មមអាចឱ្យអង្គជំនុំជម្រះ និង ភាគីដទៃទៀតយល់ពេញលេញអំពីដើមចម និង ខ្លឹមសារនៃសក្ខីកម្មរបស់បុគ្គលដែលបានស្នើសុំស្តាប់សក្ខីកម្មនោះ និង ii) សេចក្តីសង្ខេបស្តីពីអ្នកជំនាញដែលបានស្នើ និង គុណវុឌ្ឍិរបស់អ្នកជំនាញម្នាក់ៗ។ [...] សេចក្តីសង្ខេបនោះ គប្បីមានព័ត៌មានលម្អិតល្មមអាចឱ្យអង្គជំនុំជម្រះ និងភាគីដទៃទៀត យល់ពេញលេញអំពីដើមចម និងខ្លឹមសារនៃសក្ខីកម្មរបស់អ្នកជំនាញដែលបានស្នើសុំស្តាប់សក្ខីកម្មនោះ"។

[220] បុគ្គលជាច្រើនត្រូវបានស្នើឡើង ដោយពុំមានព័ត៌មានអត្តសញ្ញាណគ្រប់គ្រាន់ ឬ ពុំមានការពន្យល់អំពីភាពពាក់ព័ន្ធរបស់ពួកគេនោះឡើយ។ ឧទាហរណ៍ ក្រុមមេធាវីការពារក្តី នួន ជា បានស្នើសុំកោះហៅប្រវត្តិវិទូនៃសភាពសូវៀត ឬ ប្រទេស រុស្ស៊ី ជាច្រើននាក់ ដោយពុំបានផ្តល់ការបញ្ជាក់អំពីភាពពាក់ព័ន្ធរបស់ពួកគេចំពោះសំណុំរឿង ០០២ នេះឡើយ

## ៣.៤ បុគ្គលទាំងឡាយដែលមានក្នុងបញ្ជីដើមរបស់ភាគី អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងសំណុំរឿង ០០២ ទាំងមូល ដែលគ្មានភាគីណាមួយក្នុងសំណុំរឿង ០០២/០១ បានស្នើសុំឱ្យស្តាប់សក្ខីកម្ម

132. បុគ្គលទាំងឡាយដែលនៅសេសសល់ពីក្នុងចំណោមបបុគ្គលទាំង ១០៥៤ នាក់ ដែលភាគីបានស្នើសុំឱ្យស្តាប់សក្ខីកម្មនៅក្នុងពេលជំនុំជម្រះសម្រាប់សំណុំរឿង ០០២ ទាំងមូល ហើយដែលមានឈ្មោះនៅក្នុងបញ្ជីសាក្សីដើមអនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុងរបស់ភាគី គឺបុគ្គលទាំងឡាយណាដែលមិនមានភាគីណាមួយបានស្នើសុំឱ្យស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ឬអង្គជំនុំជម្រះយល់ឃើញថា មិនពាក់ព័ន្ធនឹងការជំនុំជម្រះក្តីដំណាក់កាលនេះ (ឧបសម្ព័ន្ធIII)។ ទោះបីជាយ៉ាងណាក្តី ដោយសារតែបុគ្គលខ្លះក្នុងចំណោមនេះ អាចមានភាពពាក់ព័ន្ធទៅនឹងផ្នែកផ្សេងទៀតនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ការសម្រេចសេចក្តីពាក់ព័ន្ធនឹងបុគ្គលទាំងនោះនឹងត្រូវពន្យារពេលទៅថ្ងៃក្រោយ រហូតមានសវនាការនាថ្ងៃអនាគត ។ បុគ្គលមួយចំនួនទំនងជាត្រូវបានកំណត់ដោយខ្វះព័ត៌មានសំខាន់ៗជាក់លាក់ ឬទំនងជាបានទទួលមរណភាពទៅហើយ (ឧបសម្ព័ន្ធ III(ខ))។

## ៣.៥ សេចក្តីសន្និដ្ឋាន

133. ដោយសារមានបុគ្គលជាច្រើនដែលភាគីស្នើសុំរួមគ្នានៅដំណាក់កាលជំនុំជម្រះក្តី អង្គជំនុំ-ជម្រះកំណត់អត្តសញ្ញាណបុគ្គលទាំងឡាយណាដែលខ្លួនយល់ឃើញថា ទំនងជាមានភាពពាក់ព័ន្ធ

---

(*សូមមើល ឧទាហរណ៍* អ្នកជំនាញ TCE-២០ (Sheila FITZPATRICK), អ្នកជំនាញTCE-២៣ (John ARCH GETTY), អ្នកជំនាញ TCE-២៤ (Wendy GOLDMAN) និង អ្នកជំនាញ TCE-៥៦ (Gabor Tamas RITTERSPORN))។ ចំណែកបុគ្គលដែលត្រូវបានស្នើសុំឯទៀត ក្រុមមេធាវីការពារក្តី ទទួលស្គាល់ថា ពួកគេមានមន្ទិលដោយមិនដឹងថា អ្នកទាំងនោះនៅរស់នៅឡើយ ឬយ៉ាងណា (*សូមមើល ឧទាហរណ៍* សាក្សីដែលត្រូវបានស្នើ ដូចជាសាក្សី TCW-១០១, សាក្សីTCW-១៥៤, សាក្សីTCW-២២២, សាក្សី TCW-២៦៦, សាក្សី TCW-២៧៩, សាក្សី TCW-៣១១, សាក្សី TCW-៣៣៧, សាក្សីTCW-៤១៩, សាក្សីTCW-៤៣០, សាក្សីTCW-៤៩៩, សាក្សីTCW-៥៧៧, សាក្សី TCW-៦១៨, សាក្សីTCW-៦៣៣, សាក្សីTCW-៦៦០, សាក្សីTCW-៧០៥, សាក្សី TCW-៧៣៤, សាក្សីTCW-៧៣៥; សាក្សីTCW-៧៩១; សាក្សី TCW-១៤, សាក្សីTCW-៣៩, សាក្សីTCW-៨៥, សាក្សីTCW-២០៩, សាក្សី TCW-២២០ និង សាក្សីTCW-៥៧៣)។ ក្នុងចំណោមសាក្សីបន្ថែមទាំងនេះ ភាគច្រើន មិនត្រូវបានស្តាប់សក្ខីកម្មក្នុងអំឡុងពេលស៊ើបអង្កេតនោះទេ។

និងមានតម្លៃភ័ស្តុតាងច្រើនជាងគេចំពោះអង្គហេតុដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះ មិនដាក់បញ្ចូលការស្តាប់សក្ខីកម្មផ្ទាល់មាត់ពីបុគ្គលទាំងឡាយណាដែលផ្តល់ភ័ស្តុតាងច្រំដែល ដូចគ្នាទៅនឹងភ័ស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះពីមុនមករួចហើយនោះទេ។ ដោយសារដំណាក់កាលមុនអង្គសេចក្តីក្នុងសំណុំរឿង ០០២ មានរយៈពេលយូរ ដែលក្នុងពេលនេះ មានបុគ្គលជាច្រើនរូបត្រូវបានស្តាប់សក្ខីកម្មដោយសហចៅក្រម ស៊ើបអង្កេត ដូច្នេះ អង្គជំនុំជម្រះបានពិចារណាថាតើ សក្ខីកម្មរបស់បុគ្គលមួយចំនួនបន្ថែមទៀតដែលត្រូវបានស្នើសុំក្នុងដំណាក់កាលនៃអង្គសេចក្តីនេះ ធ្លាប់ត្រូវបានស្នើសុំក្នុងដំណាក់កាលមុនអង្គសេចក្តីដែរ ឬ យ៉ាងណា ហើយអង្គជំនុំជម្រះក៏ពិចារណាអំពីមូលហេតុទាំងឡាយដែលនាំឲ្យសហចៅក្រមស៊ើបអង្កេតសម្រេចមិនស្តាប់ភ័ស្តុតាងបែបនេះនៅពេលដែលខ្លួនដឹងអំពីអត្ថិភាពរបស់វា។ ដោយសារមានបុគ្គលជាច្រើនត្រូវបានស្នើសុំឲ្យស្តាប់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុ ឬបញ្ហាដូចគ្នា អង្គជំនុំជម្រះចង់ស្តាប់តែភ័ស្តុតាងរបស់បុគ្គលណាដែលត្រូវបានស្នើសុំដោយភាគីមួយ ឬច្រើនជាងមួយនៃកិច្ចដំណើរការនីតិវិធី ឬសក្ខីកម្មណាដែលក្តោបលើប្រធានបទច្រើនក្នុងពេលជំនុំជម្រះក្តី ឬ សក្ខីកម្មណាដែលត្រូវបានចាត់ទុកថា ទំនងជាមានភាពពាក់ព័ន្ធ ឬ តម្លៃភ័ស្តុតាងច្រើនជាងគេ។

134. អង្គជំនុំជម្រះអនុម័តយកវិធីសាស្ត្រតាមដំណាក់កាល ក្នុងការជ្រើសរើសបុគ្គលដែលត្រូវយកមកស្តាប់សក្ខីកម្មនៅពេលជំនុំជម្រះក្តី ដើម្បីផ្តល់ជូនភាគីនូវឱកាសតាមដំណាក់កាល ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលខ្លួនយល់ឃើញថាមានសារសំខាន់ខ្លាំង ដើម្បីស្តាប់សក្ខីកម្មពាក់ព័ន្ធនឹងផ្នែកនៃការជំនុំជម្រះក្តីនីមួយៗ។ នៅមុនសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានផ្តល់ជូននូវបញ្ជីបណ្តោះអាសន្នមួយ ដែលអង្គជំនុំជម្រះយល់ឃើញថាមានភាពពាក់ព័ន្ធបំផុតទៅនឹងផ្នែកដំបូងៗនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង០០២។ បញ្ជីឈ្មោះសាក្សីចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ត្រូវបានចេញ បន្ទាប់ពីមានដីកាបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ហើយភាគីបានដាក់សារណាពាក់ព័ន្ធនឹងបញ្ជីបណ្តោះអាសន្ននេះ។ បញ្ជីដដែលនេះ ត្រូវបានយកមកពិនិត្យក្នុងដំណាក់កាលនៃការជំនុំជម្រះក្តី ហើយចំនួនបុគ្គលក្នុងបញ្ជីត្រូវបានកាត់បន្ថយខ្លះ ដើម្បីជាប្រយោជន៍ដល់ការសន្សំសំចៃរបស់តុលាការ។ បុគ្គលបន្ថែមមួយចំនួនទៀត ត្រូវ

បានបញ្ចូលបន្ថែមទៅក្នុងបញ្ជីនេះផងដែរ ដ្បិតប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ[221]។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការលើកទីពីរ អង្គជំនុំជម្រះស្នើឱ្យភាគីផ្តល់យោបល់ពាក់ព័ន្ធនឹងសំណើសុំកាត់បន្ថយចំនួនបុគ្គលនៅក្នុងបញ្ជីនេះ។ ភាគីត្រូវបានផ្តល់ឱកាស ដើម្បីកំណត់អត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធនឹងផ្នែកនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០១ ដែលនៅសេសសល់ ដោយផ្តោតជាពិសេសទៅលើតម្រូវការឱ្យក្រុមមេធាវីការពារក្តីកំណត់សាក្សីដែលអាចផ្តល់ភស្តុតាងដោះបន្ទុក។ យោងលើមូលដ្ឋានដែលបានពីការផ្តល់មតិនៅក្នុងកិច្ចប្រជុំរៀបចំសវនាការលើកទីពីរ អង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណសាក្សីទាំងអស់ដែលខ្លួនយល់ឃើញថាមានភាពពាក់ព័ន្ធជាងគេ ដើម្បីស្តាប់សក្ខីកម្មលើអង្គហេតុនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ១ និងទី ២ និងទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ និងបុគ្គលមួយចំនួនទៀតដែលក្រុមមេធាវីការពារក្តីកំណត់អត្តសញ្ញាណថា មានសារសំខាន់ខ្លាំងក្នុងការផ្តល់សក្ខីកម្មដោះបន្ទុកចំពោះបទចោទប្រកាន់មកលើជន-ជាប់ចោទ។ ចុងក្រោយ អង្គជំនុំជម្រះបានពិនិត្យរាល់បុគ្គលដែលសហព្រះរាជអាជ្ញាបានស្នើសុំនៅក្នុងបញ្ជី ខែ មីនា ឆ្នាំ ២០១៣ របស់ខ្លួន និងបុគ្គលទាំងឡាយដែលត្រូវបានភាគីកំណត់ថាមានភាពចាំបាច់ក្នុងការស្តាប់សក្ខីកម្ម នៅមុនការបិទបញ្ចប់កិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលភស្តុតាងក្នុងសំណុំរឿង ០០២/០១ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការដែលធ្វើចុងក្រោយបង្អស់នៅក្នុងខែ មិថុនា ឆ្នាំ ២០១៣។

135. ពេលចេញសេចក្តីសម្រេចនេះ អង្គជំនុំជម្រះបានថ្លឹងថ្លែងនូវរាល់សារណាដែលភាគីបានលើកឡើងនៅរាល់កិច្ចប្រជុំរៀបចំសវនាការ ដើម្បីគាំទ្រការកោះហៅបុគ្គលជាក់លាក់មួយចំនួនសម្រាប់សវនាការលើអង្គសេចក្តី និងសវនាការស្តាប់សក្ខីកម្មសាក្សី ព្រមទាំងពាក្យសុំជាលាយលក្ខណ៍អក្សរនានាដែលភាគីបានដាក់ក្នុងដំណាក់កាលនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង០០២/០១។

---

[221] *សូមមើល ឧទាហរណ៍* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១", E172, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១២ (កំណត់លំដាប់លំដោយសវនាការស្តាប់សក្ខីកម្មបុគ្គលទាំងឡាយដែលមានក្នុងបញ្ជីថ្ងៃទី ២៥ ខែ តុលាការ ឆ្នាំ ២០១១ និង គូសបញ្ជាក់ថា បុគ្គលជាច្រើនផ្សេងទៀតនឹងត្រូវស្តាប់សក្ខីកម្មផងដែរ ក្នុងពេលជំនុំជម្រះក្តី)។ អនុស្សរណៈអង្គជំនុំជម្រះ សាលាដំបូង ដែលមានចំណងជើងថា "សេចក្តីណែនាំទៅភាគីក្រោយសវនាការថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២", E233, ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ កថាខណ្ឌទី ៥ (ប្រកាសថា សាក្សី TCW-៧៥៤ និង សាក្សីTCW-១០០ នឹងត្រូវស្តាប់សក្ខីកម្មផងដែរ)។

**អាស្រ័យដូចបានរៀបរាប់ក្នុងសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេច៖**

**មិន** កោះហៅបុគ្គលទាំងអស់ដែលមានឈ្មោះក្នុងឧបសម្ព័ន្ធ II នៃសេចក្តីសម្រេចនេះដើម្បីមកផ្តល់សក្ខីកម្មនៅក្នុងការជំនុំជម្រះក្តីនៃសំណុំរឿង ០០២/០១ និង/ឬ ពន្យារការស្តាប់សក្ខីកម្មនេះរហូតដល់ការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២ នាថ្ងៃអនាគត។

**ពន្យារ** ការសម្រេចសេចក្តីពាក់ព័ន្ធនឹងបុគ្គលទាំងអស់ក្នុងឧបសម្ព័ន្ធ III នៃសេចក្តីសម្រេចនេះរហូតដល់មានការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២ នាថ្ងៃអនាគត។

ភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE PREMIERE INSTANCE

**និល ណុន**